GE.

ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៤ រាជធានីភ្នំពេញ

# វេទិកាពិគ្រោះយោបល់លើកទី ១ ស្តីពី ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និង ប្រសិទ្ធភាព នៅថ្នាក់ឃុំ/សង្កាត់ក្នុងប្រទេសកម្ពុជា

**សហការរៀបចំដោយៈ**

អង្គការ យេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C) និង ក្រសួងមហាផ្ទៃ



**ឧបត្ថម្ភដោយៈ**

**GTZ-ARDP**

ក្រសួងមហាផ្ទៃ
Ministry of Interior

ADMINISTRATION REFORM AND DECENTRALIZATION PROJECT

# មាតិកា

ទំព័រ


១ - **សុន្ទរកថាស្វាគមន៍**

ថ្លែងដោយ លោកស្រី រស់ សុភាព ............ ១

២ - **វេទិកាពិគ្រោះយោបល់**

ថ្លែងដោយ ឯកឧត្តម ព្រុំ សុខា ............ ៤

៣ - **វេទិកាពិគ្រោះយោបល់**

ថ្លែងដោយ លោកស្រី ប៉ុក ណណ្ដា ............ ៨

៤ - **យេនឌ័រ និងវិមជ្ឈការ**

ថ្លែងដោយ លោកស្រី អេង នេត្រា ............ ១៤

៥ - **បទពិសោធន៍ និងការតស៊ូបញ្ចូល**

ថ្លែងដោយ លោកស្រី វង់ ស៊ូ ............ ២២

៦ - **បទពិសោធន៍ និងការតស៊ូបញ្ចូល**

ថ្លែងដោយ លោកស្រី គង់ ផល្លី ............ ២៤

៧ - **បទពិសោធន៍ និងការតស៊ូបញ្ចូល**

ថ្លែងដោយ លោកស្រី ហាក់ លី ............ ២៧

៨ - **តួនាទីរបស់អង្គការស្ត្រី និងប្រសិទ្ធិភាព**

ថ្លែងដោយ លោកស្រី ធីតា ឃីះ ............ ២៩

៩ - **បទពិសោធន៍នៃប្រវត្តិជោគជ័យ**

ថ្លែងដោយ លោកស្រី រស់ សុភាព ............ ៣៥

១០ - **កូតាជាអ្វី?** ............ ៤១

១១ - **សុន្ទរកថាបិទ**

ថ្លែងដោយ កញ្ញា Shelley Flam ............ ៤៣

## **កម្មវិធី**

ថ្ងៃចន្ទ័ ទី១៧ ខែ មករា ឆ្នាំ ២០០៥

ទីកន្លែង : **អង្គការទស្សនៈពិភពលោក**
ផ្ទះលេខ ២០ ផ្លូវលេខ ៧១ សង្កាត់ទន្លេបាសាក់
ខ័ណ្ឌចំការមន រាជធានីភ្នំពេញ

ពេលព្រឹក:

០៧:៣០-០៨:០០ ការមកដល់របស់អ្នកចូលរួម
ការចុះឈ្មោះ

០៨:០០-៨:៤០ **វគ្គ ១**

០៨:០០-៨:៤០ **ការបើកវគ្គ**
អ្នកសម្របសម្រួល : **លោក ឆាយ គឹមស៊័រ**
ប្រធានកម្មវិធីបណ្តុះបណ្តាល និងកម្មសិក្សា
អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា ( GAD/C )

**តំណាងអង្គការ យេនឌ័រ និង អភិវឌ្ឍន៍ ដើម្បីកម្ពុជា** (GAD/C)
**លោកស្រី រស់ សុភាព**
នាយិកាប្រតិបត្តិ

**តំណាង** GTZ
**លោក លូក ជី ម៉េសស្ន៊ើរ**
ប្រធានក្រុមនៃការកែទំរង់រដ្ឋបាល និងវិមជ្ឈការ

**តំណាងក្រសួងមហាផ្ទៃ និង គណៈអធិបតីនៃ " វេទិកាពិគ្រោះយោបល់លើកទី ១ ស្តីពីការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងប្រសិទ្ធិភាពនៅថ្នាក់ឃុំ/សង្កាត់ក្នុងប្រទេសកម្ពុជា "**

305-43
FOR
sh: Gender

**ឯកឧត្តម ព្រុំ សុខា**
រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ

៨:៤០-៩:៣៥ **វគ្គ២**

៨:៤០-៩:៣៥ **ការបង្ហាញផ្នែកទី ១**
អ្នកសម្របសម្រួល : **លោកស្រី កែវ គៀង**
អនុប្រធាន
អង្គការ Pact កម្ពុជា

៨:៤០-៩:០០ ប្រធានបទ : *សារៈសំខាន់នៃការចូលរួមផ្នែកនយោបាយរបស់ស្ត្រីក្នុងប្រទេសកម្ពុជា*
ដោយ: **លោកស្រី ប៉ុក ណាណា**
នាយិកាប្រតិបត្តិ
អង្គការចំរើនស្ត្រី ( WFP )

៩:០០-៩:២០ ប្រធានបទ : *ណែនាំអំពី យេនឌ័រ និងវិមជ្ឈការ*
ដោយ: កញ្ញា **អេង នេត្រា**
អ្នកស្រាវជ្រាវ
អង្គការ CDRI

៩:២០-៩:៣៥ សំណួរ និងចំលើយ

៩:៣៥-៩:៥០ សំរាក

៩:៥០-១១:៤៥ **ការបង្ហាញផ្នែកទី ២**

៩:៥០-១០:២០ បង្ហាញដោយ: **លោកស្រី វ៉ង់ ស៊ូ** ប្រធានក្រុមប្រឹក្សាឃុំមានជ័យ ស្រុកសំឡូត ខេត្តបាត់ដំបង
ប្រធានបទ : *បទពិសោធន៍ និងការតស៊ូះបញ្ចាំងរបស់ក្រុមប្រឹក្សាឃុំដែលជាស្ត្រី នៅខេត្តបាត់ដំបង*

១០:២០-១០:៥០ បង្ហាញដោយ: **លោកស្រី គង់ ចន្នី** ក្រុមប្រឹក្សាឃុំក្របៅ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ

ប្រធានបទ : *បទពិសោធន៍ និងការឆ្លុះបញ្ចាំងរបស់ក្រុមប្រឹក្សាឃុំដែលជាស្ត្រីនៅខេត្តកំពង់ធំ*

១០:៥០-១១:២០ បង្ហាញដោយ: **លោកស្រី ចាក់ លី** ក្រុមប្រឹក្សាឃុំរំចេក ស្រុកបន្ទាយស្រី ខេត្តសៀមរាប
ប្រធានបទ : *បទពិសោធន៍ និងការឆ្លុះបញ្ចាំងរបស់ក្រុមប្រឹក្សាឃុំដែលជាស្ត្រីនៅខេត្តសៀមរាប*

១១:២០-១១:៤៥ សំណួរ និងចំលើយ

ពេលរសៀល/ល្ងាច:

២:០០-៣:០៥ **ការបង្ហាញផ្នែកទី ៣**
អ្នកសម្របសម្រួល : **លោកស្រី កែវ គៀង**
អនុប្រធាន
អង្គការ Pact កម្ពុជា

២:០០-២:២០ បង្ហាញដោយ: **លោកស្រី ទីតា យ៉ិះ**
នាយិកាប្រតិបត្តិ
អង្គការសីលការ
ប្រធានបទ: *តួនាទីអង្គការស្ត្រី និងស្ត្រីចូលរួមក្នុងវិស័យនយោបាយ និងប្រសិទ្ធិភាព*

២:២០-២:៥០ បង្ហាញដោយ: **លោកស្រី រស់ សុភាព**
នាយិកាប្រតិបត្តិ
អង្គការ យេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា (GAD/C )
ប្រធានបទ: *ការរៀនពីបទពិសោធន៍នៃប្រទេសឥណ្ឌា*

២:៥០-៣:០៥ សំណួរ និងចំលើយ

៣:០៥-៥:០០ **វគ្គ ៣**

៣:០៥-៥:០០ **ការពិភាក្សាក្រុម**

៣:០៥-៣:១៥ **ការរៀបចំក្រុមពិភាក្សា** ( ក្នុងក្រុមនីមួយៗមានអ្នកចូលរួម ១៦នាក់ និងអ្នកសម្របសម្រួល ១ នាក់ )

**ប្រធានបទ:**

១.ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ដែលជាស្ត្រី-តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល

២.ការរៀបចំសំរាប់ការបោះឆ្នោតឃុំ/សង្កាត់ឆ្នាំ ២០០៧-តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល

៣.ការរៀនពីបទពិសោធន៍នៃប្រទេសឥណ្ឌា

៣:១៥-៤:០០ **ការពិភាក្សាជាក្រុម ( ក្រុម១ ) អ្នកស្រី ចូរ៉ា ញ៉ឹបចឹង**
ប្រធានផ្នែកតស៊ូមតិ និងបណ្តាញ
ប្រធានបទ: *ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ដែលជាស្ត្រី-តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល*

៣:១៥-៤:០០ **ការពិភាក្សាជាក្រុម ( ក្រុម២) លោក អ៊ុច លាង**
ជំនួយការកម្មវិធីបណ្តុះបណ្តាល និងកម្មសិក្សា
ប្រធានបទ: *ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ដែលជាស្ត្រី-តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល*

៣:១៥-៤:០០ **ការពិភាក្សាជាក្រុម ( ក្រុម ៣ ) លោក ចី សម្បត្តិ**
អ្នកបណ្តុះបណ្តាលយេនឌ័រ
ប្រធានបទ: *ការរៀបរាប់ការបោះឆ្នោះឃុំ/សង្កាត់ឆ្នាំ ២០០៧-តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល*

៣:១៥-៤:០០ **ការពិភាក្សាជាក្រុម ( ក្រុម ៤ ) លោក ឡាំ សុជាតិ**
មន្ត្រីកម្មវិធីតស៊ូមតិ និងបណ្តាញ

ប្រធានបទ: *ការរៀបរាប់ការបោះឆ្នោតឃុំ/សង្កាត់ឆ្នាំ ២០០៧*

*តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល*

ប្រធានបទ: *ការរៀនពីបទពិសោធន៍ នៃប្រទេសឥណ្ឌា*

៤:០០-៤:៥០ ការបង្ហាញរបស់ក្រុមពិភាក្សា និងសំនួរ ចំលើយ

៤:៥០-៥:០០ **ការបិទវគ្គ**

ដោយ: Shelley Flam

ទីប្រឹក្សាការបណ្តុះបណ្តាលសមត្ថភាពសង្គមស៊ីវិល

GTZ-ARDP

# វេទិកាពិគ្រោះយោបល់លើកទី ១
# ស្តីពីការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និង ប្រសិទ្ធិភាព
# នៅថ្នាក់ឃុំ/សង្កាត់ក្នុងប្រទេសកម្ពុជា

អ្នកសម្របសម្រួលៈ

**លោក គាយ តឹមស៊័រ**

ប្រធានបទកម្មវិធីបណ្តុះបណ្តាល និងកម្មសិក្សា

អង្គការយេនឌ័រ និង អភិវឌ្ឍន៍ ដើម្បីកម្ពុជា ( GAD/C )

**លោកស្រី កែវ គៀង**

អនុប្រធាន អង្គការ Pact កម្ពុជា

អ្នករៀបចំឯកសារៈ

**លោក ឆុន ចន្ថែល**

ជំនួយការកម្មវិធីតស៊ូមតិ និង បណ្តាញ

អង្គការ យេនឌ័រ និង អភិវឌ្ឍន៍ ដើម្បីកម្ពុជា ( GAD/C )

**លោក ទៃ ចំរើន**

ជំនួយការកម្មវិធីអប់រំ និងពត៌មាន

អង្គការ យេនឌ័រ និង អភិវឌ្ឍន៍ ដើម្បីកម្ពុជា ( GAD/C )

**លោក ចង់ សុជាតិ**

ជំនួយការកម្មវិធីអប់រំ និងពត៌មាន

អង្គការ យេនឌ័រ និង អភិវឌ្ឍន៍ ដើម្បីកម្ពុជា ( GAD/C )

**លោក អនុបណ្ឌិត សូលី វណ្ណា ប៊ុក**

ទីប្រឹក្សា GTZ ក្នុងគំរោងសហប្រតិបត្តិការកម្ពុជា អាល្លឺម៉ង់ ជួយក្នុងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការនៃរាជរដ្ឋាភិបាលកម្ពុជា

អ្នកបកប្រែៈ

**លោក ទូច ចារ័រិទ្ធិ**

អ្នកបកប្រែ និងជំនួយការកម្មវិធី GTZ

អ្នកគ្រប់គ្រងទូទៅ:

**លោកស្រី ម៉ូរ៉ា ហ្វីបប៊ីង**

អង្គការ យេនឌ័រ និង អភិវឌ្ឍន៍ ដើម្បីកម្ពុជា ( GAD/C )

ប្រធានកម្មវិធីតស៊ូមតិ

**កញ្ញា សាត ធីតា**

ជំនួយការកម្មវិធីតស៊ូមតិ និងបណ្ដាញ

អង្គការ យេនឌ័រ និង អភិវឌ្ឍន៍ ដើម្បីកម្ពុជា ( GAD/C )

**លោក ឡាំ សុជាតិ**

មន្ត្រីកម្មវិធីតស៊ូមតិ និងបណ្ដាញ

អង្គការ យេនឌ័រ និង អភិវឌ្ឍន៍ ដើម្បីកម្ពុជា ( GAD/C )

អ្នកសម្របសម្រួលការពិភាក្សាក្រុម:

**លោកស្រី ម៉ូរ៉ា ហ្វីបប៊ីង**

អង្គការ យេនឌ័រ និង អភិវឌ្ឍន៍ ដើម្បីកម្ពុជា ( GAD/C )

ប្រធានកម្មវិធីតស៊ូមតិ

**លោក អ៊ុន ណាង**

ជំនួយការកម្មវិធីបណ្ដុះបណ្ដាល និងកម្មសិក្សា

អង្គការ យេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា (GAD/C)

**លោក ឡាំ សុជាតិ**

មន្ត្រីកម្មវិធីតស៊ូមតិ និងបណ្ដាញ

អង្គការ យេនឌ័រ និង អភិវឌ្ឍន៍ ដើម្បី កម្ពុជា ( GAD/C )

**លោក ទូច ថាវរិទ្ធិ**

អ្នកបកប្រែ និងជំនួយការកម្មវិធីGTZ

## បញ្ជីរឈ្មោះជាភាសាខ្មែរ

វេទិកាពិគ្រោះយោបល់លើកទី ១ ស្តីពីការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងប្រសិទ្ធិភាពនៅថ្នាក់ ឃុំ/សង្កាត់ ក្នុងប្រទេសកម្ពុជា
ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥

### តំណាងអង្គការមិនមែនរដ្ឋាភិបាល និង អង្គការអន្តរជាតិ

| | | |
|---|---|---|
| ១- | ខនណី បយអ៊ិល | អនុប្រធាន VBNK |
| ២- | លោក អ៊ុស្មាអ៊ែល អ៊ុត្រាស្មុនតេ | ប្រធាន គំរោងគាំទ្រក្រុមប្រឹក្សាឃុំ |
| ៣- | លោក ឃីត ម៉ាក់លាដ | តំណាង អង្គការ PACT ប្រចាំប្រទេស |
| ៤- | លោកស្រី លីអូនី វ៉ិនរ៉យធ៍ | អ្នកសំរបសំរួលកម្មវិធី អង្គការ Oxfam GB |
| ៥- | លោក ម៉ាក មូណូស | ប្រធានកម្មវិធីជាតិ CLI. Concern |
| ៦- | លោកស្រី ចាក់ឃ្យូលីន ផម៉េរ៉យ | តំណាងមូលនិធិអាស៊ី |
| ៧- | លោកស្រី កូណូ សាតូកូ | ទីប្រឹក្សា ការបង្កើតគំរោង អង្គការ JICA |
| ៨- | លោក ស៊ីយ៉ាម បឺថែល | ទីប្រឹក្សាគោលនយោបាយ UNDP ក្នុងគំរោងគាំទ្រវិមជ្ឈការ |
| ៩- | លោកស្រី អាន់ជីលីកា ហ្វិដជីមែន | ប្រធានក្រុម GTZ-RDP |
| ១០- | លោកស្រី ស៊ូហ្សាន ម៉ុយឡឺ | ប្រធានក្រុមលើកកំពស់សិទ្ធិស្ត្រី GTZ |
| ១១- | ស៊ែល្លី ហ្លាម | ទីប្រឹក្សាការកសាងសមត្ថភាព សង្គមស៊ីវិល GTZ |
| ១២- | ណាស្តារ៉ាន់ មូសាវី | តំណាងអង្គការ Ockenden International ប្រចាំប្រទេស |
| ១៣- | អ៊ីឡេន ម៉ាក់ខេ | ទីប្រឹក្សាការគ្រប់គ្រងគំរោង និង គោលនយោបាយជាន់ខ្ពស់ UNDP |
| ១៤- | លុក ដឺ ម៉ឺស្ត | ប្រធានក្រុម GTZ |
| ១៥- | លោកស្រី ណៃ ឌីណា | នាយកវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ |
| ១៦- | កញ្ញា អេង នេត្រា | អ្នកស្រាវជ្រាវនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា |

| | |
|---|---|
| ១៧- លោក យក់ ប៊ុនណា | ប្រធានគំរោងពុទ្ធសាសនិកដើម្បីអភិវឌ្ឍន៍ |
| ១៨- លោក ម៉ម សម្បត្តិ | អ្នកតំណាងមូលដ្ឋានរបស់អង្គការស៊ីដសេ |
| ១៩- លោក ឈ ចាន់សុផល | ទីប្រឹក្សាប្រធាន |
| ២០- លោក យី កុសលវឌ្ឍនៈ | សិទ្ធិកុមារ UNICEF |
| ២១- អ៊ុម ស៊ីវ៉ាន់ | មូលនិធិ Konrad Adenauer Foundation |
| ២២- លោកស្រី កែវ គៀង | អនុប្រធានតំណាង PACT ប្រចាំប្រទេស |
| ២៣- លីន លូស៊ីត | ទីប្រឹក្សាអង្គការ UNICEF |
| ២៤- ម៉ារីអូឡែន កូរ៉ែន-រីឡឹមស្ទ្រីក | ទីប្រឹក្សាអង្គការ UNFPA |
| ២៥- សារ៉ា អានឌឺសុន | ទីប្រឹក្សាយេនឌ័រអង្គការ Forum Syd |

**តំណាងអង្គការក្នុងស្រុកមិនមែនរដ្ឋាភិបាល**

| | |
|---|---|
| ២៦- លោក លឹម ផៃ | នាយកគណៈកម្មកាធិការ សំរបសំរួល អភិវឌ្ឍន៍ទីក្រុង (USG) |
| ២៧- លោកស្រី លឹម មុន្នី | ប្រធានផ្នែកដឹកនាំស្ត្រី អាដហុក |
| ២៨- លោកស្រី ស្រី ចាន់ផល្លាក៉ា | នាយិកាប្រតិបត្តិ អង្គការ HRCOP |
| ២៩- លោកស្រី វេជ្ជបណ្ឌិត ពុង ឈីវកេក | ប្រធានអង្គការ លីកាដូ |
| ៣០- លោក ញឹក សារិន | នាយកអង្គការ ស្តារកម្ពុជា |
| ៣១- លោក គល់ បញ្ញា | នាយកប្រតិបត្តិ អង្គការ COMFREL |
| ៣២- លោក បាង់ ពុទ្ធា | នាយកប្រតិបត្តិគណៈកម្មាធិការ អព្យាក្រឹត និងយុត្តិធម៌ដើម្បីការ បោះឆ្នោតដោយសេរី និង ត្រឹមត្រូវ នៅកម្ពុជា (NECFIC) |
| ៣៣-លោក យង់ គីមអេង | ប្រធានសមាគមយុវជនខ្មែរ |
| ៣៤- លោកស្រី ហោ ផល្លី | នាយិកាគំរោងប្រឆាំង នឹង អំពើហិង្សា ក្នុងគ្រួសារ |
| ៣៥- លោកស្រី ឯក សុផាន់ណា | អ្នកសំរបសំរួលយេនឌ័រ វេទិការ អង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា |
| ៣៦- លោកស្រី ឈឿង ស៊ុនឡាយ | មន្ត្រីកម្មវិធីសមាគមអភិវឌ្ឍន៍ស្ត្រីកម្ពុជា |

៣៧- លោកស្រី អ៊ុង ចាន់ថុល — នាយិកាប្រតិបត្តិមជ្ឈមណ្ឌលស្ត្រីមានវិបត្តិកម្ពុជា

៣៨- លោកស្រី ស៊ុំ សាទុម — នាយិកាប្រតិបត្តិអង្គការសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា

៣៩- លោកស្រី ប៊ូ ចន្ទូ — នាយិកាប្រតិបត្តិ PADEK

៤០- លោកស្រី សូភាជ សេរីធីតា — នាយិកាប្រតិបត្តិ សមាគមនារីអភិវឌ្ឍន៍

៤១- លោកស្រី ជា វណ្ណាត — នាយិកាប្រតិបត្តិមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម

៤២- លោកស្រី ជា មួយគ្រី — មន្ត្រីកម្មវិធីអង្គការកាតូលិកសង្គ្រោះនិងអភិវឌ្ឍន៍ក្រៅប្រទេស

៤៣- លោកជំទាវ ប៉ុក ណាណ្ដា — នាយិកាប្រតិបត្តិ អង្គការចំរើនស្ត្រី

៤៤- លោកស្រី ធីតា ឃីះ — នាយិកាប្រតិបត្តិ អង្គការសីលការ

## អង្គការមិនមែនរដ្ឋាភិបាលនៅតាមបណ្ដាខេត្តនានា

៤៥- លោកស្រី អោក ឡុងឌី — នាយិកាប្រតិបត្តិ អង្គការគាំពារការអភិវឌ្ឍន៍ និងការបណ្ដុះបណ្ដាល

៤៦- លោកស្រី ចៅ គីម អេង — នាយិកាប្រតិបត្តិ សមាគមស្ត្រីដើម្បីអភិវឌ្ឍន៍សហគមន៍

៤៧- លោកស្រី អ៊ឹង យក់ឃន — នាយិកា អង្គការ AMARA

៤៨- លោកស្រី ឃឹម លាងអ៊ុ — នាយិកា អង្គការបង្កើនសមត្ថភាពសហគមន៍ដើម្បីអភិវឌ្ឍន៍

៤៩- លោកស្រី អ៊ុក គីមណារី — នាយិកាប្រតិបត្តិ អង្គការ ស្ត្រីសន្តិភាពដើម្បីបរិស្ថាន

៥០- លោកស្រី នាង ប៉េងហ៊ា — អ្នកសំរបសំរួលអង្គការដៃគូអភិវឌ្ឍន៍

## កម្មវិធីពង្រឹងសិទ្ធិអំណាចស្ត្រីតាមរយៈចំណេះដឹងច្បាប់

៥១- លោកស្រី អុក សុគន្ធា — ជនបង្គោល WELA ខេត្តព្រៃវែង

៥២- លោកស្រី សន គីមហួន — ជនបង្គោល WELA ខេត្តពោធិសាត់

៥៣- លោកស្រី ទូច សាវឿត ជនបង្គោល WELA ខេត្តកំពង់ឆ្នាំង

៥៤- លោកស្រី គ្រួស សារ៉ែម ជនបង្គោល WELA ខេត្តកំពង់ឆ្នាំង

## រដ្ឋាភិបាល

### ក្រសួងកិច្ចការនារី

៥៥- លោកស្រី ញ៉ាន សុចិត្រា អនុប្រធាននាយកដ្ឋានផែនការ ក្រសួងកិច្ចការនារី

៥៦- លោកស្រី យិន សារ៉ាត់ ជនបង្គោលយេនឌ័រ នៃក្រសួងកិច្ចការនារី

### ក្រសួងអភិវឌ្ឍន៍ជនបទ

៥៧- លោកស្រី ឡាច សាម៉ន អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធានគណៈកម្មកាធិការនារី និងប្រធាន យេនឌ័រ

៥៨- លោក លាបសំណាង អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ និង អនុប្រធានក្រុម ការងារយេនឌ័រ

### ក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន)

៥៩- ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ

៦០- លោក លេង វី ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ

៦១- លោកស្រី ទិត្យ ប៉ូលី មន្ត្រីការិយាល័យរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ

៦២- លោក ចាន់ គឿយ អនុប្រធានការិយាល័យបណ្តុះបណ្តាល កសាងសមត្ថភាពនៃនាយកដ្ឋានរដ្ឋបាល

| | |
|---|---|
| | មូលដ្ឋានក្រសួងមហាផ្ទៃ |
| ៦៣- លោក ខោល យុទ្ធលី | អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ |
| ៦៤- លោក សេង សីហា | អនុប្រធានការិយាល័យ ស្ថិតិ និងពត៌មាននៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ |
| ៦៥- ឯកឧត្តម សក់ សេដ្ឋា | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ |
| ៦៦- លោក អ៊ឹង សោភ័ណ | មន្ត្រីការិយាល័យហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ |
| ៦៧- លោក ទិត សាវ៉ុឡី | មន្ត្រីការិយាល័យស្រាវជ្រាវបច្ចេកទេស នៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ |

**ក្រុមប្រឹក្សាឃុំ/សង្កាត់ជាស្ត្រី**

២៤ ខេត្តក្រុង

# បញ្ជីរាយនាមតំណាងក្រុមប្រឹក្សាឃុំ/សង្កាត់ ជាស្ត្រី ចូលរួមក្នុងវេទិកាប្រឹក្សាយោបល់លើកទី ១ ស្តីពីស្ត្រីចូលរួមក្នុងវិស័យនយោបាយ និង ប្រសិទ្ធភាពនៅឃុំ_សង្កាត់ នៅកម្ពុជា

| ល.រ | នាម-គោត្តនាម | មុខងារ | ឃុំ/សង្កាត់ | ស្រុក/ខណ្ឌ | ខេត្ត/ក្រុង | គណបក្ស | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១ | កញ្ញា ពៅ មួយ | សមាជិក | ព្រៃធំ | កែប | កែប | ប្រជាជន | |
| ២ | លោកស្រី ខាវ ចាន់ទ្រី | សមាជិក | ប្រាសាទ | ស្ទឹងត្រែង | ស្ទឹងត្រែង | ប្រជាជន | |
| ៣ | លោកស្រី សោម ពៅ | សមាជិក | ត្រាំកក់ | ត្រាំកក់ | តាកែវ | ប្រជាជន | |
| ៤ | លោកស្រី ជឹម ចាន់ | សមាជិក | មនោរម្យ | សែនមនោរម្យ | មណ្ឌលគិរី | ប្រជាជន | |
| ៥ | លោកស្រី គឹម ស៊ុនណារី | មេឃុំ | អណ្តូងពោធិ | រមាសហែក | ស្វាយរៀង | ប្រជាជន | |
| ៦ | កញ្ញា ខៀវ សុភឿន | មេឃុំ | ប្រស្នឹប | រលាប្អៀរ | កំពង់ឆ្នាំង | ប្រជាជន | |
| ៧ | លោកស្រី យាង ស៊ីផាន | សមាជិក | សំបូរមាស | កំពង់ចាម | កំពង់ចាម | ប្រជាជន | |
| ៨ | លោកស្រី ម៉ុង សំអាត | សមាជិក | ប៉ាលហាល | ត្បែងមានជ័យ | ព្រះវិហារ | ប្រជាជន | |
| ៩ | លោកស្រី ក្វាង សុផាណារី | ជំទប់ទី១ | តាតៃក្រោម | កោះកុង | កោះកុង | ប្រជាជន | |
| ១០ | លោកស្រី វង្ស ស៊ូ | មេឃុំ | មានជ័យ | សំឡូត | បាត់ដំបង | ប្រជាជន | |
| ១១ | លោកស្រី ម៉េង ស៊ីនួន | សមាជិក | ម្រោម | អង្គរជ័យ | កំពត | ប្រជាជន | |
| ១២ | លោកស្រី ហួន សារុន | ចៅសង្កាត់ | សង្កាត់លេខ៤ | មិត្តភាព | ព្រះសីហនុ | ប្រជាជន | |
| ១៣ | លោកស្រី វ៉ែន សុខុម | មេឃុំ | សន្ទ្រែ | ភ្នំក្រវាញ | ពោធិសាត់ | ប្រជាជន | |
| ១៤ | លោកស្រី ម៉ៅ រឿន | សមាជិក | ជើងទឹក | កំពង់លាវ | ព្រៃវែង | ប្រជាជន | |
| ១៥ | លោកស្រី អ៊ុំសុខា | សមាជិក | អូរឬស្សី | ក្រចេះ | ក្រចេះ | ហ៊្វុនស៊ិនប៉ិច | |
| ១៦ | លោកស្រី ខឹម ផល្លា | ជំទប់ទី១ | ស្វាយដង្គំ | សៀមរាម | សៀមរាប | ហ៊្វុនស៊ិនប៉ិច | |
| ១៧ | លោកស្រី នឹម សុខា | សមាជិក | អូរតាវ៉ៅ | ប៉ៃលិន | ប៉ៃលិន | ប្រជាជន | |
| ១៨ | លោកស្រី កុលសុខនី | សមាជិក | ត្រាចទង | ឧត្តុង្គ | កំពង់ស្ពឺ | ហ៊្វុនស៊ិនប៉ិច | |
| ១៩ | លោកស្រី ហ៊ុល គីមថុន | សមាជិក | ទឹកជោរ | ព្រះនេត្រព្រះ | បន្ទាយមានជ័យ | ហ៊្វុនស៊ិនប៉ិច | |
| ២០ | លោកស្រី | | | | ឧត្តរមានជ័យ | ហ៊្វុនស៊ិនប៉ិច | |
| ២១ | លោកស្រី មឿង ចាន់ឌី | សមាជិក | ឡាបានសៀក | បានលុង | រតនគិរី | សម រង្ស៊ី | |
| ២២ | លោកស្រីមួង ផាច័ន្ទមុនី | សមាជិក | តាខ្មៅ | តាខ្មៅ | កណ្តាល | សម រង្ស៊ី | |
| ២៣ | លោកស្រី សេងវណ្ណារី | ចៅសង្កាត់ | អូឡាំពិច | ចំការមន | រាជធានីភ្នំពេញ | ប្រជាជន | |
| ២៤ | លោកស្រី គង់ ផល្លី | សមាជិក | កំពង់ក្របៅ | ស្ទឹងសែន | កំពង់ធំ | សម រង្ស៊ី | |

# សុន្ទរកថាស្វាគមន៍ ... វេទិកាពិគ្រោះយោបល់លើកទី ១ ស្តីពី ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និង ប្រសិទ្ធិភាព នៅថ្នាក់ឃុំ-សង្កាត់ក្នុងប្រទេសកម្ពុជា




ថ្លែងដោយ : លោកស្រី រស់ សុភាព
នាយិកាប្រតិបត្តិ អង្គការ យេនឌ័រ និង អភិវឌ្ឍន៍ ដើម្បី កម្ពុជា

ខ្ញុំសូមស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ដែលមានវត្តមានក្នុងវេទិកាពិគ្រោះយោបល់លើកទី១ ស្តីពីការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងប្រសិទ្ធិភាពនៅឃុំ-សង្កាត់ក្នុងប្រទេសកម្ពុជា នៅថ្ងៃនេះ។ ជាបឋមនាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ :

- ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
- លោក Luc de Meester ប្រធានក្រុមនៃគំរោងវិមជ្ឈការ និងកំណែទំរង់រដ្ឋបាលរបស់អង្គការ GTZ ចំពោះការគាំទ្រ និងកិច្ចសហការក្នុងការរៀបចំវេទិកានេះ។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ចំពោះភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ពិសេសគឺសមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ទាំង ២៤រូប ដែលអញ្ជើញមក ពី ២៤ខេត្ត-ក្រុង ក្នុងប្រទេសកម្ពុជាដែលត្រៀមនឹងចែករំលែកបទពិសោធន៍របស់ខ្លួនជាមួយយើងខ្ញុំក្នុងថ្ងៃនេះ។

អង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា (GAD/C) គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយដែលមានបេសកកម្ម ដើម្បីលើកស្ទួយសមធម៌យេនឌ័រក្នុងវិស័យសេដ្ឋកិច្ចសង្គម និងនយោបាយ នៅប្រទេសកម្ពុជា ដោយមានការខិតខំជាប្រចាំដើម្បីធ្វើការតស៊ូមតិអោយមានការកែទំរង់គោលនយោបាយ និងច្បាប់ដែលទាក់ទងទៅនឹងសិទ្ធិស្ត្រី។ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា (GAD/C) បានអនុវត្តនូវបេសកកម្មនេះដោយសហការដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនានា អង្គការអន្តរជាតិជាច្រើនទៀត និងរាជរដ្ឋាភិបាលកម្ពុជាផងដែរ។

ក្នុងនាមជាសមាជិកមួយ នៃអង្គការក្រៅរដ្ឋាភិបាលដែលបាន និងកំពុងធ្វើការដើម្បីលើកស្ទួយស្ថានភាពស្ត្រី អង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា (GAD/C) ធ្វើការតស៊ូមតិដើម្បីបង្កើនការចូលរួមរបស់ស្ត្រីទាំងក្នុងវិស័យនយោបាយ និងសង្គម។ អង្គការយេនឌ័រ និងអភិវឌ្ឍន៍

ដើម្បីកម្ពុជា (GAD/C) បានសហការជាមួយរាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីលើកឡើងពីបញ្ហា យេនឌ័រ និងអប់រំស្ត្រី និងបុរសនៅគ្រប់កំរិតទាំងអស់ក្នុងសង្គមអោយយល់ពីសារៈសំខាន់ នៃការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយ។

ជាមូលដ្ឋាននៃការលើកកំពស់ស្ថានភាពស្ត្រីក្នុងប្រទេសកម្ពុជា គឺត្រូវតែមានការទទួលស្គាល់ពីសារៈសំខាន់នៃតំណាងស្ត្រីក្នុងវិស័យសាធារណៈ។ ក្នុងទសវត្សចុងក្រោយនេះ តួនាទីរបស់ស្ត្រីក្នុងការសំរេចចិត្តនឹងឆាកនយោបាយក្នុងប្រទេសកម្ពុជា គឺមានការប្រែប្រួលគួរឱ្យកត់សំគាល់ ហើយសព្វថ្ងៃនេះស្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងជីវិតសាធារណៈ។ ជាប្រវត្តិសាស្ត្រប្រទេសកម្ពុជាមិនដែលឃើញមានកំរិតនៃការចូលរួមក្នុងឆាកនយោបាយរបស់ស្ត្រីដូចដែលមានសព្វថ្ងៃនេះទេ។ ថ្មីៗនេះក្នុងចំណោមអ្នកតំណាងក្នុងរដ្ឋសភាជាតិ ១២៣នាក់ មាន ១៩នាក់ ជាស្ត្រីគឺស្មើនឹង ១២%។ មានស្ត្រីចំនួន ៩៣៨នាក់ ជាសមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងចំណោមសមាជិកសមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់ចំនួន ១១ ២៦១ នាក់ ដែលគិតជាភាគរយគឺ ៨%។ លើសពីនេះទៀតមាន ៩% នៃមន្ត្រីស៊ីវិលជាន់ខ្ពស់ក្នុងចំណោមក្រសួង ១០ គឺជាស្ត្រី ទោះបីជាយ៉ាងណាក៏ដោយ ក្រៅពីចំនុចវិជ្ជមានដែលបានរៀបរាប់ខាងលើនេះ ការគាំទ្រស្ត្រីក្នុងតួនាទីសំរេចចិត្តក្នុងប្រទេសកម្ពុជា គឺកំពុងស្ថិតនូវការប្រឈមមុខនៅឡើយ។ រីឯអ្នកតំណាងស្ត្រីក្នុងវិស័យនយោបាយគឺមានចំនួនតិច ហើយស្ថិតក្នុងតំណែងនយោបាយដែលតែងតាំងនៅក្នុងថ្នាក់ជាតិ។ ដូចដែលឯកឧត្តម លោកជំទាវ លោក លោកស្រីបានជ្រាបហើយថា រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា គឺកំពុងធ្វើការដើម្បីសំរេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សន៍កម្ពុជា។ ថ្មីបើការខិតខំប្រឹងប្រែងដើម្បីអោយសំរេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សន៍ទី៣ ដែលលើកកំពស់សមភាពយេនឌ័រ និងពង្រឹងសិទ្ធិអំណាចស្ត្រីក៏ដោយ ក៏កិច្ចខិតខំប្រឹងប្រែងនេះនៅតែកំពុងប្រឈមមុខនៅឡើយ។ នាងខ្ញុំសូមយកឱកាសនេះ ដើម្បីជំរាបជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ពីគោលបំណងនៃវេទិកានេះដូចតទៅ :

- បណ្តុះនូវគោលជំហជារួមអោយដឹងអំពីសារៈសំខាន់នៃការចូលរួមដ៏មានប្រសិទ្ធិភាពក្នុងឆាកនយោបាយរបស់ស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់។
- ចែករំលែកបទពិសោធន៍ដែលបានជួបប្រទះកន្លងមកនៃវត្តមានរបស់ស្ត្រីក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់កាលពី ២ ឆ្នាំមុន។
- ស្វែងរក និងទទួលបាននូវយោបល់កែលំអរអំពីក្រុមប្រឹក្សាឃុំ-សង្កាត់ដែលជាស្ត្រី
- ចាប់ផ្តើមកិច្ចពិភាក្សាស្តីអំពីប្រព័ន្ធនៃការវាស់វែងផ្សេងៗដូចជាកូតា និងវិធានការស្របច្បាប់ (Affirmative Action) នៅក្នុងបរិបទកម្ពុជា។

**ឧទាហរណ៍ :** ប្រពន្ធ័កូតា និងវិធានការស្របច្បាប់ក្នុងបរិបទកម្ពុជា

- ទិសដៅឆ្ពោះទៅមុខ និងអនុសាសន៍

យើងខ្ញុំសង្ឃឹមថា វេទិកានេះនឹងសំរបសំរួលការពិភាក្សាដោយជំហរដែលនឹងផ្តល់ជាកម្មវិធីជាមូលដ្ឋានមួយ (platform) ធ្វើអោយអ្នកពាក់ពន្ធ័មានការយល់ដឹងពីបញ្ហាប្រឈមមុខដែលស្ត្រីកំពុងជួបប្រទះនៅក្នុងឃុំ-សង្កាត់ ។

តាមរយៈការយល់ដឹងនេះ យើងទាំងអស់គ្នានឹងធ្វើការសហការគ្នា ដើម្បីគាំទ្រដំណើរការនៃការប្រែប្រួលជាវិជ្ជមានរបស់ស្ត្រីក្នុងឆាកនយោបាយ នាងខ្ញុំទន្ទឹងរង់ចាំស្តាប់នូវការចែករំលែកបទពិសោធន៍របស់អស់លោក លោកស្រី ។

សូមអរគុណ!



ថ្លែងដោយ ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ

សូមគោរព!

ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោកស្រីអស់លោក ខ្ញុំមានកិត្តិយសក្រៃលែងដោយបានទទួលការអញ្ជើញឱ្យចូលរួមជាអធិបតីនៅក្នុងពិធីបើកវេទិកាលើកទីមួយ ស្តីពីការចូលរួមផ្នែកនយោបាយរបស់ស្ត្រី និងប្រសិទ្ធិភាពនៃការចូលរួមនេះនៅថ្នាក់ ឃុំ -សង្កាត់ នៅកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណចំពោះសមាជិកក្រុមប្រឹក្សា ឃុំ-សង្កាត់ ដែលបានអញ្ជើញមកពីខេត្តក្រុងទាំងអស់ដែលបានធ្វើដំណើរយ៉ាងឆ្ងាយដើម្បីចូលរួមនៅក្នុងវេទិកានេះ។ ការចូលរួមរបស់លោកស្រីជាសមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់គឺជាកិត្តិយសសំរាប់យើងទាំងអស់គ្នា ហើយខ្ញុំជឿជាក់ថា ការយល់ដឹង និងអនុសាសន៍របស់លោកស្រីទាំងអស់នឹងរួមចំណែកយ៉ាងសំខាន់ដល់ការអនុវត្តន៍ ការកែទំរង់វិមជ្ឈការនៅកម្ពុជាឱ្យទទួលបានជោគជ័យ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C ) ដែលបានចូលរួមរៀបចំវេទិកានេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រផងដែរចំពោះគំរោងកំណែទំរង់រដ្ឋបាល និងវិមជ្ឈការនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GTZ) ដែលបានផ្តល់ការគាំទ្រយ៉ាងទូលំទូលាយ និងយ៉ាងសកម្មរបស់ខ្លួនដល់ដំណើរការវិមជ្ឈការនៅកម្ពុជា។

ការអនុវត្តន៍កំណែទំរង់វិមជ្ឈការ គឺជាជំហានយ៉ាងសំខាន់នៅក្នុងដំណើរនៃការកែទំរង់អភិបាលកិច្ចជារួមនៅកម្ពុជា។

ទិសដៅនៃការកែទំរង់វិមជ្ឈការរបស់រាជរដ្ឋាភិបាលគឺ:

- ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យពហុបក្សនៅមូលដ្ឋាន
- ដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម
- ដើម្បីការកាត់បន្ថយភាពក្រីក្រ

គ្មានអ្វីដែលគួរសង្ស័យទេថា ការនាំយកការគ្រប់គ្រងបែបប្រជាធិបតេយ្យទៅដាក់ឱ្យនៅជិតប្រជាពលរដ្ឋនឹងជំរុញឱ្យមានអភិបាលកិច្ចដែល

មានការចូលរួមពេញលេញ និងមានការឆ្លើយតប ហើយក៏ជាការយកចិត្តទុកដាក់ជាក់ស្តែងដល់សំលេង និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងការធ្វើសេចក្តីសំរេចចិត្តការផ្តល់ធនធាន និងការផ្តល់សេវា។

នៅក្នុងទិសដៅទាំងនេះ មានការរំពឹងទុកថាប្រាកដជានឹងមានភាពជាតំណាង និងការចូលរួមដោយស្មើភាពគ្នារវាងស្ត្រី និងបុរស ហើយទាំងអស់គ្នានឹងទទួលបានផលប្រយោជន៍ដូចគ្នាពីសេចក្តីសំរេចចិត្ត សេវា និងធនធានតាមបែបវិមជ្ឈការ។

ក្នុងន័យនេះ ខ្ញុំសូមចូលរួមមតិយោបល់ខ្លះអំពីតួនាទីដែលអាចមាន និងផលប្រយោជន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ដែលយើងបាន និងបោះឆ្នោតជ្រើសរើសឡើង។

ក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់មានការទទួលខុសត្រូវយ៉ាងទូលំទូលាយក្នុងការជំរុញអភិបាលកិច្ចល្អនៅក្នុងសហគមន៍ និងការលើកកំពស់ការជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ-សង្កាត់។ ក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់មានកាតព្វកិច្ចៈ

- ជំរុញឱ្យប្រជាពលរដ្ឋទាំងគ្រប់រូបនៅក្នុងសហគមន៍ចូលរួមនៅក្នុងដំណើរការអភិបាលកិច្ច
- លើកកំពស់វប្បធម៌ដែលមានការចូលរួម និងប្រជាធិបតេយ្យដែលមានកិច្ចសហការរវាងគ្នា នឹងគ្នា
- វាយតំលៃសេចក្តីត្រូវការជាសាធារណៈក្នុងសហគមន៍របស់ខ្លួន ហើយជានិច្ចជាកាលត្រូវដាក់បញ្ចូលនៅក្នុងការវាយតំលៃនេះនូវសេចក្តីត្រូវការពិសេសរបស់ជនក្រីក្រ ក្រុមដែលមិនបានទទួលផលប្រយោជន៍ផ្សេងទៀត និងស្ត្រី
- ឆ្លើយតបចំពោះសេចក្តីត្រូវការជាសាធារណៈដោយធានា ឬ សំរបសំរួលឱ្យមានការផ្តល់សេវានិងហេដ្ឋារចនាសម្ព័ន្ធសមស្របដោយខ្លួនឯងផ្ទាល់ ឬ ដោយសហការជាមួយស្ថាប័នរបស់រដ្ឋាភិបាល ឬ ទីភ្នាក់ងារមិនមែនរដ្ឋាភិបាល
- មានគណនេយ្យភាពជាប្រចាំចំពោះសហគមន៍ក្នុងការអនុវត្តន៍ភារកិច្ចរបស់ខ្លួន

សកម្មភាពទាំងអស់នេះ ត្រូវតែអនុវត្តដោយមានការចូលរួមយ៉ាងពេញលេញ និងមានតម្លាភាពមានការរួមចំណែកពីប្រជាពលរដ្ឋពីសង្គមស៊ីវិល ពីក្រុមដែលមានផលប្រយោជន៍ ពិសេស (special interest groups) សហគមន៍នៅតាមភូមិ អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារផ្សេងទៀតនៅក្នុងឃុំ-សង្កាត់។

ដំណើរការនេះ ផ្តល់កាលានុវត្តភាព (opportunty) ដ៏មានតំលៃឱ្យស្ត្រីរួចចាកផុតពីស្ថានភាពដែលមិនទទួលបានផលប្រយោជន៍ ហើយកំណត់បាននូវតំរូវការរបស់ខ្លួនដែលមិនទាន់បានដោះស្រាយ ហើយដែលនោះ គឺជាចំណុចខ្វះខាតនៅក្នុង ឃុំ-សង្កាត់។ ប្រការនេះក៏បានធ្វើឱ្យក្រុមប្រឹក្សា ឃុំ-សង្កាត់ និងអ្នកពាក់ព័ន្ធទាំងអស់ទទួលស្គាល់កាន់តែច្បាស់ អំពីតួនាទីរបស់ស្ត្រី ហើយកំណត់បាននូវតំរូវការជាអាទិភាពរបស់ស្ត្រីនៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់។

ទោះជាយ៉ាងណាក៏ដោយ វាគឺជាប្រការខុសឆ្គងដែលយើងគិតថា គ្រាន់តែផ្តល់កាលានុវត្តភាពឱ្យស្ត្រីបានចូលរួមតែប៉ុណ្ណោះ គឺជាការគ្រប់គ្រាន់នោះ។ ជារឿយៗ ស្ត្រីមានទំលាប់ស្ងៀមស្ងាត់មិនចេះនិយាយស្តី។ ស្ត្រីជាច្រើនមិនអាចបញ្ចេញមតិរបស់ខ្លួនទេ ប្រសិនបើគ្មានការគាំទ្រ

មិនចេះនិយាយស្តី ។ ស្ត្រីជាច្រើនមិនអាច បញ្ចេញមតិរបស់ខ្លួនទេ ប្រសិនបើគ្មានការគាំទ្រ ហើយបើទោះបីជាសំលេងស្ត្រីត្រូវបានបញ្ចេញ ក៏ដោយ ក៏មិនប្រាកដថានឹងទទួលបាននូវការ យកចិត្តទុកដាក់ដែរ ។

ពុំមានចំលើយដ៏ងាយស្រួលចំពោះបញ្ហា នេះឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ជាការ សំខាន់ណាស់ដែលប្រជាពលរដ្ឋទាំងអស់នៅក្នុង ឃុំ-សង្កាត់ ជាពិសេសស្ត្រីត្រូវដឹង និងយល់ ពីសិទ្ធិរបស់ខ្លួនក្នុងការទាមទារឱ្យមានការយក ចិត្តទុកដាក់ព្រមទាំងយល់ពីរបៀបបង្ហាញ សេចក្តីត្រូវការពិសេសរបស់ខ្លួន ហើយតំរូវឱ្យ មានការឆ្លើយតបសមស្របពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

ឯក្រុមប្រឹក្សាឃុំ-សង្កាត់វិញត្រូវយល់អំពី កាតព្វកិច្ចរបស់ខ្លួនដោយមិនគ្រាន់តែស្តាប់ សំលេងទាំងនេះទេ ប៉ុន្តែថែមទាំងជួយលើក ទឹកចិត្តឱ្យស្ត្រីបង្ហាញការការពារ និងជំរុញសេចក្តី ត្រូវការ និងផលប្រយោជន៍របស់ពួកគេ ។ ការងារនេះ ត្រូវតែជាផ្នែកមួយនៃកម្មវិធី កសាងសមត្ថភាពជាទូទៅ និងការបង្កើត **"វប្បធម៌ប្រជាធិបតេយ្យ"** នៅថ្នាក់ជាតិ និងនៅ ថ្នាក់មូលដ្ឋាន ។

នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់នាឆ្នាំ ២០០២ មានបេក្ខជនឈរ ឈ្មោះជានារីតែ ១២,៣៧៨នាក់ គឺប្រមាណជាង ១៦ភាគរយប៉ុណ្ណោះ ។ ស្ត្រីចំនួន ៩៨៣ នាក់ ឬ ៨,៧៣ ភាគរយប៉ុណ្ណោះដែលបានជាប់ឆ្នោតជា សមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ទោះបីជា ភាគរយនៃស្ត្រីដែលបានជ្រើសតាំង និងជាប់ ឆ្នោតនេះមានសមាមាត្រខ្ពស់ជាងកាលការ បោះឆ្នោតជាតិនាឆ្នាំ ១៩៩៨ ក្តី ក៏តួលេខនេះ នៅមានកំរិតទាបដែរ បើគិតពីអត្រាស្ត្រីក្នុង ចំណោមប្រជាពលរដ្ឋជារួម ។ ប្រការនេះឆ្លុះ បញ្ចាំងយ៉ាងច្បាស់អំពីបញ្ហាយ៉ាងជ្រាលជ្រៅ នៅក្នុងសង្គមរបស់យើងដែលទាមទារឱ្យមាន ការយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាពីសំណាក់ តួអង្គទាំងអស់ ។

ដូចដែលបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាល ស្ត្រីមានតួនាទី សំខាន់ណាស់នៅក្នុងសេដ្ឋកិច្ច និងសង្គមរបស់ យើង ។ រាជរដ្ឋាភិបាលបានប្រឹងប្រែងគ្រប់បែប យ៉ាងដើម្បីកែលំអស្ថានភាពរបស់ស្ត្រីតាម រយៈការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ ។ យុទ្ធសាស្ត្រនេះ មានបំណងផ្តល់ឱ្យស្ត្រីខ្មែរនូវ តំលៃ និងក្តីសង្ឃឹមនៅក្នុងជីវិត ហើយឆ្លង តាមរយៈនេះសំដៅជំរុញការបញ្ជ្រាបយេនឌ័រ ។

ទិសដៅចំបងរបស់យើង គឺការកសាង សមត្ថភាពរបស់ស្ត្រី និងការកែប្រែឥរិយាបថ នៅក្នុងសង្គមដែលមានការរើសអើងចំពោះស្ត្រី ។ ដូច្នេះ "**ការចូលរួមប្រកបដោយអត្ថន័យរបស់ ស្ត្រីក្នុងស្ថាប័នអភិបាលកិច្ចនៅគ្រប់ថ្នាក់** " ត្រូវ បានកំណត់ថា ជាអាទិភាពមួយនៅក្នុងវិស័យ សំខាន់ៗ ទាំងប្រាំនៃផែនការនារីរតនៈពីឆ្នាំ ២០០៥ ដល់ ឆ្នាំ ២០០៩ ។

ជាការច្បាស់ណាស់ថា វិមជ្ឈការតាមរយៈ ក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលត្រូវបោះឆ្នោត ជ្រើសរើសឡើងពុំអាចឆ្លើយតបបានទាំងស្រុង

ចំពោះសេចក្តីត្រូវការរបស់ស្ត្រី ដែលតំរូវឱ្យមានវិធានការយ៉ាងទូលំទូលាយជាច្រើនថែមទៀតនោះទេ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ វិមជ្ឈការបានផ្តល់នូវជំរើស និងកាលានុវត្តភាពយ៉ាងធំធេងដែលជំរើស និងកាលានុវត្តភាពនេះមិនអាចកើតមានឡើយប្រសិនបើពុំមានវិមជ្ឈការ។ យើងទាំងអស់គ្នាត្រូវតែប្រើប្រាស់អត្ថប្រយោជន៍ប្រកបដោយសក្តានុពលទាំងនេះអោយបានខ្លាំងក្លាបំផុត។ ការទទួលខុសត្រូវនេះមិនមែនជារបស់រាជរដ្ឋាភិបាល និងស្ថាប័នរបស់រាជរដ្ឋាភិបាលតែម្នាក់ឯងទេ។ វាក៏ជាការទទួលខុសត្រូវរបស់អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងនៅមូលដ្ឋានព្រមទាំងទីភ្នាក់ងារផ្សេងទៀត ជាពិសេសរបស់បងប្អូនស្ត្រីខ្លួនឯងគ្រប់គ្នាផងដែរ។ ក្នុងន័យនេះត្រូវមានជាចាំបាច់នូវអង្គការរបស់ស្ត្រីនៅថ្នាក់មូលដ្ឋាន។ យើងទាំងអស់គ្នាត្រូវរួមចំណែកគាំទ្រ និងលើកទឹកចិត្តឱ្យស្ត្រីប្រើប្រាស់ក្រុមប្រឹក្សាឃុំ-សង្កាត់របស់ខ្លួន ដើម្បីបញ្ចេញមតិរបស់ខ្លួនទទួលបានការឆ្លើយតបកាន់តែសមស្រប និងរួមចំណែកពិនិត្យតាមដានលទ្ធផលកាន់តែជាក់ស្តែងថែមទៀត។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរជូនវេទិកាថ្ងៃនេះសូមទទួលបានជោគជ័យ ដើម្បីជំរុញការប្តេជ្ញាចិត្តរបស់យើងទាំងអស់គ្នាក្នុងការកែលំអគុណភាពនៃជីវភាពរស់នៅរបស់ស្ត្រីនៅកម្ពុជា។

សូមអរគុណ!




សុន្ទរកថា លោកស្រី ប៉ុក ណណ្ដា នាយកប្រតិបត្តិ អង្គការចំរើនស្ត្រី

ហេតុអ្វីបានជាការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយមានសារៈសំខាន់? ជាពិសេសនៅថ្នាក់ក្រុមប្រឹក្សាឃុំ-សង្កាត់?

សូមគោរពគណៈអធិបតី !

សូមគោរព សមាជិក សមាជិកានៃអង្គពិធីជាទីគោរព!

ជាកិត្តិយសមួយដ៏ធំធេងសម្រាប់រូបនាងខ្ញុំដែលបានទទួលការអញ្ជើញឱ្យចូលរួមចែករំលែកនូវបទពិសោធន៍ខ្លះៗ នៅក្នុង"**វេទិកាពិគ្រោះយោបល់លើកទីមួយ ស្ដីពីការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងប្រសិទ្ធិភាពនៅថ្នាក់ឃុំសង្កាត់ក្នុងប្រទេសកម្ពុជា**" ដ៏មានសារៈសំខាន់នាឱកាសនេះ។

មានទស្សនៈមួយចំនួនចាត់ទុកនយោបាយថាជាល្បែងរបស់បុរស ហើយគ្រោះថ្នាក់បំផុតដែលបម្រើឱ្យក្រុមអ្នកមានអំណាច ដើម្បីគ្រប់គ្រងត្រួតពិនិត្យប្រព្រឹត្តអំពើពុករលួយ ស៊ីសំណូកកេងប្រវ័ញ្ច រំលោភ និងគាបសង្កត់លើអ្នកទន់ខ្សោយ ហើយនិងអ្នកដែលពុំមានអំណាចទាំងអស់នេះ ដូចជាពុំបានបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋសាមញ្ញទេ តែធ្វើឱ្យមានគម្លាតកាន់តែឆ្ងាយទៅៗ រវាងអ្នកជាប់ឆ្នោត និងអ្នកដែលទៅបោះឆ្នោត។ ការយល់ឃើញនេះ បានបណ្ដុះជាប់ទៅក្នុងផ្នត់គំនិតរបស់បុគ្គលក៏ដូចជាសង្គមដែលក្លាយជាវប្បធម៌មួយរារាំងផ្លូវចិត្តរបស់ស្ត្រីឱ្យមានការរារែកចូលរួមក្នុងវិស័យនយោបាយ។

តាមការយល់ឃើញរបស់ខ្ញុំ នយោបាយ គឺសំដៅទៅលើរបៀបប្រើអំណាចរបស់មនុស្ស។ អំណាចអាចត្រូវប្រើប្រាស់លើមនុស្ស ដើម្បីមនុស្ស ឬ ជាមួយមនុស្ស។ មានមនុស្សមួយចំនួនពុំត្រូវបានចូលរួមក្នុងការធ្វើសេចក្ដីសម្រេចអំពីជីវិតផ្ទាល់ខ្លួនរបស់គេទេ នេះដោយសារតែគេពុំមានអំណាច។ ស្ត្រីចាំបាច់ត្រូវស្គាល់ថានរណាជាអ្នកមានអំណាច? តើអំណាចត្រូវប្រើប្រាស់ដោយរបៀបណា? ហើយតើយើងអាចប្រមូលផ្ដុំអំណាចដោយរបៀបណា ដើម្បីឱ្យមានការប្រែប្រួល? ដូច្នេះនយោបាយ គឺជាយានក្នុងការស្វែងរកនូវអំណាច ដើម្បីធ្វើសេចក្ដីសម្រេច។

បើយើងសួរថា ហេតុអ្វីបានជាស្ត្រីចាំបាច់ត្រូវតែចូលរួមក្នុងវិស័យនយោបាយ? ស្ត្រីត្រូវយល់ថា រាល់ការសម្រេចរបស់អ្នកនយោបាយប៉ះពាល់មកលើជីវិត និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋគ្រប់រូបមិនថាតែបុរស ឬ ស្ត្រីទេ **ឧទាហរណ៍** ដូចជាការទទួលបាននូវសេវាសុខភាព អប់រំទឹកស្អាត ការការពារខាងផ្លូវច្បាប់នៅពេលមានការរំលោភបំពាន និងកេងប្រវ័ញ្ចលើស្ត្រី ។ល។ ដូច្នេះ ដើម្បីរួមចំណែកកែប្រែស្ថានភាពរបស់ស្ត្រីបានទាល់តែស្ត្រីខ្លួនឯងយល់ច្បាស់ថានរណាជាអ្នកមានអំណាច ដើម្បីរៀបចំគោលនយោបាយឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងការបារម្ភរបស់ស្ត្រីបាន? យើងទាំងអស់គ្នាដឹងហើយថា មានតែស្ត្រីខ្លួនឯងទេដែលអាចយល់ និងស្គាល់នូវសេចក្តីត្រូវការពិតប្រាកដរបស់ខ្លួនប្រសើរជាងបុរស ដូច្នេះ ដើម្បីធានាឱ្យគោលនយោបាយរបស់ជាតិឆ្លើយតបទៅនឹងសេចក្តីត្រូវការពិតប្រាកដរបស់ស្ត្រីនោះ ស្ត្រីខ្លួនឯងត្រូវហ៊ានធ្វើសេចក្តីសម្រេចចិត្តចូលរួមប្រឡូកក្នុងឆាកនយោបាយ ជ្រើសរើសគណបក្សដែលខ្លួនពេញចិត្តហ៊ានឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យ និងទៅបោះឆ្នោតគាំទ្របុគ្គលណា ឬ គណបក្សណាដែលមានគោលនយោបាយលើកស្ទួយ និងការពារផលប្រយោជន៍របស់ស្ត្រី និងកុមារ ។

នៅក្នុងជីវភាពប្រចាំថ្ងៃ ស្ត្រីតែងតែធ្វើសេចក្តីសម្រេចសំខាន់ៗជាច្រើនក្នុងគ្រួសារ និងផ្ទះសំបែងរបស់គេ ប៉ុន្តែជាអកុសលស្ត្រីដែលមានតួនាទីក្នុងនយោបាយមានចំនួនតិចតួចមិនសមាមាត្រទៅនឹងចំនួនប្រជាពលរដ្ឋជាស្ត្រីក្នុងប្រទេស ។ ដូចនេះ នៅពេលធ្វើសេចក្តីសម្រេចក្នុងវិស័យនយោបាយ ស្ត្រីមានចំនួនសម្លេងតិចតួចណាស់ក្នុងការចូលរួមរៀបចំ និងអនុម័តគោលនយោបាយរបស់ជាតិ ដែលជាមូលដ្ឋានគ្រឹះដ៏មានឥទ្ធិពលទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។

មានអំណះអំណាងជាមូលដ្ឋានមួយចំនួនដែលអាចជាទុនលើកទឹកចិត្តឱ្យស្ត្រីមានជំនឿថាខ្លួនអាចចូលរួមប្រឡូកក្នុងវិស័យនយោបាយដូចបុរស ដែលជាដំបូង គឺទាក់ទងទៅនឹងដំណើរការនៃលទ្ធិប្រជាធិបតេយ្យ សមភាព និងសមធម៌ក្នុងសង្គម ។

ស្ត្រីមានចំនួនយ៉ាងតិចបំផុតពាក់កណ្តាលនៃចំនួនប្រជាពលរដ្ឋទាំងមូល នេះគឺជាការត្រឹមត្រូវដែលស្ត្រីត្រូវតែមានតំណាងរបស់ខ្លួននៅគ្រប់វិស័យឱ្យសមាមាត្រទៅនឹងចំនួនដែលគេមាន ។ លទ្ធិប្រជាធិបតេយ្យពិតប្រាកដមិនអាចកើតមានបានទេនៅកន្លែងណាដែលស្ត្រីមានចំនួនពាក់កណ្តាលនៃចំនួនប្រជាពលរដ្ឋទាំងមូល តែស្ត្រីទាំងនោះពុំមានតំណាងរបស់ខ្លួនគ្រប់គ្រាន់ចូលកាន់តួនាទីជាអ្នកដឹកនាំ និងធ្វើសេចក្តីសម្រេច ។

ទាក់ទងទៅនឹងបញ្ហានៃការប្រព្រឹត្តឱ្យបានត្រឹមត្រូវតាមច្បាប់កង្វះតំណាងស្ត្រីនៅក្នុងនយោបាយ គឺជាការគំរាមដល់ប្រព័ន្ធប្រជាធិបតេយ្យដែលធ្វើឱ្យមានគម្លាតឆ្ងាយពីគ្នារវាងអ្នកជាប់ឆ្នោតដែលភាគច្រើនជាបុរសទៅនឹងអ្នកដែលចូលរួមទៅបោះឆ្នោតដែលភាគច្រើនជាស្ត្រី ។ គុណភាពនៃច្បាប់ដែលកើតចេញពីការសម្រេចរបស់អ្នកនយោបាយ ដែលជាបុរសជួនកាលអាចពុំដូចគ្នា ឬ ពុំមានប្រសិទ្ធភាព ដូចជា

ការសម្រេចរបស់អ្នកនយោបាយដែលជាស្ត្រីទេ។

ការពិតជាក់ស្តែងបុរស និងស្ត្រីមានសេចក្តីត្រូវការដោយឡែកពីគ្នា ដូច្នេះការចូលរួមក្នុងនយោបាយ គឺជាការបញ្ចេញនូវមតិទស្សនៈក្នុងការការពារនូវផលប្រយោជន៍រៀងៗខ្លួន។ ការចូលរួមរបស់ស្ត្រីនៅក្នុងសង្គមក៏ដូចជាក្នុងនយោបាយមានតម្លៃខុសប្លែកគ្នាពីបុរស ព្រោះមានតែស្ត្រីទេដែលយល់ស្គាល់ និងបារម្ភចំពោះសេចក្តីត្រូវការ ព្រមទាំងអាចការពារនូវសេចក្តីត្រូវការ និងការបារម្ភរបស់ខ្លួនបានល្អប្រសើរជាងបុរស។ វាជាការពិត **ឧទាហរណ៍** ដូចជាបញ្ហាទាក់ទងទៅនឹងការគ្រប់គ្រងលើសរីរាង្គកាយរបស់ស្ត្រីសេចក្តីត្រូវការរួមទាំងការគាំទ្រ ក្នុងការថែរក្សាកុមារ ឬ អំពើហិង្សាលើនារីភេទ។ ប្រសិនបើ ស្ត្រីពុំមានវត្តមានក្នុងសង្គមនយោបាយទេនោះ ស្ត្រីពុំអាចនឹងមានលទ្ធិភាពក្នុងការបញ្ចេញមតិ ដើម្បីការពារនូវផលយោជន៍របស់ខ្លួនក្នុងការរៀបចំគោលនយោបាយ និងច្បាប់សម្រាប់ប្រទេសជាតិទេ។

ដើម្បីធ្វើការផ្លាស់ប្តូរនូវទស្សនៈនយោបាយ ឬរបៀបធ្វើនយោបាយមានការកត់សំគាល់ខ្លះបង្ហាញថា ប្រសិនបើស្ត្រីមានចំនួនច្រើនគ្រប់គ្រាន់ក្នុងតួនាទីជាអ្នកធ្វើសេចក្តីសម្រេច ស្ត្រីអាចផ្លាស់ប្តូរនូវជំរៅ ឬ អត្ថន័យ និងរបៀបរបបជាប្រពៃណីនៃការធ្វើនយោបាយបាន។ គឺដោយសារតែការចូលរួមយ៉ាងសកម្មរបស់ស្ត្រី ទៅលើបញ្ហាមួយចំនួនដូចបានជម្រាបខាងលើការថែរក្សាកុមារ ការរួមភេទ ការរៀបចំផែនការគ្រួសារ និងអំពើហិង្សាក្នុងគ្រួសារ ដែលពីដើមគេតែងតែចាត់ទុកថា ជាបញ្ហាផ្ទាល់ខ្លួន បច្ចុប្បន្ននេះបានក្លាយទៅជាបញ្ហានយោបាយដែលត្រូវបានទទួលការចាប់អារម្មណ៍ និងយកចិត្តទុកដាក់ជាសាធារណៈ។

ដូច្នេះ ការចូលរួមរបស់ស្ត្រីអោយបានច្រើនក្នុងការធ្វើសេចក្តីសំរេច ឬ នយោបាយមិនមែនគ្រាន់តែដើម្បីបន្តការងារ ឬ ការពារផលប្រយោជន៍សំរាប់ស្ត្រីប៉ុណ្ណោះទេ ក៏ប៉ុន្តែ ដើម្បីផលប្រយោជន៍សំរាប់របបលទ្ធិប្រជាធិបតេយ្យការផ្លាស់ប្តូរនយោបាយ ហើយនិងការបង្កើតអោយមានយុត្តិធម៌ក្នុងសង្គមសំរាប់ប្រជាពលរដ្ឋគ្រប់រូប។ ស្ត្រីមានសក្តានុពលក្នុងការចូលរួមចំណែកក្នុងនយោបាយ និងក្នុងការធ្វើសេចក្តីសំរេចដោយឡែកពីបុរស។ ខ្ញុំចង់ពិភាក្សាលើប្រភពខុសគ្នា ៤ សំខាន់ៗ ដែលស្ត្រីមានក្នុងការធ្វើសេចក្តីសំរេច។ ប្រភពទាំង ៤ នោះកើតចេញមកពីបទពិសោធន៍នៃតួនាទីតាមប្រពៃណីនៅក្នុងគ្រួសារ។ បទពិសោធន៍ពីតួនាទីតាមប្រពៃណីនៅក្នុងគ្រួសារនេះហើយ ដែលជាមរតកអាចអោយយើងបំលែង និងទាញយកជាមាគ៌ាថ្មីៗសំរាប់អនាគត។

- **ប្រភពទី១:** ដែលស្ត្រីមានខុសប្លែកពីបុរស គឺបទពិសោធន៍ក្នុងការថែរក្សាកូន។ បើបុគ្គលណាមួយបានថែរក្សាកូនបុគ្គលនោះតែងប្រមើមើលទៅដល់អនាគត។ ស្ត្រីចូលចិត្តគិតវែងឆ្ងាយយកចិត្តទុកដាក់តាមដានស្ថានការណ៍ប្រែប្រួលក្នុងប្រទេស ដូចជាកំណើននៃធនធានមនុស្សបច្ចេកវិទ្យាថ្មី និងសំភារៈទំនើបៗ។ អ្នកដែលមានបទពិសោធន៍ខាងលើនេះ អាចជួយ

តំរង់ទិសដៅរបស់កុមារអោយមានជោគវាសនាក្នុងការទទួលបាននូវអនាគតដ៏ល្អរុងរឿង។

• **ប្រភពទី២:** គឺស្ត្រីមានបទពិសោធន៍ក្នុងការគ្រប់គ្រងផ្ទះសម្បែង។ ស្ត្រីដែលជាអ្នកថែរក្សាគ្រប់គ្រងផ្ទះសម្បែងតាមប្រពៃណី ជាពិសេសនៅតំបន់ដែលគាត់រស់នៅដែលពោរពេញទៅដោយធម្មជាតិ គាត់ប្រាកដជាយកចិត្តទុកដាក់ក្នុងការថែរក្សាសម្បត្តិធម្មជាតិទាំងនោះ ដូចជាគាត់ថែរក្សាផ្ទះសម្បែងរបស់គាត់ដែរ។ គាត់អាចធ្វើអោយមាននិរន្តរភាពនៃទំនាក់ទំនងរវាងមនុស្ស និងធម្មជាតិ ។

• **ប្រភពទី៣:** គឺសមភាពនៃសុចរិតធម៌ក្នុងអារម្មណ៍។ ស្ត្រីខុសប្លែកពីបុរសដោយបានទទួលពីធម្មជាតិអោយចេះគិតថា អារម្មណ៍ហើយនិងមនោសញ្ចេតនាមានសារៈសំខាន់។ ស្ត្រីត្រូវបានអនុញ្ញាតអោយគិតថា ការសម្រក់ទឹកភ្នែកជារឿងធម្មតា។ យើងពុំដែលគិតថាការសម្រក់ទឹកភ្នែកជាការអៀនខ្មាស់ ឬ ធ្វើអោយយើងអាប់ឱនកិត្តិយសនោះទេ។ ទាំងនោះបង្ហាញថា ស្ត្រីមិនត្រឹមតែអោយតំលៃលើសំភារៈប៉ុណ្ណោះទេ តែស្ត្រីអោយតំលៃដល់ស្មារតីថែមទៀត។ នេះគឺជាការអភិវឌ្ឍន៍ធនធានមនុស្សដែលជាតំរូវការរបស់សង្គមក៏ដូចជាពិភពលោកទាំងមូល។

• **ប្រភពទី៤:** គឺបទពិសោធន៍របស់ស្ត្រីនៅក្រៅដែនអំណាច។ ភាពជាអ្នកនៅក្រៅដែនអំណាច បទពិសោធន៍ និងការយល់ឃើញរបស់ស្ត្រីទៅលើអំណាចមានការខុសប្លែកពីបុរស។ ស្ត្រីជួបប្រទះនូវទំនាស់ច្រើនបែបយ៉ាងក្នុងនាមដែលគេយល់ឃើញថា ជាភាគីទន់ខ្សោយស្ត្រីបានរកដំណោះស្រាយដោយអហិង្សា។ ដូច្នេះហើយ ស្ត្រីដោះស្រាយទំនាស់តាមរយៈការរកឃើញនូវដំណោះស្រាយឈ្នះជាជាងដំណោះស្រាយដោយហិង្សា។ គុណសម្បត្តិនេះហើយដែលស្ត្រីមានភាពខុសប្លែកពីបុរសក្នុងការរកដំណោះស្រាយបញ្ហាសង្គម និងសន្តិភាព។

ក្នុងការលើកឡើងអំពីភាពខុសគ្នាពីបុរសដែលស្ត្រីអាចធ្វើបានក្នុងនយោបាយ និងក្នុងការធ្វើសេចក្តីសំរេច ខ្ញុំចង់បញ្ជាក់អោយច្បាស់ថា ខ្ញុំមិនមែនជំរុញអោយស្ត្រីបន្តការងារតាមប្រពៃណីនោះទេ។ ក៏ប៉ុន្តែខ្ញុំចង់និយាយថា ឆ្លងតាមបទពិសោធន៍ជាប្រពៃណីដែលស្ត្រីមានជាអាទិភាពជាម្តាយអ្នកថែរក្សា និងអ្នកគ្រប់គ្រងផ្ទះសម្បែងយើងអាចមានលទ្ធិភាពក្នុងការតំរង់ទិសដៅទស្សនៈវិស័យ និងបទពិសោធន៍នេះទៅកសាងអនាគតរបស់សហគមន៍ និងប្រទេសជាតិយើង។ គុណសម្បត្តិ និងទស្សនៈវិស័យដោយឡែកនេះ ចាំបាច់ត្រូវបង្ហាញឡើងពីបុគ្គលចំពោះជីវភាពនយោបាយ។ ស្ត្រីចាំបាច់ត្រូវយកមកបញ្ចូលក្នុងដែនអំណាច ដើម្បីអោយស្ត្រីបានចូលរួមពេញលេញនៅក្នុងរាល់គំរោងផែនការ។ ចំណុចសំខាន់ គឺយើងមិនចង់បន្តតួនាទីជាប្រពៃណីរបស់ស្ត្រីទេ ប៉ុន្តែយើងបំលែងការបែងចែកតួនាទីភេទតាមប្រពៃណី។ ដូច្នេះបុរសក៏អាចទាមទារទទួលចំណែក និងអោយតំលៃលើគុណសម្បត្តិ និងបទពិសោធន៍ ដោយឡែកទាំងនេះទុកជារបស់ខ្លួនផ្ទាល់ ហើយចំណុចជាងនេះទៅទៀតគឺភេទទាំងពីរមានសារៈសំខាន់

ដូចគ្នាក្នុងពិភពលោក។ ដល់ពេលនោះ ស្ត្រីដែលជាអ្នកធ្វើសេចក្តីសំរេចប្រាកដជាមិនជួបប្រទះទៅនឹងការលំបាកស្រពិចស្រពិលក្នុងការជ្រើសរើសរវាងគ្រួសារ ហើយនិងការងាររវាងជីវភាពឯកជន ហើយនិងជីវភាពសាធារណៈ។ ការនេះត្រូវតែកើតឡើងដែលពេលនោះបញ្ហាផ្ទាល់ខ្លួន និងបញ្ហានយោបាយអាចប្រែប្រួល ហើយមនុស្សម្នាក់ៗនឹងមានសេរីភាពពិតប្រាកដពិភពលោកនឹង មានយុត្តិធម៌សំរាប់មនុស្សគ្រប់រូប។ ទាំងនេះគឺ ជាទិសដៅដែលស្ត្រី គួរស្វែងរកពេលដែលស្ត្រីពង្រីកនូវតួនាទីក្នុងនយោបាយ និងក្នុងការធ្វើសេចក្តីសំរេច។

ប្រទេសនីមួយៗ ចាំបាច់ត្រូវតែប្រើប្រាស់នូវធនធានមនុស្សទាំងអស់ដែលខ្លួនមាន ដើម្បីអភិវឌ្ឍន៍ប្រទេសឱ្យបានរីកចំរើន ស្ត្រីដែលមានចំនួនពាក់កណ្តាលនៃមនុស្សក្នុងប្រទេសក៏ជាតំណាងមួយក្រុមធំនៃទេពកោសល្យ និងជំនាញដែរ។ ការដាក់ស្ត្រីឱ្យនៅក្រៅតួនាទីជាអ្នកមានអំណាច និងពីក្រុមនយោបាយធ្វើឱ្យជីវិតនយោបាយទន់ខ្សោយ និងធ្វើឱ្យស្ទះដំណើរក្នុងការអភិវឌ្ឍន៍សង្គម។ បើគ្មានការចូលរួមពេញលេញពីស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចទេនោះ ដំណើរការនយោបាយមានភាពទន់ខ្សោយមិនបានឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋមួយចំនួនធំដែលជាស្ត្រី និងជាក្រុមដែលងាយរងគ្រោះជាហេតុធ្វើឱ្យខូចប្រយោជន៍ដល់សង្គមជាតិទាំងមូល។

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ទិសដៅកំណែទំរង់វិមជ្ឈការចំនួនបីគឺពង្រឹងលទ្ធិប្រជាធិបតេយ្យពហុបក្សនៅមូលដ្ឋានលើកកំពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម និងកាត់បន្ថយភាពក្រីក្រ។ ប្រជាពលរដ្ឋមានក្តីសង្ឃឹមច្រើនទៅលើប្រព័ន្ធវិមជ្ឈការដោយយល់ថា ប្រព័ន្ធនេះនឹងនាំមកនូវការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋនៅមូលដ្ឋាននៅក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន ហើយនឹងបង្កើនបាននូវភាពជាក់លាក់ និងប្រសិទ្ធភាពនៃសេវាសាធារណៈ។ រដ្ឋបាលមូលដ្ឋានបាននៅជិតប្រជាពលរដ្ឋ ហើយបញ្ហាទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានដឹងឮ និងទទួលបាននូវការដោះស្រាយដោយឆាប់រហ័សជាងរង់ចាំការសម្រេចពីថ្នាក់លើ។ ថ្នាក់ដឹកនាំមូលដ្ឋានអាចពិនិត្យយល់ដឹងស្គាល់ពីស្ថានភាពជាក់ស្តែងនូវសេចក្តីត្រូវការរបស់សហគមន៍ ហើយលើកឡើងនូវដំណោះស្រាយសមស្របដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ក្រុមនោះ។ មានសមាសភាពស្ត្រីច្រើនចូលរួមជាអ្នកធ្វើសេចក្តីសម្រេចក្នុងប្រព័ន្ធវិមជ្ឈការនោះសេចក្តីត្រូវការជាចាំបាច់របស់ប្រជាពលរដ្ឋនៅមូលដ្ឋាននឹងទទួលបាននូវការយកចិត្តទុកដាក់ ការចូលរួមក្នុងដំណើរការនយោបាយនៅមូលដ្ឋានដោយមានសមាសភាពស្ត្រីច្រើនបង្ហាញនូវការរីកលូតលាស់នៃលទ្ធិប្រជាធិបតេយ្យ ហើយក៏ជាឱកាសសម្រាប់ស្ត្រីចាប់ផ្តើមអភិវឌ្ឍន៍សហគមន៍ដែលនេះអាចលើកទឹកចិត្តស្ត្រីឱ្យចាប់យកអាជីពជាអ្នកនយោបាយជំហានដំបូងព្រោះបទពិសោធន៍ដែលខ្លួនមានពីមូលដ្ឋាន គឺជាគ្រឹះដ៏រឹងមាំក្នុងការ

ចាប់យកតួនាទីបន្តជាអ្នកនយោបាយនៅថ្នាក់ជាតិ និងអន្តរជាតិ។ គេនិយាយថា នយោបាយអភិវឌ្ឍន៍ល្អចាប់ផ្ដើមពីមូលដ្ឋានទៅ ពីព្រោះមូលដ្ឋាននេះ ហើយដែលជាសេចក្ដីត្រូវការពិតប្រាកដរបស់ប្រជារាស្ត្រ ហើយដែលអ្នកដឹកនាំនយោបាយ ឬ អ្នកធ្វើសេចក្ដីសម្រេចគ្រប់រូបត្រូវតែផ្ដោតអារម្មណ៍ជាអាទិភាព។

ការបង្កើតឱ្យមានគណៈកម្មាធិការស្ត្រី និងកុមារ នៅគ្រប់ឃុំ-សង្កាត់ឆ្លុះបញ្ចាំងនូវការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលដោយលើកទឹកចិត្តឱ្យស្ត្រីបានចូលរួមដោយពេញលេញ ដោយស្មើភាព និងដោយសកម្មក្នុងការងារ នយោបាយក៏ដូចជាការងារសាធារណៈដែលនឹងនាំមកនូវការផ្លាស់ប្ដូរទំលាប់ នៃការអនុវត្តន៍នយោបាយដើម្បីដោះស្រាយបញ្ហា និងសេចក្ដីត្រូវការ របស់ស្ត្រី និងកុមារ។ ការបង្កើនអោយមាននូវតម្លាភាព និងការទទួលខុសត្រូវរួមបញ្ចូលទាំងការឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងសេចក្ដីត្រូវការ និងការទាមទាររបស់ប្រជាពលរដ្ឋមានសារៈសំខាន់ណាស់ក្នុងការពង្រឹងអភិបាលកិច្ចដែលទាំងនេះ គឺជាលក្ខខ័ណ្ឌចាំបាច់សម្រាប់ពន្លឿនសមភាព សមធម៌យេនឌ័រ។



អេង នេត្រា អ្នកស្រាវជ្រាវកម្មវិធីអភិបាលកិច្ច និងវិមជ្ឈការ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ កម្ពុជា (CDRI)

ប្រធានបទផ្តោតសំខាន់សំរាប់ការប្រជុំយើងថ្ងៃនេះ គឺអំពីយេនឌ័រ និងវិមជ្ឈការហើយឯកសារសង្ខេបនេះនឹងឆ្លើយទៅសំនួរ ៣ ខាងក្រោម :

១.តើទស្សនៈយេនឌ័រ និងវិមជ្ឈការមានន័យដូចម្តេច?

២.តើទស្សនៈយេនឌ័រ និងវិមជ្ឈការមានន័យមានទំនាក់ទំនងគ្នាដូចម្តេច?

៣.តើមានបទពិសោធន៍ និងបញ្ហាប្រឈមអ្វីខ្លះកន្លងមកពីយេនឌ័រ និងវិមជ្ឈការក្នុងប្រទេសកម្ពុជា?

**១-យេនឌ័រ និងវិមជ្ឈការ:** ការពន្យល់ពីទស្សនៈទាំងពីរ

**ក.យេនឌ័រ:** យើងនឹងពិភាក្សាពីយេនឌ័រ និងតួនាទីយេនឌ័រតែមិនមែនស្ត្រី និងតួនាទីស្ត្រីទេ ពីព្រោះពាក្យនិមួយៗបង្ហាញពីទស្សនៈផ្សេងគ្នា។ នៅពេលយើងនិយាយពីបុរស និងស្ត្រី គឺយើងសំដៅលើភេទ និងតួនាទីភេទ ហើយនឹងតួនាទីភេទ (តួនាទីជាភេទបុរស និងស្ត្រីមានជាទូទៅជាធម្មជាតិ និងដូចគ្នាក្នុងពិភពលោកនឹងមិនអាចផ្លាស់ប្តូរបាន)។

ចំណែកយេនឌ័រ គឺសំដៅលើអត្តចរិកដែលទទួលបាន និងការរំពឹងទុកដែលទាក់ទងបុរស និងស្ត្រី។ ហេតុដូចនេះហើយ តួនាទីយេនឌ័រមិនមែនផ្តល់ដោយធម្មជាតិទេ ជាទូទៅតួនាទីទាំងនេះអាចអនុវត្តន៏បានដូចគ្នាទាំង បុរស និងស្ត្រី( **ឧទាហរណ៍** ការបង្កើតកូនជាតួនាទីស្ត្រីតែការមើលកូន និងការទុកដាក់ផ្ទះសំបែងអាចធ្វើដោយបុរស ឬ ស្ត្រី)។ សរុបមកតួនាទីយេនឌ័រគឺជាលទ្ធផលនៃវប្បធម៌ ជំនឿ និងតំលៃរបស់សង្គមនិមួយៗ។ តួនាទីទាំងអស់នេះ ត្រូវបានពង្រឹង និងអនុវត្តន៏ក្រោមសំពាធនៃរចនាសម្ព័ន្ធសង្គម និងស្ថាប័នផ្សេងៗ ដូចជា គ្រួសារសាលារៀន សហគមន៏ រដ្ឋាភិបាល សារពត៌មាន និងអង្គការសង្គមជាច្រើនទៀត។

ជា**ឧទាហរណ៏:** ស្ត្រីត្រូវបានគេបង្រៀនអោយ

យកចិត្តទុកដាក់លើការងារផ្ទះ ហើយបុរសត្រូវបានគេបង្រៀនអោយធ្វើការលើឧបករណ៍ការងារខាងក្រៅ។

**ខ.វិមជ្ឈការ:** ទំនាក់ទំនងគ្នារវាងរដ្ឋ និងអាជ្ញាធរមូលដ្ឋានអាចបង្កើតឡើងតាមមធ្យោបាយផ្សេងៗគ្នាជាច្រើន។រដ្ឋទាំងឡាយណាដែលទំនើបទំនាក់ទំនងរដ្ឋ និងអាជ្ញាធរមូលដ្ឋាន គឺជាធម្មតាទំនាក់ទំនងមួយដែលអំណាច និងមុខងារជាក់លាក់មួយចំនួនត្រូវបានធ្វើវិមជ្ឈការ។ ជាទូទៅពាក្យថា វិមជ្ឈការ ក្តោបន័យ ២យ៉ាង: វិមជ្ឈការផ្នែកនយោបាយ និងវិមជ្ឈការផ្នែករដ្ឋបាល។ វិមជ្ឈការក៏ក្តោបមានន័យផ្សេងៗទៀតដែរ ដែលមានទំនាក់ទំនងជាមួយនឹងវិមជ្ឈការផ្នែកនយោបាយ និងផ្នែករដ្ឋបាល។

- **វិមជ្ឈការផ្នែករដ្ឋបាល:** សំដៅទៅលើការធ្វើប្រតិភូកម្មភារកិច្ច និងការផ្ទេរនូវសិទ្ធិអំណាចពីកំរិតថ្នាក់ជាតិទៅកំរិតថ្នាក់បន្ទាប់នៃរាជរដ្ឋាភិបាល។ ថ្នាក់បន្ទាប់ទាំងនោះ អាចជាសាខានៃថ្នាក់ជាតិ។ នាយកដ្ឋានសាធារណ: ដែលបានបង្កើតឡើង គឺជាទូទៅស្របទៅនឹងកំរិតថ្នាក់បន្ទាប់ក្រោមឋានានុក្រម នាយកដ្ឋានការិយាល័យផ្សេងៗ ដូចជា: នាយកដ្ឋានអប់រំ នាយកដ្ឋានសុខភាពជាដើម។ កំរិតនៃការគ្រប់គ្រងថ្នាក់បន្ទាប់ពីថ្នាក់ជាតិជា ឧទាហរណ៍ដូចជា ខេត្តស្រុកដែលថ្នាក់ទាំងនេះមិនមែនជាស្ថាប័នដែលបានបោះឆ្នោតជ្រើសរើសដោយប្រជាជននោះទេ តែត្រូវបានចាត់តាំងដោយក្រសួងផ្ទាល់។ វិមជ្ឈការ ផ្នែករដ្ឋបាលគឺសំដៅទៅលើការគ្រប់គ្រងបែបវិសហមជ្ឈការ (Cohen and Peterson 1999 )
- **វិមជ្ឈការនយោបាយ:** អំណាច និងមុខងារត្រូវបានផ្ទេរពីរដ្ឋាភិបាលថ្នាក់កណ្តាលទៅអោយរដ្ឋាភិបាលមូលដ្ឋាន រដ្ឋាភិបាលមូលដ្ឋានមានតំណាងមកពីគណបក្សនយោបាយនីមួយៗនេះមានន័យថា ក្រុមប្រឹក្សាឃុំត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាជន ដើម្បីតំណាងអោយប្រជាជនដែលរស់នៅក្នុងឃុំ។ វិមជ្ឈការប្រភេទនេះ គឺជាទូទៅគេហៅថា វិមជ្ឈការផ្នែកនយោបាយ ឬ ការផ្ទេរអំណាច (Conyer 1983)

**២-យេនឌ័រ និងវិមជ្ឈការ និងទំនាក់ទំនងរវាងទស្សនៈទាំងពីរ :**

វិមជ្ឈការត្រូវបានគេជំរុញអោយបង្កើតឡើងដោយការជជែកវែកញែកគ្នា ២ សំខាន់ៗ:

**ក.វិមជ្ឈការអាចនាំអោយមានការកើនឡើងនៃប្រសិទ្ធិភាព** ដែលអាចកើតឡើងរដ្ឋាភិបាលតាមរយ:មូលដ្ឋាន ក្នុងការអនុវត្តន៍នូវគោលនយោបាយ និងកម្មវិធី និងសកម្មភាពទាំងឡាយណាដែលឆ្លើយតបនឹងតំរូវការ និងបញ្ហាយ៉ាងពិតប្រាកដរបស់ប្រជាជននៅក្នុងឃុំ ដើម្បីពង្រឹងនិងធ្វើការអោយកាន់តែប្រសើរឡើងនូវការបែងចែកធនធានមូលដ្ឋាន។

កត្តាទាំងអស់នេះមានសារៈសំខាន់ណាស់សំរាប់ស្ត្រីក្នុងការចូលរួម និងផ្តល់មតិតាមរយៈសកម្មភាពធ្វើផែនការឃុំ ដំណើរការនៃការអនុវត្តន៍គំរោងការតាមដានត្រួតពិនិត្យ និងការវាយតំលៃ។ ជាមួយនឹងចំនួនប្រជាជនកម្ពុជាដ៏ច្រើនជាស្ត្រី និងមានមេគ្រួសារជាស្ត្រី

វិមជ្ឈការគឺជាមធ្យោបាយមួយ ដើម្បីបង្កើននូវការចូលរួមរបស់ស្ត្រីក្នុងដំណើរការធ្វើសេចក្ដីសំរេចចិត្តទៅលើការផ្ដល់សេវាកម្មសាធារណៈក្នុងឃុំសំរាប់បំរើផលប្រយោជន៍ចំបងដល់ស្ត្រី។

**ខ.វិមជ្ឈការអាចនាំអោយមានការកែលំអការគ្រប់គ្រង** តាមរយៈការពង្រឹងគណនេយ្យភាព និងការត្រួតពិនិត្យលើមន្ត្រីបុគ្គលិក និងអ្នកធ្វើសេចក្ដីសំរេច។ វិមជ្ឈការអាចឈានបង្កើតនូវគណនេយ្យភាពក្នុងថ្នាក់មូលដ្ឋាននៅក្នុងកិច្ចការនយោបាយក្នុងឃុំ និងការបញ្ជ្រាបអោយកាន់តែស៊ីជំរៅនៃការអនុវត្តន៍លិទ្ធិប្រជាធិបតេយ្យ។

មតិយោបល់ទាំងនេះមានទំនាក់ទំនងសំខាន់ណាស់សំរាប់ស្ត្រីនៅក្នុងការឈានចាប់យកតួនាទីជាអ្នកនយោបាយ ជាអ្នកតំណាងអោយស្ត្រីដទៃទៀត និងជាអ្នកមានឥទ្ធិពលលើសេចក្ដីសំរេចនានា ដែលពាក់ព័ន្ធ និងមានផលប្រយោជន៍ច្រើនសំរាប់សហគមន៍ និងស្ត្រីដទៃ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយវិមជ្ឈការពុំអាចធានាថានឹងនាំមកនូវលទ្ធផលទាំងនេះជាស្វ័យប្រវត្តិនោះទេ។ វិមជ្ឈការ និងកត្តាជាច្រើនរួមគ្នាទើបអាចបង្កើនអោយមានការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយ ការបង្កើនភាពស្មើគ្នារវាងបុរស និងស្ត្រី និងការរំពឹងទុកការជាច្រើនទៀត ដូចជាការកាត់បន្ថយភាពក្រីក្រ។

**៣-៤យេនឌ័រ និងវិមជ្ឈការក្នុងប្រទេសកម្ពុជា: បទពិសោធន៍ និងបញ្ហាប្រឈម**

ប្រទេសកម្ពុជាបានចាប់ផ្ដើមប្រតិបត្តិបែបទំរង់វិមជ្ឈការ រួមបញ្ចូលទាំងការផ្ទេរអំណាចដើម្បីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ និងវិសហមជ្ឈការទាំងតួនាទី និងអំណាចពីថ្នាក់ដឹកនាំកំពូលទៅអភិបាលខេត្ត-ក្រុង។ បច្ចុប្បន្ននេះ ដំណើរការកំណែទំរង់វិមជ្ឈការក្នុងប្រទេសកម្ពុជាកើតឡើងក្រោមការផ្ដួចផ្ដើមនៃកម្មវិធីសីលាចាប់តាំងពីឆ្នាំ ១៩៩៦ ជាមួយគ្នានោះដែរ ដោយសារតែមានរបៀបវារៈដំបូងដែលបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ ១៩៩៩ ជាមួយជំហ៊ានដំបូងរបស់វាឆ្ពោះទៅមុខដើម្បីទទួលយកក្របខ័ណ្ឌច្បាប់ ដើម្បីអនុម័តប្រើប្រាស់ក្នុងការគ្រប់គ្រងបែបវិមជ្ឈការ។

ការបង្កើតជាផ្លូវការនូវវិមជ្ឈការបានចាប់ផ្ដើមជាមួយនឹងការទទួលប្រើប្រាស់នូវច្បាប់ ស្ដីពីការបោះឆ្នោតឃុំ-សង្កាត់ និងច្បាប់ស្ដីពីរដ្ឋបាល និងការគ្រប់គ្រងក្រុមប្រឹក្សាឃុំ-សង្កាត់។ ច្បាប់ទាំងនេះសំរេចលើប្រភេទអ្វីដែលរដ្ឋាភិបាលមូលដ្ឋាន និងរបៀបគ្រប់គ្រងដែលគួរអោយមាននៅប្រទេសកម្ពុជា។ ច្បាប់សំខាន់ៗ ទាំងនេះបានជំរុញអោយមានការអនុវត្តន៍លើការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ពីឆ្នាំ ២០០២ តាមរយៈប្រព័ន្ធសមាមាត្រដែលមានបញ្ជីឈ្មោះបេក្ខជនកំណត់តាមដោយគណៈបក្សនយោបាយ។ ការបោះឆ្នោតទាំងនេះ បានកំណត់នូវការបញ្ចប់ការពិភាក្សាយ៉ាងវែងជាច្រើនក្នុងរដ្ឋាភិបាលនៃរបៀបដែលរដ្ឋាភិបាលនឹង (i) បង្កើតនូវភាពជាម្ចាស់ក្នុងកិតមូលដ្ឋាន ហើយ (ii) ធានាអោយបានថាការអភិវឌ្ឍន៍បានកើនឡើងនៅឯមូលដ្ឋានដើម្បីកាត់បន្ថយភាពក្រីក្រ។

ក្នុងគោលបំណងដើម្បីបង្កើនតួនាទីនៃការអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ និងធានានូវឱកាសសំរាប់ការចូលរួម ដោយក្រុមដែលមិនបានផលប្រយោជន៍តិច (ជាទូទៅគេដឹងថា ជាស្ត្រីមេម៉ាយ និងជនពិការ) ថ្នាក់មូលដ្ឋានដែលគួរត្រូវបានគេជ្រើសរើសតាមរយៈសន្លឹកឆ្នោត គឺជាថ្នាក់ឃុំ-សង្កាត់។ ក្នុងឃុំនីមួយៗ មានប្រជាពលរដ្ឋជាមធ្យមរវាង ១៥.០០០ ទៅ ២០.០០០នាក់។ ឃុំមួយមានក្រុមប្រឹក្សាឃុំមួយក្រុមដែលមានសមាជិកពី ៥ ទៅ ១១នាក់ យោងទៅតាមចំនួនប្រជាពលរដ្ឋក្នុងឃុំ។

រចនាសម្ព័ន្ធរួមមួយនៅក្នុងក្រុមប្រឹក្សាឃុំកម្ពុជា មានមេឃុំ ជំទប់ទី១ ជំទប់ទី២ និងសមាជិកក្រុមប្រឹក្សាឃុំច្រើននាក់ទៀត។ ក្នុងការបោះឆ្នោតឃុំក្នុងខែ កុម្ភៈ ឆ្នាំ ២០០២ មានស្ត្រីជាក្រុមប្រឹក្សាឃុំ ៩៨៣នាក់ ក្នុងចំណោមក្រុមប្រឹក្សាឃុំចំនួន ១១២៦១នាក់ នៃឃុំ-សង្កាត់ទាំងអស់ចំនួន ១៦២១។ ក្នុង ចំណោមក្រុមប្រឹក្សាជាស្ត្រី ៩៨៣ នាក់ មាន ៣៤នាក់ ត្រូវបានគេបោះឆ្នោតជាប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់។ ក្រុមប្រឹក្សាឃុំម្នាក់ៗ ត្រូវបានបែងចែកការទទួលខុសត្រូវលើការងារផ្សេងៗគ្នា។ ចំនុចដែលសំខាន់ដែរនោះគឺថា ច្បាប់បានចែងអោយក្រុមប្រឹក្សាឃុំតែងតាំងក្រុមប្រឹក្សាឃុំជាស្ត្រី ឬ អ្នកភូមិជាស្ត្រីម្នាក់ ដើម្បីអោយទទួលខុសត្រូវទៅលើការងារស្ត្រី និងកុមារក្នុងឃុំ។ ម្យ៉ាងវិញទៀត ច្បាប់បានតំរូវអោយឃុំនីមួយៗ បង្កើតអោយមានគណៈកម្មាធិការ ២ គឺគណៈកម្មាធិការផែនការ និងថវិកា (PBC) និងគណៈកម្មាធិការលទ្ធកម្ម (PC)។

អស់រយៈពេលកន្លងមករដ្ឋាភិបាលកម្ពុជាបានសំរេចនូវស្នាដៃគួរអោយកត់សំគាល់ជាច្រើនសំរាប់កំនែទំរង់វិមជ្ឈការ ដែលក្រុមប្រឹក្សាឃុំបានធ្វើផែនការអភិវឌ្ឍន៍ឃុំរយៈពេល ៥ឆ្នាំ និងមានគំរោងថវិកាប្រចាំឆ្នាំ។ ផែនការ និងគំរោងថវិកាទាំងនេះ បានអនុញ្ញាតិអោយឃុំទាំងអស់បានអនុវត្តន៏នូវគំរោងហេដ្ឋារចនាសម្ព័ន្ធជាច្រើនតាមរយៈថវិកាឃុំ-សង្កាត់ (CSF)។ ចំណែកការទទួលខុសត្រូវជាចំបងកន្លងមក ដែលបានផ្តល់អោយក្រុមប្រឹក្សាឃុំ-សង្កាត់មាន ដូចជា អត្រានុកូលដ្ឋាន ការចុះបញ្ជីកំណើត ស្លាប់ អាពាហ៏ពិពាហ៏។

ទោះជាយ៉ាងណាក៏ដោយ ក៏ការលំបាក ចំបងៗជាច្រើនដែលនឹងត្រូវដោះស្រាយជាជំហ៊ានៗ។ បញ្ហាប្រឈមគួរអោយកត់សំគាល់ពីកំនែទំរង់វិមជ្ឈការ និងយេនឌ័រ ពិសេសចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រីអាចសង្ខេបដូចខាងក្រោម:

- ចាប់តាំងពីក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបានគេបង្កើតឡើងពីគណបក្សនយោបាយធំបីដូចដែលមានក្នុងពេលបច្ចុប្បន្ននេះទាំងអស់គ្នាកំពុងស្ថិតនៅក្នុងដំណើរការនៃការរៀនសូត្រពីរបៀបធ្វើការរួមគ្នា ទោះបីជាមានបញ្ហាមួយចំនួនក៏ដោយ។ ប្រសិនបើមានក្រុមប្រឹក្សាជាស្ត្រីម្នាក់មកពីគណបក្សនយោបាយមួយដែលមិនមានសំលេងភាគច្រើនក្នុងឃុំនោះគាត់នឹងមិនត្រូវបានគេយកចិត្តទុកដាក់ ហើយរមែងជួបការលំបាកចំពោះការបញ្ចេញយោបល់របស់គាត់។
- ក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រី ជាទូទៅទទួលបានការគាំទ្រ និងការយកចិត្តទុកដាក់

តិចតួចពីគណបក្សនយោបាយទាំងក្នុងដំណើរការបោះឆ្នោតឃុំ-សង្កាត់ និងក្នុងអំឡុងពេលជាក្រុមប្រឹក្សាឃុំ-សង្កាត់ បើប្រៀបធៀបទៅនឹងក្រុមប្រឹក្សា ឃុំ-សង្កាត់ដែលជាបុរស ។

- គណបក្សនយោបាយធំអាចឆ្លើយតបទៅនឹងតំរូវការខ្ពស់របស់ប្រជាជនខណៈពេលដែលគណបក្សផ្សេងមិនអាចឆ្លើយតបបាន ។ ហើយដោយសារកម្មវិធីឃុំ-សង្កាត់សំខាន់ៗមួយចំនួនត្រូវបានឧបត្ថម្ភ ដោយគណបក្សនយោបាយធ្វើអោយសមាជិកក្រុមប្រឹក្សាឃុំជាស្ត្រីកំពុងបាត់បង់នូវមុខមាត់ដោយសារមិនអាចឆ្លើយតបនឹងតំរូវការរបស់ស្ត្រី និងកុមារបានពីព្រោះតែតំរូវការផ្សេងៗ (គំរោងហេដ្ឋារចនាសម្ព័ន្ធ) ត្រូវបានគេផ្តល់អោយជាអាទិភាពខ្ពស់ជាងគេ ។
- ក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រីនៅតែមានចំនួនភាគតិចក្នុងឃុំ-សង្កាត់នីមួយៗ ប៉ុន្តែច្បាប់នៃការបោះឆ្នោតមិនបានតំរូវអោយមានចំនួនអប្បបរមានៃក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រីទេ ។ ឃុំខ្លះមិនមានសមាជិកក្រុមប្រឹក្សាឃុំជាស្ត្រីឡើយ ដូច្នោះហើយហាក់ដូចជាក្រុមប្រឹក្សាឃុំជាការងារបុរស ។ ការលំបាកក្នុងការលើកទឹកចិត្តស្ត្រីក្នុងការងារគ្រប់គ្រង និងការងារអភិបាលកិច្ចដោយសារបញ្ហាប្រឈមជាមួយនឹងតំលៃសង្គមប្រពៃណី សេដ្ឋកិច្ច គ្រួសារ ជាទូទៅរបស់ប្រទេសកម្ពុជា ។
- វាមានការលំបាកដើម្បីអោយស្ត្រីចូលរួមឈរឈ្មោះសំរាប់ការបោះឆ្នោត ពីព្រោះនៅក្នុងប្រពៃណីខ្មែរស្ត្រីមិនត្រូវបានលើកទឹកចិត្តអោយចូលរួមក្នុងការងារនយោបាយពីសំណាក់ប្តី និងគ្រួសាររបស់នាងឡើយ ។ ហើយបញ្ហានេះវានៅតែជាបញ្ហាដ៏ធំមួយសំរាប់ប្រពៃណីនៃសង្គមខ្មែរទោះបីពេលបច្ចុប្បន្ននេះក៏ដោយ ។ លើសពីនេះទៅទៀតស្ត្រីខ្មែរ គឺជាអ្នកទទួលខុសត្រូវច្រើនចំពោះការងារសេដ្ឋកិច្ចគ្រួសារ ហើយស្ត្រីត្រូវថែរក្សាកូនចៅ និងគ្រួសារ ។ ដូច្នេះហើយកាតព្វកិច្ចសេដ្ឋកិច្ចសង្គមធ្វើអោយស្ត្រីកាន់តែទទួលរងគ្រោះកាន់តែច្រើន និងខ្វះនូវឱកាសចូលប្រលូកក្នុងសកម្មភាពនយោបាយក្នុងសង្គម ។
- ហេតុនេះក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រីកំពុងតែមានការទទួលខុសត្រូវយ៉ាងធ្ងន់ធ្ងរ និងបន្ទុកការងារជាច្រើនទាំងនៅផ្ទះនិងកន្លែងធ្វើការ ។
- ទោះបីជាមានគំលាតក្នុងកំរិតនៃការអប់រំរវាងបុរស និងស្ត្រីនៅតាមជនបទនៃប្រទេសកម្ពុជាក៏ដោយ ក៏ក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រីជាទូទៅកំរិតអប់រំរបស់គាត់មិនទាបជាងដៃគូរការងារជាបុរសឡើយ ។ លើសពីនេះទៅទៀតពួកគាត់តែងតែមានបទពិសោធន៍ពីអង្គការ NGOs ជាច្រើនទៀតផង ។
- តួនាទីនៃក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រីក្នុងការងារឃុំមានកំណត់ ដោយសារច្បាប់តំរូវអោយស្ត្រីទទួលខុសត្រូវសំរាប់តែកិច្ចការស្ត្រី និងកុមារក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់និមួយៗ ។ ច្បាប់នេះរារាំងនូវការចូលរួម និងឥទ្ធិពលរបស់ពួកគាត់ទៅលើតួនាទីផ្សេងៗរបស់ឃុំ ។
- ការពិតបញ្ហានេះកាន់តែធ្វើអោយធ្ងន់ធ្ងរឡើងៗ ដោយសារតែមានថវិកាតិចតួច ឬ គ្មានសោះដើម្បីទ្រទ្រង់សកម្មភាពគំរោង ដែលផ្តោតទៅលើបញ្ហាយេនឌ័រ និងកុមារ ។ វាបង្កអោយ

មានការលំបាកដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រី ក្នុងការឆ្លើយតប និងតំណាងអោយប្រជាជនរបស់គាត់ ។

● ក្រុមប្រឹក្សាឃុំជាស្ត្រីមិនអាចមានឥទ្ធិពលពេញលេញក្នុងការសំរេចចិត្តក្នុងនាមជាក្រុមប្រឹក្សាឃុំបានទេ ពីព្រោះតែពួកគាត់មិនសូវបានគេផ្តល់ពត៌មានអោយគ្រប់ជ្រុងជ្រោយ និងមិនបានចូលរួមនៅក្នុងការសំរេចចិត្តសំខាន់ៗជាច្រើនរបស់គណៈកម្មាធិការឃុំ ។ មូលហេតុមួយដោយសារក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រីមានការរវល់ខ្លាំងជាមួយនឹងការចូលរួមវគ្គបណ្តុះបណ្តាលសិក្ខាសាលា និងការផ្សព្វផ្សាយពត៌មានទៅលើបញ្ហាយេនឌ័រ និងកុមារ ។ ហេតុផលមួយទៀតពីព្រោះតែក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រីមានការទទួលខុសត្រូវនឹងកាតព្វកិច្ចនៅឯផ្ទះ និងទទួលប្រាក់ឧបត្ថម្ភតិចដែលផ្តល់ដោយក្រុមប្រឹក្សាឃុំ ។

● យើងទាំងអស់គ្នាគួរតែមានមោទនភាពចំពោះការអនុវត្តន៏ការងារបច្ចុប្បន្នរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រី ទោះបីជាភាពពិតមានការខ្វះខាតផ្នែកការគាំទ្រផ្នែកហិរញ្ញវត្ថុ និងជាស្មារតីក៏ដោយ ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រីក៏មានការពិបាកក្នុងការពិភាក្សាបញ្ហា និងស្វែងរកនូវការពិគ្រោះយោបល់បើប្រៀបធៀបទៅនឹងក្រុមប្រឹក្សាឃុំ-សង្កាត់ជាបុរស ។ បច្ចុប្បន្ននេះមិនមានសហគមន៏ក្រុមការងារ និងសហជីពសហគមន៏ដែលស្ត្រីជាក្រុមប្រឹក្សាឃុំ-សង្កាត់អាចចែករំលែក និងការរៀនសូត្រពីស្ត្រីជាក្រុមប្រឹក្សាឃុំដទៃដើម្បីដោះស្រាយបញ្ហាគ្នាទៅវិញទៅមកឡើយ ។

## ៤- ការសន្និដ្ឋាន

ការបោះឆ្នោតឃុំនៅ ខែ កុម្ភៈ ឆ្នាំ ២០០២ បានធ្វើអោយមានការផ្លាស់ប្តូរតួនាទីស្ត្រីក្នុងនយោបាយនៃប្រទេសកម្ពុជា ប៉ុន្តែនៅមានរយៈពេលយូរអង្វែងទៅទៀតសំរាប់ដំណើការកែទំរង់វិមជ្ឈការ ដើម្បីដោះស្រាយបញ្ហាប្រឈមនឹងឧបសគ្គទាំងអស់ដែលបានជួបប្រទះ ។ បញ្ហាប្រឈមសំខាន់ៗ មួយចំនួន ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ ដូចជា :

● នៅប្រទេសកម្ពុជាសព្វថ្ងៃមានគំនិត និងមតិដែលថាស្ត្រីភាគច្រើនហាក់ដូចជាមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើការងារមួយចំនួនអាចនិយាយបានថា នៅមានការមើលងាយលើសមត្ថភាពស្ត្រី ។ នេះវាបានបង្ហាញយ៉ាងច្បាស់ពិតប្រាកដដោយក្រុមប្រឹក្សាឃុំជាស្ត្រីមិនត្រូវបានគេផ្តល់ភាពស្មើគ្នា និងអាទិភាពពេញលេញក្នុងការអនុវត្តន៏ តួនាទីរបស់គាត់ឡើយ ហើយក៏គ្មានអំណាចការងារដែរ ។

● ភាពក្រីក្រក៏ជាបញ្ហាមួយដែរ ដែលរារាំងមិនអោយស្ត្រីចូលរួម និងអនុវត្តការងាររបស់គាត់អោយបានពេញលេញ ។ វាបានបង្ហាញអោយយើងឃើញយ៉ាងច្បាស់ថា បញ្ហានេះវាជះឥទ្ធិពលលើការអនុវត្តន៏វិមជ្ឈការអោយបានល្អនោះ ។

● ការលំបាកក្នុងការអោយស្ត្រីឈរឈ្មោះសំរាប់ការបោះឆ្នោតទៀត ដោយសារតែក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រីក្នុងតួនាទីនាពេលបច្ចុប្បន្ននេះមិនពេញចិត្តដោយសារគាត់ពុំមានឥទ្ធិពល ហើយនឹងមិនចង់បន្តតួនាទីរបស់

ក្នុងប្រទេស។ ទន្ទឹមនឹងនោះក៏មានបញ្ហា និងឧបសគ្គមួយចំនួនដែរ (i) តើមានរបៀបណាដែលក្រុមប្រឹក្សាឃុំ-សង្កាត់ស្ត្រីគួរ និងអាចទទួលបានការគាំទ្រគ្នាទៅវិញទៅមកបាន? (ii) តើគួរធ្វើយ៉ាងណាដើម្បីបង្កើត និងពង្រឹងអោយមានការចែករំលែកបទពិសោធន៍ ការរៀនសូត្រពីគ្នា និងតួនាទីគំរូរវាងស្ត្រីក្នុងក្រុមប្រឹក្សា? ហើយ (iii) តើមានឱកាស និងវេទិកាណាដែលការផ្លាស់ប្តូរបទពិសោធន៍ទាំងនេះអាចកើតឡើង?

• សំនួរនៅតែមានជាច្រើនទៀត តើវេទិកាណា អ្នកណា ពេលណា ដែលយើងទាំងអស់គ្នានឹងត្រូវលើកយកបញ្ហាប្រឈមរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រីទាំងនេះមកដោះស្រាយនូវបរិបទនៃកំណែទម្រង់វិមជ្ឈការក្នុងប្រទេសកម្ពុជា?

**បទសំភាសន៍ ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់នៅខេត្តក្រចេះឆ្នាំ ២០០៣**

ខ្ញុំបានក្លាយជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់បន្ទាប់ពីការបោះឆ្នោតឃុំ-សង្កាត់ក្នុង ខែ កុម្ភៈ ឆ្នាំ ២០០២ មុនខ្ញុំធ្វើជាក្រុមប្រឹក្សាឃុំ-សង្កាត់ ខ្ញុំធ្វើជាអ្នកស្ម័គ្រចិត្តម្នាក់នៅកាកបាទក្រហមខេត្ត ហើយក៏ជាកម្មសិក្សាការីផ្នែកឱសថសាស្ត្រផងដែរ។ ពីមុនខ្ញុំមិនសូវយល់ដឹងពីវិមជ្ឈការទេ ក្រុមប្រឹក្សាឃុំថ្ងៃនេះ ការទទួលខុសត្រូវរបស់ខ្ញុំក្នុងឃុំ គឺ លើយេនឌ័រ និងសុខភាព ហើយខ្ញុំក៏ជាសមាជិកគណៈកម្មាធិការត្រួតពិនិត្យ និងវាយតំលៃក្នុងឃុំម្នាក់ដែរ។ រាល់ខែមានការប្រជុំ ៤ ដងក្នុងឃុំ ហើយខ្ញុំតែងតែលើកយោបល់រាល់ពេលអង្គប្រជុំ ប៉ុន្តែមើលទៅ គឺមានអ្នកគាំទ្រតិចតួចប៉ុណ្ណោះ។ ក្រុមប្រឹក្សាឃុំ-សង្កាត់បុរសផ្សេងទៀតនៅតែគិតថា ក្រុមប្រឹក្សាឃុំ-សង្កាត់ស្ត្រីមិនមានសមត្ថភាព និងមិនទាន់ផ្តល់អាទិ-ភាពពេញលេញនៅឡើយទេ។ ខ្ញុំនិយាយបាន ១០ ម៉ាត់គេបានស្តាប់ខ្ញុំតែ ៣ ម៉ាត់ ប៉ុណ្ណោះ។ ទស្សនៈរបស់គេមកលើរូបខ្ញុំដែលធ្វើជាគណៈកម្មាធិការត្រួតពិនិត្យ និងវាយតំលៃឃុំនោះ គឺគ្រាន់តែបុគ្គលគ្មានប្រយោជន៍ប៉ុណ្ណោះ ព្រោះគេគ្រាន់តែលើកបន្តុបខ្ញុំ ប៉ុន្តែគេមិនដែលអោយខ្ញុំដឹងលំអិតក្នុងគំរោងណាមួយសោះឡើយ។ ជាឧទាហរណ៍គំរោងសាងសង់ផ្លូវថ្នល់ប្រវែង ៦៧២ម៉ែត្រនៅក្នុងឃុំ។ មេឃុំឃើញភាពមិនប្រក្រតីក្នុងគំរោងបែរជាគាត់មិនបានប្រាប់ក្រុមប្រឹក្សាឃុំអោយដឹងទេ ជាពិសេសខ្ញុំតែម្តងដែលជាគណៈកម្មាធិការត្រួតពិនិត្យ និងវាយតំលៃស្រាប់។ ផ្លូវថ្នល់ត្រូវបានបញ្ចប់ដោយមិនត្រូវតាមស្តង់ដារបច្ចេកទេសបន្ទាប់ពីក្រុមអ្នកបច្ចេក-

ទេសថ្មី (TSS) បានវាយតំលៃរួច។ ទោះបីជាខ្ញុំមានឱកាសនិយាយជាមួយអ្នកធ្វើកិច្ចសន្យាក៏ដោយ ក៏គេមិនស្តាប់ខ្ញុំដែរ គេស្តាប់តែមេឃុំប៉ុណ្ណោះ។ វាមិនត្រឹមតែខ្ញុំជាគណៈកម្មាធិការស្ត្រីប៉ុណ្ណោះទេ ទោះបីតួនាទីក្នុងយេនឌ័រ និងសុខភាពក៏ដោយ ក៏គេមិនសូវស្តាប់ខ្ញុំដែរ។ តាមពិតខ្ញុំបានទទួលវគ្គបណ្តុះបណ្តាលយេនឌ័រ ហើយខ្ញុំគិតថា ខ្ញុំមានចំណេះដឹងគ្រប់គ្រាន់ក្នុងការបំពេញតួនាទីជាក្រុមប្រឹក្សាឃុំបានល្អ ប៉ុន្តែខ្ញុំមិនដែលទទួលប្រាក់ឧបត្ថម្ភសោះក្នុងការអនុវត្តន៍ការងាររបស់ខ្ញុំ។ ដូច្នេះហើយបានជាខ្ញុំពុំសូវដើរឆ្ងាយពីភូមិដើម្បីផ្សព្វផ្សាយពតិមាន។

ខ្ញុំមានការត្រេកអរណាស់ ហើយមានអារម្មណ៍ធូរស្រាលមែនទែនដែលអ្នកបានមកសំភាសន៍ខ្ញុំម្តងម្នាក់ដូច្នេះ។ ខ្ញុំបានគិត២ យប់ទុកជាមុន ហើយថាតើខ្ញុំត្រូវលាតត្រដាងនូវរាល់បញ្ហាទាំងនេះឬអត់? ខ្ញុំក៏ដឹងដែរថា បើខ្ញុំនិយាយរឿងនេះប្រាប់ គេវាហាក់ដូចជាការជះទឹកដាក់គ្នាប៉ុណ្ណោះ ប៉ុន្តែវាមិនធ្វើអោយខ្ញុំរស់នៅដោយស្ងប់បាននោះទេប្រសិនខ្ញុំព្យាយាមលាក់ទុកបញ្ហា គ្រប់បែបយ៉ាងនោះ។ ម្សិលមិញមេឃុំបាននិយាយថាបើយើងទាំងអស់គ្នាត្រូវបានគេសម្ភាសន៍ នៅថ្ងៃស្អែកនេះ សូមឆ្លើយ តែអ្វីដែលគេសួរបាន ហើយ កុំនិយាយអ្វីក្រៅ ប្រធានបទអោយសោះ។

**"បើគេសួរពីគោ សូមឆ្លើយគោ កុំឆ្លើយពីក្របី "**

ក្រុមប្រឹក្សាឃុំដទៃបានបន្ទោសខ្ញុំថា ខ្ញុំមិនដែលមកធ្វើការនៅការិយាល័យរាល់ថ្ងៃទេ ប៉ុន្តែខ្ញុំដឹងតួនាទីរបស់ខ្ញុំច្បាស់លាស់ ហើយខ្ញុំទៅការិយាល័យសំរាប់តែពេលប្រជុំប៉ុណ្ណោះ ខ្ញុំមិនចាំបាច់ទៅការិយាល័យរាល់ថ្ងៃទេ បើអោយខ្ញុំទៅដើម្បីតែបោសសំអាត និងហុចទឹកតែនោះ។ ហើយហ្នឹងមិនមែនជាការទទួលខុសត្រូវរបស់ខ្ញុំទេ។ ខ្ញុំខ្លាចផងដែរ ព្រោះខ្ញុំជាមនុស្សនិយាយចំៗមិនលាក់លៀមខ្ញុំនឹងត្រូវគេធ្វើបាប ហើយនឹងគ្មាននរណាថែរទាំកូនរបស់ខ្ញុំទេ ប្រសិនបើខ្ញុំសំភាសន៍រួមគ្នាជាមួយក្រុមប្រឹក្សាឃុំដទៃទៀតខ្ញុំក៏មិនបានប្រាប់រឿងរ៉ាវទាំងអស់នោះដែរ។ ខ្ញុំជាបេក្ខជនគណបក្សប្រជាជនកម្ពុជាទាំងអស់ក្នុងក្រុមប្រឹក្សាឃុំធ្វើការជាមួយគ្នាបានល្អ ប៉ុន្តែអ្នកដែលមានបញ្ហាគឺតែខ្ញុំម្នាក់ឯងប៉ុណ្ណោះ ហើយនិងក្រុមប្រឹក្សាឃុំនៅឃុំដទៃទៀត ពីព្រោះខ្ញុំមិនអាចបិទមាត់គ្រប់ពេលទេ ហើយខ្ញុំក៏ដឹងថាគ្មាននរណា ម្នាក់អាចបង្ខំខ្ញុំអោយបិទមាត់បានដែរ។ បញ្ហាលំបាកបំផុតក្រៅពីបញ្ហាទាំងអស់ដូចបានរៀបរាប់ខាងលើទៀតនោះ គឺកំរិតជីវភាពនៃការរស់នៅ។ ខ្ញុំទទួលបានប្រាក់ខែតែ៧0.000 រៀលប៉ុណ្ណោះក្នុង ១ខែហើយគ្រាន់តែចំណាយលើការធ្វើដំណើរទៅប្រជុំ ៤ដង ក្នុង ១ខែ នោះវាជិតអស់ទៅហើយ ខ្ញុំមិនចង់ធ្វើជាក្រុមប្រឹក្សាឃុំទៀតទេ ហើយខ្ញុំពិតជាចង់លាឈប់ពីការងារណាស់ ខ្ញុំនឹងមិនឈរឈ្មោះបោះឆ្នោតជាក្រុមប្រឹក្សាឃុំ-សង្កាត់ទៀតទេនៅអណត្តិក្រោយ។

# បទពិសោធន៍ និង ការឆ្លុះបញ្ចាំងស្ត្រី
# ភាពជាក្រុមប្រឹក្សាឃុំ-សង្កាត់




លោកស្រី វង់ ស៊ូ ប្រធានក្រុមប្រឹក្សាឃុំមានជ័យ ស្រុកសំឡូត ខេត្តបាត់ដំបង

សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាដែលជាភ្ញៀវជាតិ និងអន្តរជាតិជាទីគោរព និងរាប់អាន។

ខ្ញុំមានកិត្តិយសណាស់ដែលត្រូវបានទទួលការអញ្ជើញចូលរួមថ្លែងសុន្ទរកថាក្នុងវេទិកាពិគ្រោះយោបល់លើកទី ១ ស្ដីពីការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងប្រសិទ្ធភាពនៃការចូលរួមនេះនៅថ្នាក់ឃុំ-សង្កាត់ក្នុងប្រទេសកម្ពុជា។ ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីថ្លែងអំណរគុណដល់អង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា GAD/C និងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន DoLA ដែលបានអញ្ជើញរូបខ្ញុំឱ្យមកចូលរួមក្នុងថ្ងៃនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់គំរោងកែទំរង់រដ្ឋបាល និងវិមជ្ឈការ GTZ-ARDP ក្នុងការចូលរួមរៀបចំ និងឧបត្ថម្ភវេទិកានេះឡើង និងផ្ដល់ការគាំទ្រយ៉ាងសកម្មជាច្រើនចំពោះដំណើរការវិមជ្ឈការនៅក្នុងប្រទេសកម្ពុជា។

ខ្ញុំឈ្មោះ **វង់ ស៊ូ** ជាប្រធានក្រុមប្រឹក្សាឃុំមានជ័យ ស្រុកសំឡូត ខេត្តបាត់ដំបង និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ដែលមានវត្តមានថ្ងៃនេះ គឺដើម្បីចែករំលែកជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់អំពីការងារប្រកបដោយជោគជ័យរបស់ក្រុមប្រឹក្សាឃុំជាស្ត្រីទាំងបីនៅក្នុងឃុំមានជ័យ។ យើងទាំងអស់គ្នាបានធ្វើការរួមគ្នាយ៉ាងខ្លាំងក្លាអស់រយៈពេលបីឆ្នាំកន្លងមកដើម្បីធ្វើការផ្លាស់ប្ដូរនូវអ្វីដែលអាចធ្វើបាន ហើយនឹងប្រើសិទ្ធិអំណាចរបស់យើងដើម្បីលើកឡើងអំពីបញ្ហាស្ត្រីជាច្រើន។

ធ្វើការដើម្បីប្រជាជន និងស្ត្រីមិនមែនជារឿងថ្មីសំរាប់ខ្ញុំនោះទេ ព្រោះខ្ញុំបានធ្វើការ ៦ ឆ្នាំរួចមកហើយជាសមាជិកសកម្មរបស់សមាគមស្ត្រីកម្ពុជានៅក្នុងឃុំរបស់ខ្ញុំ។ ដូច្នេះហើយនៅក្នុងការបោះឆ្នោតឃុំ-សង្កាត់ លោកអភិបាលស្រុក ហើយនឹងប្រជាជនបានជំរុញលើកទឹកចិត្តខ្ញុំឱ្យឈរឈ្មោះក្នុងបញ្ជីបេក្ខជន។

### "ហើយខ្ញុំត្រូវបានគេបោះឆ្នោតអោយជាមេ ឃុំ"

នៅពេលនោះខ្ញុំមានអារម្មណ៍ច្របូកច្របល់ណាស់ថែមទាំងរំភើប និងភ័យផងដែរ។ ជាមួយគ្នានេះមានសំនួរជាច្រើនបានលេចឡើង

ក្នុងអារម្មណ៍របស់ខ្ញុំ។

**"តើខ្ញុំនឹងធ្វើការងារនេះយ៉ាងដូចម្តេច? មានការងារ និងការខ្វល់ខ្វាយជាច្រើនចំពោះខ្ញុំ ចំពោះរូបខ្ញុំជាស្ត្រីដែលមានការរើសអើងពីសង្គមផងនោះថា តើស្ត្រីអាចធ្វើជាមេឃុំ និងធ្វើការងារបានល្អដូចម្តេចទៅ ?"**

ប៉ុន្តែថ្ងៃនេះ ខ្ញុំមានវត្តមាននៅទីនេះគឺដើម្បីជំរាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ថា **"ទេ"** ស្ត្រីអាចធ្វើជាមេឃុំ ឬ ក្រុមប្រឹក្សាឃុំ និងធ្វើការងាររបស់គាត់បានល្អជាងបុរសទៀតផង។

ការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ គឺជាការងារអាទិភាពមួយសំរាប់ស្ត្រីនៅក្នុងឃុំរបស់ខ្ញុំ ដូច្នេះហើយយើង (ទាំងក្រុមប្រឹក្សាឃុំប្រុសនិងស្រី) បានចាប់ផ្តើមធ្វើយុទ្ធនាការបង្កើនការយល់ដឹង យេនឌ័រក្នុង៦ភូមិនៅក្នុងឃុំ។ យុទ្ធនាការនេះយើងបានប្រាប់ដល់អ្នកភូមិទាំងអស់គ្នាអំពីគណៈកម្មាធិការដោះស្រាយជំលោះ ក្នុងរចនាសម្ព័ន្ធក្រុមប្រឹក្សាឃុំ និងតួនាទីរបស់គណៈកម្មាធិការទាំងនោះដែលអាចធ្វើការការពារដល់ស្ត្រី

**"ចាស់ វាពិតជាជោគជ័យដំបូងរបស់យើងសំរាប់ការងារបីឆ្នាំកន្លងមក គឺការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ"**

ប៉ុន្តែរឿងនិមួយៗតែងតែមានមុខពីរ ចាស់មែនហើយយើងមានការលំបាកណាស់។ នៅពេលដែលខ្ញុំ និងក្រុមប្រឹក្សាឃុំស្ត្រីពីរនាក់ទៀតនៅក្នុងឃុំមានជ័យបានចាប់ផ្តើមធ្វើការងារ យើងឃើញថា មានការប្រឆាំងការមិនទុកចិត្ត ការព្រងើយកណ្តើយពីក្រុមប្រឹក្សាឃុំជាបុរសផងដែរ។ ប៉ុន្តែក្រោយមកក៏មានការផ្លាស់ប្តូរយ៉ាងរលូន និងរៀនសូត្រពីគ្នាទៅវិញទៅមកផងដែរ។ ពួកយើងមានទំនុកចិត្តលើខ្លួនឯងកាន់តែច្រើនផងដែរទៅលើការអនុវត្តន៍ការងារ និងតួនាទីរបស់យើងបន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលរបស់អង្គការចំរើនស្ត្រី និងអមរា។

ទោះបីជាយ៉ាងណាក៏ដោយស្ត្រីអាច ឬ នៅតែចូលរួមការងារក្រុមប្រឹក្សាឃុំយ៉ាងច្រើនពិតប្រាកដ។ ក្នុងនាមជាស្ត្រីទាំង ៣នាក់ក្នុងក្រុម-ប្រឹក្សាឃុំរបស់ខ្ញុំ យើងខ្ញុំបានធ្វើអោយយើងកាន់តែរឹងមាំឡើងក្នុងការឆ្លុះបញ្ចាំងពីតំរូវការរបស់ស្ត្រី នៅក្នុងរបៀបវារៈរបស់យើង។ ខ្ញុំសូមសំណូមពរអោយមានក្រុមប្រឹក្សាឃុំជាស្ត្រី ៣នាក់គ្រប់ឃុំនៅទូទាំងប្រទេស។ យើងត្រូវការស្ត្រីច្រើនទៀតដើម្បីអោយគេបោះឆ្នោតអោយសំរាប់ការបោះឆ្នោតនាពេលខាងមុខ ហើយយើងត្រូវការស្វែងរកនូវវិធីសាស្ត្រដែលយើងអាចឈានទៅរកការរីកចំរើន។

លើសពីនេះទៀតក្រុមប្រឹក្សាឃុំជាស្ត្រីត្រូវការការជួយជ្រោមជ្រែងពី NGOs ទាំងឡាយដែលធ្វើការនៅក្នុងសហគមន៍ជាមួយនឹងប្រជាជនដើម្បីធ្វើការឱ្យកាន់តែមានប្រសិទ្ធិភាពថែមទៀត។

យើងត្រូវការវគ្គបណ្តុះបណ្តាលថែមទៀត ប៉ុន្តែវគ្គបណ្តុះបណ្តាលមិនមែនជារឿងតែមួយមុខប៉ុណ្ណោះទេដែលយើងត្រូវការ ហើយវគ្គបណ្តុះបណ្តាលយេនឌ័រនឹងមិនជួយបានច្រើនទេ ដរាបណាយើងមិនបញ្ចូលក្រុមប្រឹក្សាឃុំជាបុរសផងនោះ។

សូមអរគុណ!

# បទពិសោធន៍ និង ការឆ្លុះបញ្ចាំង
# ស្ត្រីភាពជាក្រុមប្រឹក្សាឃុំ-សង្កាត់



លោកស្រី គង់ ផល្លី សមាជិកក្រុមប្រឹក្សាឃុំកំពង់ក្របៅ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ

សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ដែលជាភ្ញៀវជាតិ និងអន្តរជាតិជាទីគោរព និងរាប់អាន។

ខ្ញុំមានកិត្តិយស និងពេញចិត្តយ៉ាងខ្លាំង ដែលបានមកចូលរួមថ្លែងសុន្ទរកថាក្នុងវេទិកាពិគ្រោះយោបល់លើកទី ១ ស្តីពីការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងប្រសិទ្ធភាពនៃការចូលរួមនេះនៅថ្នាក់ឃុំ-សង្កាត់ក្នុងប្រទេសកម្ពុជា។ ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីថ្លែងអំណរគុណដល់អង្គការ យេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា GAD/C និងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន DoLA ដែលបានអញ្ជើញរូបខ្ញុំឱ្យមកចូលរួមក្នុងថ្ងៃនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះគំរោងកែទំរង់រដ្ឋបាល និងវិមជ្ឈការ GTZ-ARDP ក្នុងការខិតខំយ៉ាងខ្លាំង ដើម្បីរៀបចំព្រឹត្តិការណ៍នេះឡើងគួរជាទីមោទនៈ។

"**៣ឆ្នាំជាសមាជិកក្រុមប្រឹក្សាឃុំ**" នៅពេលដែលខ្ញុំត្រូវបានគេអញ្ជើញអោយមកចូលរួមក្នុងវេទិកានេះ ដើម្បីចែករំលែកនូវបទពិសោធន៍ចំពោះការងារជាក្រុមប្រឹក្សាឃុំបីឆ្នាំកន្លងមក ខ្ញុំបានគិតមួយភ្លែត ហើយយល់ថា "**វាមិនជាការពិបាកណាស់ទេចំពោះខ្ញុំ ប៉ុន្តែខ្ញុំក៏មានមោទនភាពចំពោះខ្លួនឯងដែរ។**"

ខ្ញុំឈ្មោះ **គង់ ផល្លី** ខ្ញុំបានឈរឈ្មោះក្នុងការបោះឆ្នោតឃុំ-សង្កាត់ គឺដើម្បីជួយ និងបំរើប្រជាពលរដ្ឋក្នុងឃុំរបស់ខ្ញុំ។ ហើយ "**ខ្ញុំបានជាប់ឆ្នោតជាក្រុមប្រឹក្សាដែលជាស្ត្រីតែម្នាក់ប៉ុណ្ណោះក្នុងឃុំរបស់ខ្ញុំ**"

ការប្រឆាំងនឹងអំពើពុករលួយ និងបញ្ហាស្ត្រី គឺជាផ្នែកយ៉ាងសំខាន់ដែលខ្ញុំបានផ្តោតការយកចិត្តទុកដាក់ទៅលើអស់រយៈពេល ៣ឆ្នាំកន្លងមក។ ទោះបីជាមានបញ្ហា និងឧបសគ្គបានកើតឡើងចំពោះខ្ញុំយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែចាំជាប់ជានិច្ចចំពោះអ្វីដែលបានសន្យាចំពោះប្រជាពលរដ្ឋរបស់ខ្ញុំថា "**ខ្ញុំនឹងប្រើសិទ្ធិអំណាចរបស់ខ្ញុំអោយអស់ពីសមត្ថភាពដើម្បីផលប្រយោជន៍របស់ពួកគេ**"។

ការផ្តល់នូវភ្លើងអគ្គិសនីក្នុងឃុំដោយមាន

ការចុះកុងត្រាជាផ្លូវការជាមួយក្រុមហ៊ុនឯកជនដែលឆ្នាំដំបូងគឺត្រូវយកតំលៃថេរ និងឆ្នាំបន្ទាប់នឹងបញ្ចុះតំលៃ។ ផ្ទុយទៅវិញវាគួរអោយភ្ញាក់ផ្អើលណាស់ដែលម្ចាស់កុងត្រាមិនទាន់នឹងបានមួយឆ្នាំផង បែរជាម្ចាស់ក្រុមហ៊ុនភ្លើងឯកជនស្នើសុំអោយតំលើងថ្លៃភ្លើងទៅវិញ។ ពេលនោះខ្ញុំបាននិយាយក្នុងអង្គប្រជុំក្រុមប្រឹក្សាថា **"ទេ !"**

យើងមិនគួរយល់ព្រមនឹងសំណើនេះទេ ហើយយើងមិនត្រូវចំណាយលើសពីហ្នឹងទៀតដែរ ពីព្រោះយើងមានកិច្ចសន្យាជាមួយគ្នារួចទៅហើយថាតំលៃនៅថេរ។ **"ហេតុអ្វីបានជាយើងត្រូវយល់ព្រមជាមួយគេ?** "សហការីរបស់ខ្ញុំក៏គេបានយល់ស្របទៅនឹងគំនិតរបស់ខ្ញុំដែរ ប៉ុន្តែគេមិនច្បាស់ថា គេអាចធ្វើអន្តរាគមន៍លើរឿងនេះបានជោគជ័យ ឬ ក៏អត់ទេ? ខ្ញុំក៏និយាយទៀតថា ខ្ញុំនឹងសន្យាដោះស្រាយបញ្ហានេះ ដូច្នេះ **"ខ្ញុំត្រូវតែយកករណីនេះ មកធ្វើការតវ៉ាទោះបីជាយ៉ាងណាក៏ដោយ"**។ ទីបញ្ចប់ម្ចាស់ក្រុមហ៊ុនឯកជនបានយល់ព្រមទៅតាមកុងត្រាថា នឹងរក្សាតំលៃដដែល។ នេះគឺជាសមិទ្ធផលរបស់ខ្ញុំ។

ប៉ុន្តែថ្ងៃនេះខ្ញុំចង់ចែករំលែករឿងរ៉ាវ និងការលំបាក ដែលខ្ញុំបានជួបប្រទះអស់រយៈពេលបីឆ្នាំកន្លងមកដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់អោយបានដឹង និងជ្រាបជាពត៌មាន ហើយទោះបីជាឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជឿ ឬ មិនជឿក៏ដោយ។ ការលំបាកសំរាប់ខ្ញុំវាមានច្រើនពេក ហើយបើគ្រាន់តែគិតវាស្ទើរតែធ្វើអោយខ្ញុំស្រក់ទឹកភ្នែកទៅហើយ។

**រឿងដែលគួរអោយភ្ញាក់ផ្អើលដំបូងនោះគឺ** នៅពេលដែលខ្ញុំបានដឹងថា មានស្ត្រីផ្សេងម្នាក់ទៀតដែលមិនមែនជាក្រុមប្រឹក្សាឃុំត្រូវបានមេឃុំតែងតាំងអោយទទួលខុសត្រូវលើបញ្ហាស្ត្រី និងកុមារ។ តើយើងមិនបានរៀនទេ ឬ នៅក្នុងវគ្គបណ្តុះបណ្តាលដែលថា ការងារនេះជាការទទួលខុសត្រូវជាផ្លូវការរបស់ខ្ញុំ?

**ខ្ញុំនៅតែមិនទាន់មានចំលើយនៅឡើយ?**

បន្ទាប់មកការងាររបស់ខ្ញុំត្រូវបានផ្អាកជាបណ្តោះអាសន្នមានរយៈពេល ២ ខែដោយគ្មានកំណត់ហេតុ ឬ របាយការណ៍ណាទេ។ តើហេតុអ្វីបានជាយ៉ាងនេះ? តើយើងមិនបានរៀនទេ ឬ ដែលថា ប្រជាជនជាអ្នកជ្រើសរើសខ្ញុំឡើង ហើយមានតែពួកគាត់ទេដែលអាចដកយកសិទ្ធិក្នុងការធ្វើការងារពីខ្ញុំបាន?

**មកដល់ពេលនេះខ្ញុំនៅតែគ្មានចំលើយសោះសំរាប់ខ្ញុំ !**

ប្រសិនបើថ្ងៃនេះយើងនៅតែសួរនូវសំនួរស្តីពីការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងប្រសិទ្ធិភាពនៃការចូលរួមនេះ នៅថ្នាក់ឃុំសង្កាត់វាមិនអាចកើតឡើងទេ បើគ្រាន់តែផ្តល់ការបណ្តុះបណ្តាលចំពោះតែស្ត្រីប៉ុណ្ណោះនោះ។

**យើងត្រូវការការជួយគាំទ្រជាច្រើនផ្សេងទៀត។**

ជារៀងរាល់ព្រឹកខ្ញុំតែងតែស្តាប់វិទ្យុ ហើយខ្ញុំសប្បាយចិត្តណាស់ដែលបានឮអង្គការក្រៅ

រដ្ឋាភិបាលជាច្រើនបាន និងកំពុងព្យាយាមជួយស្ត្រីជាច្រើនទូទាំងប្រទេសកម្ពុជា។ ប៉ុន្តែក្រោយមកខ្ញុំបានសួរខ្លួនឯងថា តើអង្គការទាំងនោះនៅឯណា? ហើយពួកគេបាននិយាយតែនៅក្នុងវិទ្យុទេឬ?

**យើងជាក្រុមប្រឹក្សាឃុំស្ត្រីពិតជាត្រូវការអ្នកទាំងអស់គ្នាណាស់**

យើងត្រូវការអ្នកទាំងអស់គ្នាដើម្បីជួយក្នុងការសំរេច និងដោះស្រាយបញ្ហាដែលបានជួបប្រទះយើងត្រូវការអ្នកទាំងអស់គ្នាជួយដើម្បីធ្វើអោយឆ្លើយតបទៅនឹងតំរូវការ និងផលប្រយោជន៍របស់ស្ត្រីនៅក្នុងគំរោងអភិវឌ្ឍន៍របស់ឃុំ។ យើងក៏ត្រូវការអ្នកទាំងអស់គ្នាទៀតផងដែរ ដើម្បីអោយមានស្ត្រីកាន់តែច្រើនក្នុងក្រុមប្រឹក្សាឃុំសំរាប់ការបោះឆ្នោតនាពេលខាងមុខនេះ។

ជាពិសេស គឺយើងត្រូវការអ្នកទាំងអស់គ្នាដើម្បីធ្វើការរួមគ្នា។

សូមអរគុណ!




លោកស្រី ហាក់ លី សមាជិកក្រុមប្រឹក្សាឃុំរំចេក ស្រុកបន្ទាយស្រី ខេត្តសៀមរាប

សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាដែលជាភ្ញៀវជាតិ និងអន្តរជាតិជាទីគោរព និងរាប់អាន។

ជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា GAD/C និងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន DoLA និងអង្គការ GTZ និងគំរោងកែទំរង់រដ្ឋបាលវិមជ្ឈការ ARDP ដែលបានផ្តល់ឱកាសអោយខ្ញុំមានវត្តមាននៅទីនេះ ដើម្បីចែករំលែកបទពិសោធន៍ជាស្ត្រីនយោបាយម្នាក់ក្នុងវេទិកាពិគ្រោះយោបល់លើកទី ១ ស្តីពីការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងប្រសិទ្ធិភាពនៅថ្នាក់ឃុំ-សង្កាត់ក្នុងប្រទេសកម្ពុជា។

ខ្ញុំឈ្មោះ **ហាក់ លី** សមាជិកក្រុមប្រឹក្សាឃុំជាស្ត្រីតែម្នាក់គត់បានជាប់ឆ្នោតក្នុងឃុំរំចេក ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ ទោះបីខ្ញុំជួបការលំបាក និងឧបសគ្គអស់រយៈពេល ៣ ឆ្នាំកន្លងមកជាសមាជិកក្រុមប្រឹក្សាឃុំជាស្ត្រីតែម្នាក់យ៉ាងណាក៏ដោយ **"ប៉ុន្តែខ្ញុំនៅតែមិនបាត់បង់នូវសេចក្តីក្លាហានដើម្បីបំរើស្ត្រី និងបុរសនៅក្នុងឃុំរបស់ខ្ញុំឡើយ ពីព្រោះខ្ញុំបានទទួលការគាំទ្រជ្រោមជ្រែងយ៉ាងកក់ក្តៅពីប្រជាជននៅក្នុងឃុំរបស់ខ្ញុំក្នុងការទទួលបានតួនាទីនេះ"** ហើយពួកគេគឺជាអ្នកដែលផ្តល់សេចក្តីក្លាហានអោយខ្ញុំឈរឈ្មោះជាបេក្ខជនបោះឆ្នោតឃុំកាលពីឆ្នាំ ២០០២។ ទោះបីជាការបារម្ភដ៏ធំបំផុតរបស់ខ្ញុំថា តើខ្ញុំអាចនឹងធ្វើជាក្រុមប្រឹក្សាឃុំបាន ឬអត់នោះក៏ដោយ ៣ឆ្នាំកន្លងមកនេះខ្ញុំបានរៀនសូត្រជាច្រើនដែលធ្វើអោយខ្ញុំកាន់តែមានទំនុកចិត្តកាន់តែខ្លាំង ក្នុងការងារជាប្រចាំរបស់ខ្ញុំ និងខ្លួនខ្ញុំដោយសារតែខ្ញុំបានរៀនពីអង្គការចំរើនស្ត្រី។

ខ្ញុំធ្វើការ ៥ថ្ងៃក្នុង ១អាទិត្យនៅឯការិយាល័យ ហើយទទួលខុសត្រូវនូវការងារជាមួយចំនួនដូចខាងក្រោម:

- ការងាររដ្ឋបាល
- ការសរសេររបាយការណ៍
- ការងារស្ត្រី និងកុមារ
- ការចុះទៅតាមភូមិ

ប៉ុន្តែខ្ញុំមិនសូវបានចូលរួមក្នុងដំណើរការនៃ

ការសំរេចចិត្តប៉ុន្មានទេ ពីព្រោះយោបល់របស់ខ្ញុំភាគច្រើនត្រូវបានគេបដិសេធ ឬ ត្រូវបានគេប្រាប់ថាខ្ញុំមិនដឹងអីទេ ឬ មិនមានសមត្ថភាពគ្រប់គ្រាន់ឡើយ ។ រឿងដែលសំខាន់ជាងនេះទៀតគឺថា ដំណើរការនៃការសំរេចលើការងារក្រដាសស្នាមត្រូវបានធ្វើនៅឯផ្ទះរបស់មេឃុំ ក្នុងខណៈដែលខ្ញុំកំពុងតែនៅប្រចាំការនៅការិយាល័យឃុំដូចជាអ្នកយាម ។ ខ្ញុំបានរៀននិងយល់ដឹងពីច្បាប់ពីតួនាទីជាក្រុមប្រឹក្សាឃុំសង្កាត់ ហើយខ្ញុំបានយល់ដឹងពីបញ្ហានេះច្បាស់ជាងក្រុមប្រឹក្សាឃុំជាបុរសក៏ដោយ ក៏ពួកគេមិនទទួលស្គាល់នូវចំណេះដឹងរបស់ខ្ញុំដែរ ពីព្រោះខ្ញុំជាស្ត្រីតែម្នាក់ឯងគត់នៅក្នុងឃុំរបស់ខ្ញុំ ។

ខ្ញុំបានរៀនច្បាប់ក្រុមប្រឹក្សាឃុំយ៉ាងពិតប្រាកដ ហើយបានយល់ដឹងថា តួនាទីរបស់ស្មៀននៅក្នុងឃុំ គឺជួយការងាររដ្ឋបាលក្រុមប្រឹក្សាឃុំ "**ប៉ុន្តែការងារទាំងនោះបានធ្លាក់មកលើខ្ញុំដដែល ហើយថែមទាំងគាត់ចាត់ទុកខ្ញុំធ្វើមិនបានល្អទៀតផង**"

**ខ្ញុំសូមលើករឿងពិតមួយដែលកើតមានឡើងលើរូបខ្ញុំជូន :** ថ្ងៃមួយមានគ្រួសារពីរនាក់មកការិយាល័យឃុំដើម្បីយកលិខិតបញ្ជាក់ស្នើសុំរៀបអាពាហ៍ពិពាហ៍ ហើយឯកសារទាំងនោះស្មៀនឃុំបានសន្យានឹងធ្វើរួចនៅថ្ងៃនោះ ។ ពេលនោះ ខ្ញុំឆែកឆេររកមើលឯកសារគ្រប់ទីកន្លែងតែមិនឃើញ ហើយខ្ញុំសំរេចចិត្តទូរស័ព្ទទៅស្មៀន និងសួរគាត់ពីឯកសារទាំងនោះបែរជាស្មៀនឃុំឆ្លើយទាំងសំលេងខឹង និងសួរខ្ញុំហេតុអ្វីបានជាទូរស័ព្ទទៅរកគាត់បើត្រូវការអ្វីសូមទៅជួបគាត់ផ្ទាល់ ។

រាល់ថ្ងៃខ្ញុំចំណាយលុយហោប៉ៅខ្លួនឯងក្នុងការធ្វើដំណើរទៅធ្វើការងារតាមភូមិដោយគ្មានការបង់សងពីថវិកាឃុំអោយខ្ញុំវិញទេ នេះមិនត្រឹមតែខ្ញុំទេក្រុមប្រឹក្សាឃុំដទៃទៀតក៏មិនបានដែរ នេះជាទំលាប់នៅក្នុងឃុំរបស់ខ្ញុំ ។ តែចំពោះ ខ្ញុំវាធ្ងន់ធ្ងរជាងគេ ពីព្រោះខ្ញុំត្រូវការចំណាយលុយផ្ទះដើម្បីធ្វើការអោយឃុំ ។

ខ្ញុំមិនមែនត្អូញត្អែរថា ខ្ញុំមានការងារច្រើនជាងក្រុមប្រឹក្សាឃុំជាបុរសឡើយ ។ តែខ្ញុំកំពុងតែត្អូញត្អែរពីការរើសអើងរបស់សង្គម និងការឆ្លើយតបជាបន្ទាន់ពីក្រុមអ្នកពាក់ពន្ធ័ទាំងអស់ ។

យើងជាក្រុមប្រឹក្សាឃុំជាស្ត្រីត្រូវការការជួយគាំទ្រជ្រោមជ្រែងបន្ត ដូចជាបងស្រីក្រុមប្រឹក្សាឃុំមានជ័យ និងឃុំក្របៅដែលបានលើកឡើងក្នុងសុន្ទរកថារបស់គាត់ផងដែរ ។

**ចាស៎ មែនហើយយើងត្រូវការវគបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំទាំងបុរស និងស្ត្រី** ហើយបើយើងផ្តោតការសិក្សាលើតែស្ត្រីនោះ នោះបញ្ហាមិនអាចដោះស្រាយបានទេ ។ ខ្ញុំមានបំណងចង់អោយមានស្ត្រីកាន់តែច្រើនត្រូវបានបោះឆ្នោតជ្រើសរើសគ្រប់ឃុំផងដែរ ។

ទោះបីតិចក៏ដោយ" **តែមិនត្រូវអត់ទេក្នុងឃុំនីមួយៗ ប្រសិនប្រជាជនចង់បានខ្ញុំទៀត ខ្ញុំនឹងឈរឈ្មោះបោះឆ្នោតបន្តទៀតនៅអាណត្តិក្រោយ ប៉ុន្តែពេលនោះខ្ញុំចង់ជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សាឃុំ ដែលខ្ញុំអាចនឹងមានសិទ្ធិអំណាចដើម្បីបំពេញការងារ និងឆ្លើយតបនឹងតំរូវការរបស់ស្ត្រី**" ។

សូមអរគុណ!




ធីតា ឃីះ នាយិកាប្រតិបត្តិ អង្គការសីលការ
ថ្ងៃទី ១៧ មករា ២០០៥ ទីក្រុង ភ្នំពេញ

ខ្ញុំមានកិត្តិយសនៅក្នុងពេលនេះ ដោយបានទទួលភារកិច្ចមកចែករំលែកនូវទស្សនៈផ្ទាល់ខ្លួនមួយចំនួនដែលខ្ញុំទទួលបានដោយឆ្លងកាត់បទពិសោធន៍ផ្ទាល់ខ្លួន និងដោយការរៀនសូត្រពីអ្នកសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះព្រមទាំងយោងទៅលើការសង្កេត និងស្រាវជ្រាវផ្ទាល់ខ្លួនរបស់ខ្ញុំផ្ទាល់ផង ខ្ញុំសូមលើកមកនូវចំនុចគោល៧ ដោយសង្ខេបដែលមាន :

១.អ្វីទៅជាអង្គការស្ត្រីបច្ចុប្បន្ននៅកម្ពុជា? តើគេធ្វើអ្វីខ្លះ នៅពេលបច្ចុប្បន្ន និងដើម្បីអ្វី?

២.តើគេបានជួបឧបសគ្គអ្វីខ្លះ ក្នុងការអនុវត្តសកម្មភាពរបស់គេ?

៣.អនុសាសន៍អ្វីខ្លះ ដើម្បីធ្វើអោយសំរេចនូវគោលបំណង?

នៅក្នុងចំណោមអង្គការស្ត្រីដែលបច្ចុប្បន្ននេះកំពុងដំណើរការនៅក្នុងសង្គមកម្ពុជាយើងសព្វថ្ងៃអាចចាត់ទុកជា ២ ប្រភេទ: ទី ១ ស្ថាប័នសង្គមសាធារណៈ និងទី ២ ស្ថាប័នសង្គមស៊ីវិល។

ស្ថាប័នសាធារណៈ គឺជាស្ថាប័នរបស់រាជរដ្ឋាភិបាលដែលមាន ១) ផ្នែកនិតិប្រតិបត្តិ ២) និតិបញ្ញត្តិដែលមានរដ្ឋសភា និងព្រឹទ្ធសភា និងទី៣ ផ្នែកតុលាការ។ អង្គការដែលបំរើអោយស្ត្រីនៅក្នុងស្ថាប័នរដ្ឋាភិបាលយើងមានក្រសួងកិច្ចការនារីដែលមានបណ្តាញតាមរយៈខ្សែបណ្តោយទៅដល់ ខេត្ត ស្រុក ឃុំ និងភូមិ។

តាមរយៈខ្សែបណ្តោយរបស់ខ្លួនក្រសួងកិច្ចការនារី បានគ្រប់គ្រងទៅលើមជ្ឈមណ្ឌលអភិវឌ្ឍន៍ចំនួន ៦ខេត្ត។ ក្រសួងកិច្ចការនារីគឺជាយន្តការរបស់រាជរដ្ឋាភិបាល និងមានភារកិច្ចដើម្បីលើកស្ទួយ និងការពារផលប្រយោជន៍ និងសិទ្ធិរបស់ស្ត្រី និងគ្រួសាររបស់គេក្នុងប្រទេសកម្ពុជា។ ក្រសួងធ្វើការសំរបសំរួលជាមួយក្រសួងមន្ទីរខេត្តក្រុងដែលពាក់ព័ន្ធ ក្រុមប្រឹក្សា ឃុំ-សង្កាត់ គណៈកម្មការនានា និងអង្គការមិនមែនរដ្ឋាភិបាល **"ដើម្បីបញ្ជ្រាបយេនឌ័រ ទៅក្នុងគោលនយោបាយជាតិ គោលនយោបាយមូលដ្ឋាន និងកម្មវិធីនានាដើម្បី**

**បង្កើនសមាមាត្រនៃការចូលរួមរបស់ស្ត្រីអោយបានជាអតិបរមាតាមដែលអាចធ្វើទៅបានក្នុងស្ថាប័ន ជាតិគ្រប់ជាន់ថ្នាក់**"។

ក្រសួងកិច្ចការនារីបានធ្វើគំរោងនារីរតនៈ ២ លើករួចមកហើយលើកតំកើងសេចក្តីថ្លៃថ្នូរ និងសេចក្តីសង្ឃឹមរបស់ស្ត្រី។ ក្រសួងកិច្ចការនារីបានជ្រើសរើសយកក្រសួងមួយចំនួនជាអាទិភាពមានក្រសួងយុត្តិធម៌ ក្រសួងអប់រំ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច ក្រសួងផែនការ ក្រសួងទេសចរណ៍ និងក្រសួងអភិវឌ្ឍន៍ជនបទដោយលើកជាគំរោងកម្មវិធីជាក់ស្តែងមកអនុវត្ត។ បន្ថែមទៅលើនោះទៀត ក្រសួងធ្វើការជាមួយក្រុមបង្គោលយេនឌ័រនៅគ្រប់ក្រសួង។ រដ្ឋមន្ត្រីនៃក្រសួងកិច្ចការនារីក៏ជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រីដែលជាសេនាធិការដល់រាជរដ្ឋាភិបាល រួមទាំងការផ្តល់អនុសាសន៍នានាទៅលើការអនុវត្តន៍គោលនយោបាយច្បាប់ សេចក្តីប្រកាស និងវិធានការផ្សេងៗ សំរាប់ "**លើកស្ទួយតួនាទី និងសង្គមកិច្ចរបស់ស្ត្រីខ្មែរ ហើយនិងលុបបំបាត់ការជួញដូរ ការចាប់ពង្រត់ និងការកេងប្រវ័ញ្ចទៅលើស្ត្រី និងកុមារ**"។ ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រីក៏ជាយន្តការមួយសំរាប់ពិនិត្យ និងលើកជាអនុសាសន៍សំរាប់របាយការណ៍ថ្នាក់ជាតិក្នុងការប្រតិបត្តិ និងឆ្លើយតបទៅនឹងការអនុវត្តន៍អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់ នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW)។ ស្ថាប័ននេះមានសមាជិកថ្នាក់រដ្ឋលេខាធិការមកពី ១៤ ក្រសួង និងស្ថាប័ន ២ (គឺស្ថាប័នគណៈកម្មាការសិទ្ធិមនុស្ស និងគណៈកម្មាការជាតិសំរាប់កុមារ)។ ខាងផ្នែកនិតិបញ្ញត្តិមានរដ្ឋសភា និងព្រឹទ្ធសភាជាស្ថាប័នដែលមានគណៈកម្មាការសុខាភិបាលសង្គមកិច្ច ការងារ និងកិច្ចការនារី។ គណៈកម្មាការនេះ មានភារកិច្ចត្រួតពិនិត្យ និងតាក់តែងច្បាប់ទាំងឡាយដែលទាក់ទងទៅលើប្រធានបទខាងលើ។ យើងពុំមានស្ថាប័ននារីទេក្នុងប្រពន្ធ័តុលាការ។

ខាងផ្នែកសង្គមស៊ីវិល យើងមានអង្គការក្រៅរដ្ឋាភិបាលនានា ដែលបានធ្វើសកម្មភាពដើម្បីចូលរួមក្នុងការជួយស្ត្រី។ ក្នុងចំណោមអង្គការទាំងនោះយើងអាចធ្វើការបែងចែកចេញជា ២ ប្រភេទ : ទី ១ គឺអង្គការដែលធ្វើការងារខាងផ្នែកលើកតំកើងសេដ្ឋកិច្ចទី ២ គឺអង្គការដែលធ្វើការងារការពារ និងលើកស្ទួយសិទ្ធិដែលរួមទាំងសិទ្ធិចូលរួមក្នុងវិស័យនយោបាយ។ អង្គការដែលធ្វើការងារផ្នែកលើកតំកើងសេដ្ឋកិច្ចមានអង្គការធ្វើខាងផ្នែកឥណទានបង្រៀនវិជ្ជាជីវៈ អប់រំទូទៅ និងខាងផ្នែកសុខភាព ។ល។ ចំណែកអង្គការដែលធ្វើការងារទាក់ទងនឹងសិទ្ធិបានធ្វើសេវាកម្មក្នុងការឃ្លាំមើលការរំលោភ និងការពារសិទ្ធិរបស់ស្ត្រីផ្តល់សេវាគាំទ្រខាងផ្នែកច្បាប់ និងសង្គមកិច្ចដល់ស្ត្រីដែលទទួលរងគ្រោះដោយអំពើហិង្សា (គឺសំដៅទៅលើហិង្សាក្នុងគ្រួសារ ហិង្សាដោយការចាប់រំលោភ និងហិង្សាដោយការចាប់ជំរិត ការកេងប្រវ័ញ្ច និងការជួញដូរផ្លូវភេទ)។ នៅមានអង្គការមួយចំនួនតូចទៀត ដែលធ្វើការខាងការបង្កើនសមត្ថភាព និងជំរុញស្ត្រីអោយចូលរួមក្នុងផ្នែកនយោបាយទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។

ចំណែកចលនាស្ត្រី ដែលស្ថិតនៅក្នុងជួរគណបក្សនៅមានចំនួនតិចតួចនៅឡើយ ហើយការបញ្ចេញមតិយោបល់ក៏នៅមានកំរិតផងដែរ។ គេច្រើននៅជាឧបករណ៍របស់គោលនយោបាយនៃគណបក្ស ហើយពុំទាន់ជាអ្នកមានឥទ្ធិពលទៅលើគោលនយោបាយនោះនៅឡើយទេ។

ជាទូទៅយើងសង្កេតឃើញថាស្ថាប័នពុំសូវមានការសហការគ្នាល្អទេ ដោយប្រកាន់យកតែភារកិច្ចចំពោះមុខរៀង១ខ្លួនទាំងស្ថាប័នសាធារណៈ និងសង្គមស៊ីវិល។ ជាធម្មតាអង្គការដែលធ្វើការងារខាងផ្នែកសេដ្ឋកិច្ចមានការញញើតញញើមក្នុងការចូលរួមក្នុងការងារនយោបាយ។ ដោយឡែកធនធានមនុស្សនៅក្នុងសង្គមយើងនៅមានកំរិត ដោយសារស្ត្រីភាគច្រើនទើបតែចាប់ផ្តើមចូលប្រឡូកក្នុងការងារនេះទើបបានតែរយៈពេលជិត ១០ ឆ្នាំប៉ុណ្ណោះ។ អង្គការភាគច្រើនបានចាត់ចំណាត់អាទិភាពតែទៅលើការងារមនុស្សធម៌បន្ទាន់ដូចជា ចំណីអាហារ សុខភាព និងការអប់រំទូទៅ។ ប៉ុន្តែការយល់ដឹងខាងផ្នែកយេនឌ័រនិងការងារគោលនយោបាយនៅមានកំរិតនៅឡើយ។ ធនធានមនុស្សដែលជាស្ត្រីទាំងនៅស្ថាប័នរដ្ឋ និងឯកជនក៏នៅមានកំរិតដោយយើងទើបតែរៀនធ្វើការអនុវត្តន៍ការងារបច្ចេក-ទេសផ្ទាល់ក្នុងផ្នែកធ្វើផែនការ និងកម្មវិធីនានានិងពុំទាន់មានបទពិសោធន៍ច្រើនទៅលើការងារផ្នែកតស៊ូមតិគោលនយោបាយផ្សេង១ និងខ្វះពតិមាន។ ស្ថាប័នទាំងនេះ ក៏ជួបការលំបាកជាច្រើនក្នុងការស្វែងរកថវិកាមកផ្គត់ផ្គង់កម្មវិធីរបស់ខ្លួន។

ស្ត្រីខ្មែរក៏ដូចជាថ្នាក់ដឹកនាំខ្មែរដទៃទៀតគ្មានបទពិសោធន៍ និងមានជំនាញតិចតួចក្នុងការធ្វើកាងារជាក្រុម។ ការសហការរវាងគ្នា និងគ្នាពុំសូវបានរលូនល្អដោយច្រើនតែធ្វើការងារដោយឯករាជ្យតែឯង។ ឧបសគ្គមួយទៀតរបស់សង្គមយើង គឺទម្លាប់អនុវត្តការងារដោយបែងចែកទៅតាមឋានៈ បុណ្យស័ក្តិ អាយុ និងទៅតាមភេទ ដោយពុំបានអោយតំលៃទៅលើសមត្ថភាពបទពិសោធន៍ និងមានទំលាប់ធ្វើការងារតាមរបៀបបញ្ជាពីលើចុះក្រោម។ ស្ថាប័នរដ្ឋ និងសង្គមស៊ីវិលពុំទាន់បានរៀបចំជាប្រព័ន្ធ និងបទដ្ឋានត្រឹមត្រូវដើម្បីកត់ត្រានូវក្បួនខ្នាតសំរាប់អនុវត្តនៅឡើយទេ ដោយភាគច្រើនធ្វើតាមតែទំលាប់បក្សពួក ឋានៈ និងតាមមេដឹកនាំដែលមានប្រជាប្រិយភាព។ សង្គមខ្មែរដែលបានរងគ្រោះដោយការកាប់សំលាប់ និងការបំផ្លិចបំផ្លាញក្នុងរបបប៉ុលពតបានបន្សល់ទុកនូវស្នាមរបួសខាងផ្លូវចិត្ត ដែលធ្វើអោយប្រជាពលរដ្ឋខ្មែរភាគច្រើនបាក់ស្បាត និងបាត់បង់នូវទំនុកចិត្តចំពោះគ្នា ដែលបង្កអោយបែកបាក់សាមគ្គីភាពរវាងគ្នា និងគ្នាក្នុងការសហការធ្វើការងារជារួមព្រមទាំងមានគំនិតការពារខ្លួនច្រើនជាងការពារផលប្រយោជន៍រួម។ បរិបទសង្គមពុំសូវអំណោយផលដោយបរិយាកាសភ័យខ្លាចក្នុងការបញ្ចេញមតិ ដោយពុំមានការអនុវត្តន៍ច្បាប់ត្រឹមត្រូវប្រពន្ធ័អប់រំនៅខាងក្រៅនៅមានកំរិត

សង្គមជាសំភារៈនិយម គុណតំលៃពុំទាន់ច្បាស់ក្នុងនាមជាជាតិសាសន៍មួយបញ្ហាបុគ្គល និងបញ្ហារួមចែកពុំដាច់ និងបញ្ហាសីលធម៌រស់នៅក្នុងសង្គមចុះខ្សោយដែលជាមូលហេតុចំបងធ្វើអោយការចូលរួមរបស់បុគ្គល និងស្ថាប័ននានានៅមានកំរិត។ នេះជាការធម្មតានៅក្នុងសង្គមមួយដែលទើបតែឆ្លងកាត់ភ្លើងសង្គ្រាមរួច។

នៅក្នុងប្រទេសកម្ពុជាយើងចំនួនស្ត្រីមានទៅដល់ ៥២% នៃចំនួនប្រជាជនទាំងអស់ក៏ប៉ុន្តែធនធានមនុស្ស គឺស្ត្រីមានចំនួនតិចជាងបុរស ដោយសារតែឪពុកម្តាយ អាណាព្យាបាលបានបញ្ជូនតែកូនប្រុសអោយទៅរៀន ព្រោះតែពួកគាត់មានការព្រួយបារម្ភចំពោះសុវត្ថិភាពរបស់កូនស្រីក្នុងការទៅរៀននៅសាលាដែលនៅឆ្ងាយពីផ្ទះ ហើយម្យ៉ាងទៀត គាត់ចង់ទុកកូនស្រីអោយនៅផ្ទះដើម្បីជួយធ្វើកិច្ចការងារផ្ទះ ហើយបង្វែរដោះសារថា **"ស្ត្រីវិលចង្ក្រានមិនជុំ"** ដែលជាហេតុធ្វើអោយពួកគាត់មានគំនិតថា ស្ត្រីគឺមានតួនាទីតែនៅក្នុងការថែទាំផ្ទះសម្បែង ថែទាំប្តី និងកូនតែប៉ុណ្ណោះ"។ ឯបញ្ហាសង្គមខាងក្រៅ និងបញ្ហាជីវភាព គឺជាភារកិច្ចរបស់បុរសដែលទាំងអស់នេះហើយ គឺជាសំពាធដ៏ធ្ងន់ធ្ងរសំរាប់ស្ត្រីកម្ពុជាយើងសព្វថ្ងៃ ព្រោះយើងគ្មានឱកាសបញ្ចេញនូវឧត្តមគតិគំនិតយោបល់ផ្ទាល់ខ្លួន និងរកដំណោះស្រាយសំរាប់ជីវិតរបស់យើងផ្ទាល់។ បញ្ហាទាំងអស់នេះក៏បានធ្វើអោយស្ត្រីបាត់បង់នូវជំនឿចិត្ត និងភាពក្លាហានក្នុងការក្រោកឈរ ដើម្បីដោះស្រាយបញ្ហារបស់ខ្លួនផងដែរ ព្រោះតែយើងពុំបានទទួលការគាំទ្រពីសង្គមគ្រួសារ និងសង្គមខាងក្រៅ។ ចំពោះផ្នែកសុខភាពស្ត្រី និងកុមារបានប្រឈមមុខយ៉ាងធ្ងន់ធ្ងរ ដោយសារតែសេវាសុខភាពពុំទាន់មានគ្រប់គ្រាន់នៅឡើយ។ យើងសង្កេតឃើញថា អត្រាស្លាប់របស់ស្ត្រីនៅពេលឆ្លងទន្លេមានចំនួនច្រើនជាងគេនៅក្នុងតំបន់អត្រាកុមារស្លាប់ និងកុមារដែលមានភាពក្រិនដោយសារពុំមានអាហារគ្រប់គ្រាន់ក៏ច្រើនជាងគេក្នុងតំបន់ អត្រាអក្ខរនៃស្ត្រីក៏មានច្រើនជាងគេនៅក្នុងតំបន់ អត្រាស្ត្រីដែលពុំបានសិក្សាបន្តបន្ទាប់ពីបញ្ចប់មធ្យមសិក្សាក៏ច្រើនជាងគេ ហើយលើសពីនេះ អត្រាចំណូលជាមធ្យមសំរាប់គ្រួសារក៏មានកំរិតទាបជាងគេក្នុងចំណោមប្រទេសក្រីក្រផងដែរ។ ដោយប្រឈមមុខនឹងភាពក្រីក្រនេះ ហើយបានបង្ខំអោយប្រជាជនទាំងបុរស និងស្ត្រីចេញទៅធ្វើការរកស៊ីឆ្ងាយពីផ្ទះដែលជាបញ្ហាប្រឈមមុខយ៉ាងធ្ងន់ធ្ងរចំពោះការឆ្លងជំងឺអេដស៍។ គោលដៅអភិវឌ្ឍន៍សហស្សវត្សន៍កម្ពុជារបស់រាជរដ្ឋាភិបាលសព្វថ្ងៃ គឺកាត់បន្ថយភាពក្រីក្រអោយបានពាក់កណ្តាលពីចំនួន ៣៩% អោយនៅត្រឹមតែ ១៩% នៅឆ្នាំ ២០១៥ ខាងមុខនេះ។ ដូច្នេះ តើគោលដៅនេះអាចសំរេចទៅបានរឺទេ ប្រសិនបើគ្មានការចូលរួមពីស្ត្រីដែលមានចំនួន ៥២% នេះ? តើអាទិភាពក្នុងការចំណាយថវិការដ្ឋ និងលើកគំរោងកម្មវិធីអភិវឌ្ឍន៍ ដើម្បីឆ្លើយតបបញ្ហាជាក់ស្តែងតាមមូលដ្ឋាន និងផ្តល់ប្រយោជន៍ជាក់ស្តែងដល់ជីវិតយើងផ្ទាល់អាចធ្វើបានទេ បើគ្មានការទាមទារពីយើង? ជាទូទៅសង្គមនយោបាយ

បានដាក់សំពាធយ៉ាងធ្ងន់ធ្ងរចំពោះស្ត្រី ដោយយើងជាស្ត្រីត្រូវបានអប់រំអោយគិតពីអ្នកដទៃមុននឹងគិតពីខ្លួនឯងនេះ ហើយគឺជាគុណសម្បត្តិដែលធ្វើអោយស្ត្រីអាចទ្រទ្រង់គ្រួសារ និងចិញ្ចឹមកូនបាននៅពេលសង្រ្គាម។ ក៏ប៉ុន្តែនៅពេលយើងឆ្លងផុតសង្រ្គាម និងពេលដែលគ្មានសង្រ្គាមបុរសក៏អាចធ្វើបានដូចគ្នាដែរ។ យើងយល់ថា នេះជាគុណសម្បត្តិក្នុងនាមយើងជាមនុស្សរស់នៅក្នុងសង្គមមួយដែលថ្លៃថ្នូរ ហើយយើងនឹងអាចបញ្ចៀសសង្រ្គាម និងធ្វើអោយដំណើរការអភិបាលកិច្ចមានប្រសិទ្ធភាពទៅមុខជានិច្ច។ តាមការអង្កេត និងការសិក្សាស្រាវជ្រាវបន្ទាប់ពីមានការបញ្រ្ជាបយេនឌ័រទៅក្នុងសង្គមយើងឃើញថា ការបណ្តុះបណ្តាលចំណេះដឹងដល់ស្ត្រី និងបុរសក្នុងបញ្ហានេះគឺមានប្រសិទ្ធិភាពយ៉ាងឆាប់រហ័សដោយស្ថិតនៅក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ។ ដូច្នេះដើម្បីឆ្លើយតបទៅនឹងបញ្ហា និងហេតុផលទាំងប៉ុន្មានខាងលើ យើងត្រូវ :

- បង្កើតទស្សនៈវិស័យរួមទៅលើសង្គមកម្ពុជា និងតួនាទីរបស់ស្ត្រីនៅក្នុងគ្រួសារ និងសង្គមដោយបង្កើនឱកាសការងារដល់ស្ត្រី និងភាពស្និទ្ធស្នាលរវាងគ្នា និងគ្នា។
- បង្កើនការយល់ដឹងអំពីបញ្ហាយេនឌ័រទៅក្នុងអង្គការស្ថាប័នសាធារណៈ និងសង្គមស៊ីវិល និងបង្កើនសកម្មភាពបញ្រ្ជាបយេនឌ័រចូលទៅក្នុងរចនាសម្ព័ន្ធយន្តការផ្សេងៗទាំងក្នុងស្ថាប័នសាធារណៈ និងសង្គមស៊ីវិល។
- បង្កើនសមត្ថភាពក្នុងការរៀបចំចាត់ចែងធនធានមនុស្ស និងស្ថាប័ន។
- រួមគ្នារៀបចំលើកគំរោងដែលយើងចាប់អារម្មណ៍រួមក្នុងការស្វែងយល់ពីសង្គម និងការស្វែងរកចំណេះដឹងក្នុងការអភិវឌ្ឍន៍ និងក្នុងការអភិបាលកិច្ច ។
- បង្កើនឱកាសជួបជុំគ្នាដើម្បីចែករំលែកពត៌មានដោះស្រាយបញ្ហារួម និងជួយគ្នាទៅវិញទៅមក។
- ស្រាវជ្រាវ និងលើកតំកើងវីរភាពនារីក្នុងប្រវត្តិសាស្ត្រខ្មែរដើម្បីទុកជាគំរូដល់ស្ត្រីជំនាន់ក្រោយ និងរៀបចំទិវារំលឹកគុណ និងលើកកំពស់វីរភាពរបស់ស្ត្រី។
- រួមគ្នាតស៊ូមតិដើម្បីធ្វើអោយមានការកែប្រែទូវប្រព័ន្ធបោះឆ្នោតបច្ចុប្បន្នដែលផ្តល់ឱកាសតិចតួចដល់ស្ត្រី ។
- រៀបចំជាសេវាគាំទ្រដល់ស្ត្រីដែលមានបំណង និងសមត្ថភាពចូលរួមក្នុងឆាកនយោ-បាយ ។
- លើកកំពស់ស្នាដៃរបស់ស្ត្រីក្នុងឆាកនយោបាយ ដែលបានបញ្ចេញនូវស្នាដៃពិតប្រាកដដល់ប្រជាជនមូលដ្ឋានរបស់គាត់។
- ផ្តល់ពត៌មានអោយបានទូលំទូលាយ និងចុះផ្ទាល់ដល់មូលដ្ឋាន និងពង្រឹងសមត្ថភាពថ្នាក់ដឹកនាំស្ត្រីតាមមូលដ្ឋាន ។

យើងមិនអាចសំរេចការងារខាងលើជូនសង្គមយើងដោយមិនមានការចងក្រង និងធ្វើការរួមគ្នានោះទេ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា នៅថ្ងៃអនាគតសង្គមកម្ពុជានឹងផ្តល់ឱកាសកាន់តែច្រើនដល់ស្ត្រីក្នុងការចូលរួមរៀនសូត្រ ដោយមាន

សមាមាត្រជាមួយនឹងបុរសដើម្បីពង្រឹងសមត្ថភាព និងស្មារតីរបស់ស្ត្រីក្នុងការចូលប្រឡូកក្នុង វិស័យនយោបាយក៏ដូចជាវិស័យផ្សេងៗទៀត នៅក្នុងជួររដ្ឋាភិបាល និងសង្គមយើង។

ខ្ញុំមានជំនឿចិត្តថា នៅពេលដែលស្ត្រីមានឱកាសច្រើនក្នុងការចូលប្រឡូកនៅក្នុងសង្គម និងសំរាលការងារបុរស ដែលជារូមបានក្លាយជាចលករដ៏សំខាន់ក្នុងការរុញច្រានអោយប្រទេសយើងមានសន្តិភាព និងអភិវឌ្ឍន៍ប្រកបដោយចិរភាព។ ខ្ញុំជឿថា អង្គវេទិកាយើងនឹងផ្តល់នូវអនុសាសន៍បន្ថែមក្នុងជំហានជាក់ស្តែងដែលយើងអាចធ្វើរួមគ្នាដើម្បីលើកស្ទួយតួនាទីរបស់ស្ត្រីកម្ពុជាក្នុងមូលហេតុរួមសំរាប់សង្គមយើង និងមាតុប្រទេសរបស់យើង។

សូមអរគុណ !

ថ្លែងដោយ : អ្នកស្រី រស់ សុភាព នាយិកាប្រតិបត្តិ អង្គការ យេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C)

សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញាទាំងអស់ជាទីគោរព និងជាទីរាប់អាន ។

ខ្ញុំមានកិត្តិយសដោយមានឱកាសចូលរួមមានមតិដែលទាក់ទងទៅនឹង បញ្ហាយេនឌ័រ និងវិមជ្ឈការក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី ១ ស្ដីពីការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងប្រសិទ្ធិភាពនៅថ្នាក់ឃុំ-សង្កាត់ ក្នុងប្រទេស ។

ថ្ងៃនេះខ្ញុំនឹងដកស្រង់ប្រវត្តិជោគជ័យខ្លះៗរបស់ក្រុមប្រឹក្សាស្ត្រីនៅរដ្ឋបាលមូលដ្ឋាន ប្រទេសឥណ្ឌា (ប៉ាន់ឆាយ៉ាតរ៉ាច) ដែលនិយាយអំពីស្ត្រីចំនួន 330.000នាក់ ដែលបានចូលប្រឡូកក្នុងឆាកនយោបាយផ្លូវការ (មានន័យថាស្ត្រីដែលជាក្រុមប្រឹក្សាត្រូវបានជាប់ឆ្នោត) ហើយចំនួនស្ត្រីនេះនឹងកើនឡើងដល់ទៅជាង ១លាននាក់ក្នុងពេលដ៏ឆាប់នេះ ។

ប្រវត្តិនេះចាប់ផ្ដើមដោយច្បាប់មួយដែលបានអនុម័តក្នុងឆ្នាំ 1983 នៅក្នុងរដ្ឋកាណាតាកាភាគខាងត្បូងនៃប្រទេសឥណ្ឌា ។ ច្បាប់នេះរួមមាន " **ខ** " មួយដែលចែងថា អាសនៈចំនួន 25% នៅក្នុងក្រុមប្រឹក្សានឹងត្រូវរក្សាទុកឱ្យស្ត្រី ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះត្រូវបានប្រព្រឹត្តឡើងនៅឆ្នាំ 1987 ។ នៅថ្ងៃ ទី1 ខែ ឧសភា ឆ្នាំ1987 គណបក្សចាណាតាដាល់ (គណបក្សដែលបានឈ្នះឆ្នោត) បានអំពាវនាវឱ្យមានអនុសញ្ញាស្ដីពីអ្នកតំណាងដែលបានជ្រើសរើសទាំង 56.000 នាក់នោះត្រូវអោយមានស្ត្រីចំនួន 25% ។ វាជាទិដ្ឋភាពដ៏អស្ចារ្យមួយដែលមានស្ត្រីចំនួន 14.000នាក់ បានចូលរួមជាតំណាងអោយស្ត្រី ។ នេះវាបានបង្ហាញនូវភាពដ៏រុងរឿងរបស់ស្ត្រីឥណ្ឌាទាំងអស់នៅក្នុងប្រទេសឥណ្ឌាព្រោះពេលនោះគេមានស្ត្រីចំនួន 80% បានចូលប្រឡូកក្នុងឆាកនយោបាយជាលើកដំបូងដែលធ្វើអោយពួកគេមានសេចក្ដីរំភើបនឹងជោគជ័យរបស់គេយ៉ាងខ្លាំង ។

ក្នុងកំឡុងឆ្នាំ 1995 វត្តមានរបស់ស្ត្រីក្នុងជួររដ្ឋាភិបាលបានកើនឡើងជាច្រើនដោយសារប្រទេសជាតិទាំងមូលធ្វើការផ្លាស់ប្ដូរនយោបាយ ឬ ផ្នែករដ្ឋបាលដើម្បីរក្សាទុកអាសនៈនៅក្នុងក្រុមប្រឹក្សាឱ្យស្ត្រីតាមរយៈវិសោធនកម្មរដ្ឋធម្មនុញ្ញ លើកទី 73 និងទី 74 ។ នៅប្រទេសឥណ្ឌាគេហៅប្រព័ន្ធនេះថា ជាប្រព័ន្ធស្ថាប័ន **ប៉ាន់ឆាយ៉ាតរ៉ាច** (PRI) ក្នុងនាមជាសមាជិករដ្ឋាភិបាលមូលដ្ឋានដែលបានបោះឆ្នោតជាប់ឆ្នោតអំណាចរបស់ស្ត្រីទាំងនោះ (ស្ត្រីជាសមាជិករដ្ឋាភិបាលមូលដ្ឋាន) រួមមានអំណាចក្នុងការធ្វើ

ការសំរេចទាំងផ្នែកទិសដៅអភិវឌ្ឍន៍នៅក្នុងតំបន់ និងអំណាចក្នុងការគ្រប់គ្រង និងត្រួតពិនិត្យតាមដានមើលរាល់ការអនុវត្តន៍ទាំងនោះ ។

**ប្រព័ន្ធស្ថាប័នប៉ាន់ឆាយ៉ាតរ៉ាច**

ការបែងចែកការងារជាវិជ្ជមាននៃប្រព័ន្ធស្ថាប័ន **ប៉ាន់ឆាយ៉ាតរ៉ាច** បានបង្កើតឱ្យមានសន្ទុះផ្លាស់ប្តូរ ។ ការចូលប្រឡូកក្នុងរដ្ឋាភិបាលរបស់ស្ត្រីក្នុងចំនួនដ៏ធំបែបនេះជាញឹកញាប់បានកើនឡើងលើសពីតំរូវការ 33.3% ព្រមទាំងភាពជោគជ័យរបស់ពួកគេនៅក្នុងយុទ្ធនាការ ដូចជាភាពជោគ-ជ័យលើបេក្ខជនបានធ្វើឱ្យមានការផ្លាស់ប្តូរលើផ្នត់គំនិតដែលគិតថា ស្ត្រីមិនចាប់អារម្មណ៍ផ្នែកនយោបាយ និងគ្មានពេលវេលាដើម្បីចូលរួមប្រជុំ ឬ បំពេញកិច្ចការទាំងឡាយសំរាប់ដំណើរការគណបក្សនយោបាយ ។ មានភស្តុតាងដែលបង្ហាញថា ស្ត្រីនឹងមិនបានចូលរួមក្នុងក្រុមប្រឹក្សាទាំងនេះក្នុងចំនួនដ៏ច្រើនបែបនេះទេ បើសិនជាមិនមែនដើម្បីហេតុផលអាណត្តិរដ្ឋធម្មនុញ្ញទេនោះ ។ នេះគឺជាសំពាធរបស់ច្បាប់ជាតិ រួមផ្សំជាមួយនឹងភាពចាំបាច់ផ្នែកនយោបាយក្នុងការឈ្នះឆ្នោតដែលបានផ្លាស់ប្តូរទស្សនៈគណបក្សនយោបាយ អំពីសមត្ថភាពរបស់ស្ត្រីនៅមានកំរិតសំរាប់ការិយា-ល័យសាធារណៈ ។

ជាការពិតណាស់ថា ប្រវត្តិដ៏សំខាន់នៃការផ្លាស់ប្តូរដែលខ្ញុំកំពុងអធិប្បាយនេះមានភាពស្មុគស្មាញយ៉ាងខ្លាំង ។ ការកំណត់បទបញ្ញត្តិដែលកំណត់លើការរក្សាអាសនៈទុកឱ្យស្ត្រីមិនមែនជាលទ្ធផលពីយុទ្ធនាការដែលមានសារៈសំខាន់ណាមួយដោយចលនារបស់ស្ត្រី ឬ ដោយភាពដឹកនាំយល់ដឹងអំពីយេនឌ័រមិនធម្មតាណាមួយរបស់គណបក្សនយោបាយនោះទេ ។ វាអាចមានសំពាធខ្លះៗ ពីភាគីស្ត្រីរបស់គណបក្សចាណាតាដាល់ដែលមានប្រវត្តិអំពីការទាមទារតំណែងជាច្រើនសំរាប់ស្ត្រីនៅក្នុងការបែងចែកធម្មនុញ្ញភាពសំរាប់សភាមជ្ឈិម ។ ប្រព័ន្ធស្ថាប័ន **ប៉ាន់ឆាយ៉ាតរ៉ាច** បានសង្កត់ធ្ងន់ទៅលើចំណុចប្រសព្វរវាងផល-ប្រយោជន៍យេនឌ័រ និងឋានៈនៅក្នុងសង្គមដោយសារការរក្សាទុកអាសនៈរបស់ខ្លួនអោយស្ត្រី ។ នេះហើយដែលអាចបង្កលក្ខណៈឱ្យស្ត្រីដែលក្រីក្រ និងទន់ខ្សោយមានលទ្ធភាពបង្ហាញពីមនសិកានយោបាយដ៏ជ្រាលជ្រៅរបស់ពួកគេ និងផលប្រយោជន៍ក្នុងការទទួលបានអំណាច ។ សំរាប់ពួកគេនយោបាយ និងការបោះឆ្នោតគឺជាមាគ៌ាគន្លឹះមួយដែលមានប្រយោជន៍ក្នុងការជៀសផុតពីភាពក្រីក្រ និងជាមធ្យោបាយសំខាន់សំរាប់ការផ្លាស់ប្តូរសង្គម ។

**តើក្រុមប្រឹក្សាស្ត្រីទាំងនេះជានរណា?**

- ស្ត្រីដែលត្រូវបានជ្រើសរើសភាគច្រើនជាអនក្ខរជន (បុរសចំនួន 20%ដែលទទួលបានការអប់រំ និងជំនាញបើប្រៀបធៀបទៅនឹងស្ត្រីមានតែ 5%) ។

- ស្ត្រីភាគច្រើនបានប្រកាសខ្លួនថា ជាមេផ្ទះប៉ុន្តែយើងដឹងថាពាក្យនេះមានន័យទូលំទូលាយណាស់ ព្រោះពួកគេរ៉ាប់រងក្នុងគ្រួសារទាំងស្រុងរួមទាំងការទទួលខុសត្រូវ ដូចជាការរកប្រាក់ចំណូលសំរាប់ផ្គត់ផ្គង់ជីវភាពគ្រួសារទៀតផង ។

- មានស្ត្រីចំនួនតែ 20% ប៉ុណ្ណោះដែលមានបទពិសោធន៍ខាងនយោបាយពីមុនមកបើ

ប្រៀបធៀបទៅនឹងបុរសមានចំនួន 80% ។

**ប្រវត្តិជោគជ័យក្រុមប្រឹក្សាស្ត្រីឈ្មោះនៅប៉ាន់ឆាយ៉ាតវ៉ាច**

បទពិសោធន៍ពីប្រព័ន្ធស្ថាប័ន **ប៉ាន់ឆាយ៉ាតវ៉ាច** បានធ្វើឱ្យស្ត្រីមានការប្រែប្រួលយ៉ាងច្រើន ។ កត្តាប្រែប្រួលនេះ រួមមានអំណាចភាពជឿជាក់ខ្លួនឯង ការយល់ដឹងពីនយោបាយ និងហ៊ានធ្វើការអះអាងលើអត្តសញ្ញាណអ្វីមួយ ។ ស្ត្រីបានដឹងថា អំណាចដែលពួកគេបានទទួលនោះគឺជាអំណាចដែលគេអាចគ្រប់គ្រងលើធនធានមន្ត្រី (បុគ្គលិកនៅការិយាល័យឃុំដូចជាស្មៀនឃុំជាដើម) និងភាគច្រើនបំផុតនោះ គឺដោយការប្រឈមមុខជាមួយបុរស (ចេនឆ្នាំ 1980 អានវើសស៊ីឆ្នាំ 1993) ។ បុរស និងទំលាប់របស់ពួកគេដែលស្ថិតនៅក្រៅរង្វង់នៃឥទ្ធិពលរបស់ស្ត្រីហាក់ ដូចជាមានកង្វល់យ៉ាងខ្លាំងអំពីស្ត្រីដែលត្រូវបានជាប់សន្លឹកឆ្នោត ។

**ដកស្រង់សំដីសមាជិកក្រុមប្រឹក្សាស្ត្រីម្នាក់ (១៩៩៥):**

**"ប្រសិនបើយើងនិយាយឥតសំចៃពួកគេប្រុសៗបាននិយាយអំពីយើងជាចំហថា យើងគ្មានការខ្មាស់អៀន ។ ប៉ុន្តែឥឡូវនេះយើងមិនខ្វល់ទេ ពីព្រោះយើងដឹងថា យើងអាចចូលរួមជាមួយអ្នកដែលត្រូវស្តាប់យើង ។ ថ្ងៃដែលយើងមានអង្គប្រជុំប្រែ្ហមប៉ាន់ឆាយ៉ាតបុរសៗ និងអ្នកនៅផ្ទះបានលើចចំអកឱ្យយើង ។ ពេលនោះយើងបានយកសៀវភៅកត់ត្រាចេញហើយបង្ហាញដល់ពួកគេនូវអ្វីដែលយើងបានដឹង "** ។

ការផ្តល់អំណាចរបស់ស្ត្រីក៏ជាការប្រឈមមុខមួយ និងផ្ទុតគំនិតបុរាណចាស់គំរិលអំពីអំណាច និងឧត្តមភាពរបស់បុរសព្រមទាំងភាពជឿជាក់លើខ្លួនឯង ដែលបុរសទទួលបានតាមរយៈអង្គការក្នុងតំបន់ដែលបានធ្វើឱ្យពួកគេជៀសផុតពីទំនាក់ទំនងវិសមភាព ។

**"ការអប់រំមិនមែនជាបញ្ហាចំបងទេនៅទីនេះ ។ វាគឺជាភាពក្លាហាន និងការតាំងចិត្តដែលស្ត្រីមានយ៉ាងលើសលប់ "**

ម្យ៉ាងទៀតការប្រឡូកក្នុងនយោបាយរបស់ស្ត្រីមួយចំនួននៅក្នុងប្រព័ន្ធស្ថាប័ន**ប៉ាន់ឆាយ៉ាតវ៉ាច** បានជួយពួកគេក្នុងការយល់ច្បាស់អំពីអត្ត សញ្ញាណរបស់គេថាជាស្ត្រីដែលមានបទពិសោធន៍ជាក់លាក់ និងបានរួមចំណែកក្នុងការចែករំលែកបទពិសោធន៍នោះអោយគ្នាទៅវិញទៅមក ។ ស្ត្រីម្នាក់នៅអង្គប្រជុំ **ប៉ាន់ឆាយ៉ាត** ក្នុង **កាណាតាកា** បាននិយាយថា : **"ពេលពួកយើងជួបគ្នា ពួកយើងធ្វើការរួមគ្នា ក្នុងនាមជាស្ត្រីសំរាប់ក្រុមរបស់យើង ។ ពួកយើងមិនចាប់អារម្មណ៍ច្រើនទេ អំពី អត្តសញ្ញាណគណបក្ស របស់ពួកយើង"** ។

បុរសគិតថា អ្នកនយោបាយថ្មីទាំងនេះគឺជាស្ត្រីមិនមែនជាមិត្តរួមគណបក្សឡើយ ។ នយោបាយគណបក្សដែលជាលក្ខខ័ណ្ឌចាំបាច់សំរាប់ប្រជាធិបតេយ្យបុរាណ គឺមានលក្ខណៈប្រកួតប្រជែង ប៉ុន្តែស្ត្រីនាំមកនូវក្រមសីលធម៌មួយដែលមានលក្ខណៈសហការ ឬ មិនប្រកួតប្រជែងក្នុងពេលដែលពួកគេបានធ្វើការរួមគ្នាក្នុងជួរគណបក្ស ហើយព្រមទាំងមានផលប្រយោជន៍ដូចគ្នា ។ យេនឌ័រអាចជំនួសវណ្ណៈ និងជួរគណបក្ស ។ ស្ត្រីបានបើកជំរុញលទ្ធភាពសំរាប់

នយោបាយមិនត្រឹមតែដើម្បីមានមុខមាត់ថ្មីប៉ុណ្ណោះទេ ថែមទាំងមានគុណភាពថ្មី ផងដែរ។

មធ្យោបាយមួយចំនួនដែលស្ត្រីកំពុងតែធ្វើការផ្លាស់ប្តូរអភិបាលកិច្ចតាមរយៈប្រព័ន្ធ ស្ថាប័ន **ប៉ាន់ឆាយ៉ាត** គឺបានស្តែងចេញនៅក្នុងបញ្ហាទាំងឡាយដែលពួកគេជ្រើសរើសក្នុងការដោះស្រាយទឹក ការប្រើប្រាស់ជាតិស្រវឹង ការអប់រំសុខភាព និងអំពីហិង្សាក្នុងគ្រួសារ។ **ឧទាហរណ៍:** ស្ត្រីចំនួន 40 ក្រុមនៅក្នុងតំបន់សុនបាដ្រា(**រ៉ាជាស្ថានប្រាដែស**) បានអនុវត្តយ៉ាត្រាជាប្រព័ន្ធ ឬ ក្បួនព្យុះហយាត្រាទៅលើភូមិចំនួន 10។ សំរាប់ក្បួននីមួយៗ ឬ ចំនួន 400 ភូមិក្បួនទាំងអស់មានភារកិច្ចពន្យល់ពីលក្ខណៈសំខាន់នៃវិសោធនកម្មលើកទី 73 និងកន្លែងឱ្យស្ត្រី។ ការពិភាក្សានៅយ៉ាត្រាក្នុងពេលនោះ ស្ត្រីបានយល់ច្បាស់ពីអាទិភាពរបស់ពួកគេ។ សំរាប់ស្ត្រីចំនួនជិត 90% គិតថាបញ្ហាលំបាកជាងគេគឺទឹក ដូច្នេះ ការដោះស្រាយទឹក គឺជាអាទិភាពខ្ពស់បំផុតសំរាប់ពួកគេ។ ពួកគេសង្កត់ធ្ងន់ថា គេត្រូវការទឹកស្អាតសំរាប់ស្រែចំការសំរាប់គោ-ក្របី និងសំរាប់គ្រួសាររបស់ពួកគេ។ ពួកគេនិយាយថា គេមិនអាចទ្រាំទ្រនឹងការរស់នៅបានទេ បើគ្មានទឹកសំរាប់ការដាំដំណាំ និងគ្មានការអភិវឌ្ឍន៍ធនធានទឹកសំរាប់តំបន់គេនោះ។ ទោះបីពួកគេតាំងចិត្តរារាំងមិនអោយទឹកហូរចេញពីតំបន់របស់ពួកគេក៏ដោយ ក៏ពួកគេរួមគ្នាសំរេចថានឹងបង្ការទប់ស្កាត់នូវការហូរចូលជាតិស្រវឹងទៅក្នុងតំបន់របស់ពួកគេ។ ពួកគេបានបញ្ឈប់ល្បែងស៊ីសងរបស់ពួករគ ហើយបានមកធ្វើការទប់ទល់នឹងគ្រឿងស្រវឹងក្នុងតំបន់គេទៀត។ គោលនយោបាយមួយដែលគេបានអនុម័ត និងព្រមព្រៀងគ្នាដើម្បីអភិវឌ្ឍន៍នោះគឺ **"បិទទ្វារកុំអោយប្តី ដែលស្រវឹងចូលផ្ទះ"**។

**"យើងនឹងមិនទ្រាំទៅទេ។ នៅពេលយើងទទួលបានឋានៈអំណាចយើងនឹងប្រយុទ្ធ។ ហើយយើងបានដឹងថា វាមិនមែនងាយស្រួលទេ ចំពោះបញ្ហានេះ ពីព្រោះសង្គ្រាមនេះនឹងត្រូវកើតឡើងនៅគ្រប់ផ្ទះ។ ប៉ុន្តែ ដោយសារធាតុពិតប៉ាន់ឆាយ៉ាតស្នើឱ្យមានចំនួនស្ត្រីជាអប្បបរមានោះ យើងនឹងប្រើភាពរឹងមាំនេះ ដើម្បីប្រើប្រាស់ចលនាស្ត្រីឱ្យបានទូលំទូលាយ និងឈានទៅបំបាត់ជាតិស្រវឹងចេញពីបញ្ជីអាទិភាពរបស់យើង"**។

ស្ត្រីកំពុងតែខិតជិតទៅរកធម្មនុញ្ញភាពរបស់ពួកគេ។ ស្ត្រីក្រីក្រត្រូវតែឈានទៅឱ្យដល់ភាពងាយស្រួល ហើយដើម្បីទៅអោយដល់នោះស្ត្រីត្រូវចំណាយពេលវេលាដ៏មានតំលៃនោះយ៉ាងយូរ។ ម្យ៉ាងទៀត នៅពេលប្រឆាំងនឹងការចាប់រំលោភសេពសន្ថវៈ និងអំពើហិង្សាផ្សេងទៀតប្រឆាំងស្ត្រី ដូចជា វាយដំ ការយកភ្លើងមកដុត។ល។ ដែលកើតឡើងចំពោះស្ត្រីនោះ វាពិតជាមានការលំបាកខ្លាំងណាស់ ក្នុងការស្វែងរកជំនួយ និងដំណោះស្រាយចំពោះអ្នកដែលរស់នៅឆ្ងាយពីក្រុមប្រឹក្សា ហើយពេលខ្លះប្រហែលជាមិនអាចទៅរួចផង។ ប៉ុន្តែ បើសិនជាក្រុមប្រឹក្សាទាំងនោះ និងសមាជិកនៅជិតគ្នាឱកាសក្នុងការជួយ និងការរកយុទ្ធសាស្ត្រសំរាប់ដោះស្រាយបញ្ហាទាំងនោះ និងមានប្រសិទ្ធិភាពច្រើន។

**ឧបសគ្គរួម**

មានឧបសគ្គជាច្រើនក្នុងការបំពេញឱ្យបាន

សំរេចនូវសក្ដានុពលការកែប្រែប្រព័ន្ធស្ថាប័ន **ប៉ាន់ឆាយ៉ាតវ៉ាច** ។ មានភាពសង្ស័យជាច្រើនអំពីវិមជ្ឈការ ។ ហើយនៅតែមានការប្រឆាំងទៅនឹងអំណាចផ្ទេរពិតប្រាកដ និងមូលនិធិពីមជ្ឈដ្ឋានកណ្ដាលនៃអំណាចទៅបរិមណ្ឌល ។ ស្ត្រីនៅតែប្រឈមមុខនឹងភាពងងឹតងងល់ចំពោះការចូលរួមនៅក្នុងនយោបាយរបស់ពួកគេ **ឧទាហរណ៍៖** ការអប់រំមិនគ្រប់គ្រាន់បន្ទុកលើតួនាទីគ្រួសារប្រាក់ចំណូលកង្វះការជឿជាក់លើខ្លួនឯង និងការប្រឆាំងនឹងទស្សនៈសាសនា និងវប្បធម៌ដែលកប់ជ្រៅ ។ នៅមានឧបសគ្គខាងផ្នែករដ្ឋបាលដែលត្រូវពុះពារផងដែរ ។ ក្របខ័ណ្ឌរដ្ឋបាលបច្ចុប្បន្នមានទំរង់ជាការផ្ដល់ឱ្យផ្នែកមូលនិធិដែលជាទំនាស់នឹងកម្មវិធីតាមតំបន់ ដែលដឹកនាំដោយស្ត្រីកម្មវិធីនេះកើតចេញពីប្រព័ន្ធស្ថាប័ន**ប៉ាន់ឆាយ៉ាតវ៉ាច** ។

**ស្ត្រី និង ការគាំទ្រស្ត្រី**

ក្រុមប្រឹក្សាស្ត្រីនៅប៉ាន់ឆាយ៉ាតបានស្នើឱ្យមានការគាំទ្រជាក់លាក់ដែលក្នុងនោះ គឺការបណ្ដុះបណ្ដាលបច្ចេកទេស ។ យើងត្រូវការការគាំទ្រដើម្បីបង្កើនសាមគ្គីភាពក្នុងចំណោមស្ត្រីតាមរយៈពង្រឹងសម្ព័ន្ធភាពរវាងអង្គការស្ត្រី និងស្ថាប័នដែលបានបោះឆ្នោតជ្រើសរើស ។ យើងត្រូវការពតិមានពីអង្គការដែលមានគំនិតច្នៃប្រឌិតខ្ពស់ដែលអាចជួយលើកស្ទួយជីវភាពរបស់ស្ត្រី ដូចជាអ្នកផ្ដល់សេវាខាងសុខភាពស្ថាប័នឥណទាន ។ល ។ អង្គការក្រៅរដ្ឋាភិបាលសំរាប់ស្ត្រីភាគច្រើនកំពុងតែផ្ដល់ការគាំទ្របែបនេះ រួចហើយដល់តំណាងស្ត្រី ។

ទោះបីជាយ៉ាងណាក៏ដោយនៅមានគំលាតចំបងមួយនៅក្នុងការគាំទ្រស្ត្រី និងស្ត្រីគ្នាឯងដែលទាមទារឱ្យមានការយកចិត្តទុកដាក់ពីចលនាសំរាប់ស្ត្រីឥណ្ឌា និងក្រុមស្ត្រីនៅក្នុងតំបន់ ។ ផ្នែកជាច្រើននៃចលនានេះដើមដំបូងមានការសង្ស័យ អំពីតំលៃពិតនៃ "**ប៉ាន់ឆាយ៉ាត និងប្រព័ន្ធស្ថាប័នប៉ាន់ឆាយ៉ាតវ៉ាច**" នេះ ។ ប៉ុន្តែពេលដែលពួកគេកាន់តែស្និទ្ធស្នាលជាមួយគ្នាព្រោះពេលដែលស្ត្រីត្រូវបានបោះឆ្នោតជ្រើសតាំងពួកគេរំភើបដោយភាពក្លៀវក្លា និងសេចក្ដីសាទររបស់ស្ត្រី ហើយឥឡូវនេះពួកគេកំពុងតែផ្ដល់ការគាំទ្រទាំងផ្នែកសីលធម៌ និងសម្ភារៈ ។ ដំណើរការនេះមានសារៈសំខាន់ណាស់ ហើយត្រូវតែបន្ត និងជំរុញបន្ថែមទៀត ។

**ឧទាហរណ៍នៃការគាំទ្រចលនារបស់ស្ត្រី**

- ជួយសំរួលការប្រជុំរបស់ពួកគេតាមបណ្ដាស្រុក ។
- ធានាថាស្ត្រីគ្មានភាពទន់ខ្សោយក្នុងរចនាសម្ព័ន្ធគណៈកម្មាធិការចំណូល និងចំណាយដែលត្រូវបង្កើតឡើងដើម្បីគ្រប់គ្រងការអភិវឌ្ឍន៍នៅក្នុងស្ថាបន័ទាំងនេះ ។
- ធានាទៅលើការផ្ទេរអំណាចលើការលើកគំរោង និងការត្រួតពិនិត្យអំណាចពីរដ្ឋាភិបាលថ្នាក់កណ្ដាលដល់ស្ថាប័ន ឬ អ្នកដែលបានជ្រើសតាំង ។
- ពង្រឹងអត្តសញ្ញាណ និងការយល់ដឹងអំពីការតំលើងឋានៈអោយដល់តំណាងស្ត្រី **ឧទាហរណ៍** តាមរយៈការបណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំ ។
- ដឹកនាំស្ត្រីឱ្យចូលក្នុងរចនាសម្ព័ន្ធនយោបាយ

និងគាំទ្រសម្ព័ន្ធភាពខាងមុខ និងខាងក្រោយនៃវត្តមានស្ត្រីនៅក្នុងផ្នែកនយោបាយដោយផ្សារភ្ជាប់គ្រួសារ និងអាទិភាពគ្រួសារជាមួយនឹងដំណើរការធ្វើផែនការម៉ាក្រូ។

**សាររសំខាន់ចុងក្រោយ**

ការស្វែងរកសមភាពមិនអាចនឹងឈានដល់ទេ បើគ្មានតំណាងដ៏ទូលំទូលាយពីក្រុមទាំងអស់ ពិសេសចំពោះស្ត្រីដែលបច្ចុប្បន្ននេះ កំពុងតែឈានទៅរកការអនុវត្តន៍ផ្ទាល់ ដើម្បីប្រើអំណាចរបស់ខ្លួនដែលក្នុងនោះរួមទាំងដំណើការក្នុងការធ្វើការសំរេចចិត្តទៀតផងនោះ។

ប្រវត្តិរបស់ឥណ្ឌាអាចធ្វើអោយយើងនឹកឃើញ អំពីការពិតដែលជាចំនុចកណ្តាលមួយ (ចំនុចដែលមានលក្ខណៈមួយដូចគ្នា ឬ ស្រដៀងគ្នាដែលបញ្ហានេះវាកើតមានឡើងចំពោះស្ត្រី) អំណាចមិនមែនជាអ្វីមួយដែលគេនឹងប្រគល់អោយបោះបង់ចោលងាយៗនោះទេ។ វាត្រូវតែធ្វើការចរចារ។ មេរៀនរបស់ស្ថាប័ន**ប៉ាន់ឆាយ៉ាត់រ៉ាច** មានភាពច្បាស់លាស់ បើសិនជាយើងមានគំនិតចង់អោយមានស្រីជាក្រុមប្រឹក្សានៅមូលដ្ឋាន ពិសេសសេចក្តីក្លាហាន និងការទាមទារច្បាស់លាស់នូវអ្វីដែលយើងចង់បាននោះ ស្ត្រីត្រូវប្រែក្លាយអោយទៅជាគោលការណ៍នយោបាយនៅថ្នាក់រដ្ឋាភិបាលមូលដ្ឋាន។ ហើយយើងចាំបាច់ត្រូវរួបរួមគ្នា និងទាមទារច្បាស់លាស់សំរាប់សំលេងគាំទ្ររបស់ពួកយើង ដើម្បីទទួលបានអំណាច។

**ប្រវត្តិឯកសារ**


Jain, Devaki. 1996.PanchaytRaj:

Women

Changing governance. Jain, L.C. 1994.

" Panchayats : Women Will

Win " , inKurukshetra

Narayanan , IDS Bulltin , No121 ,

Brighton.

Revathi.1993. "Women in

Panchayati Raj:

Experiences from Karnataka", in

Search Newsletter, Bangalore.


**កំណត់សំគាល់:** សំដីដកស្រង់ទាំងអស់ក្នុងឯកសារនេះ ត្រូវបានស្រង់ចេញពីសារពត៌មានស្តីអំពី **"ស្ត្រីផ្លាស់ប្តូរអភិបាលកិច្ចល្អ"**

ការបង្ហាញជូនខាងលើនេះគឺជាសេចក្តីសង្ខេបនៃសារពត៌មានដែលសរសេរដោយ លោក **ទេវ ដេវ៉ាគី** ដែលជាអ្នកនិពន្ធដ៏ល្បីឈ្មោះ និងជាសកម្មជនគាំទ្រស្ត្រីនៅប្រទេសឥណ្ឌា។

## កូតាជាអ្វី?

គំនិតស្នូលនៅខាងក្រោយប្រព័ន្ធកូតា គឺដើម្បីជ្រើសរើសស្ត្រីអោយចូលក្នុងតួនាទីនយោបាយ និងដើម្បីធានាថា ស្ត្រីមិនត្រូវបានដាក់អោយនៅដាច់ដោយឡែកក្នុងឆាកនយោបាយឡើយ ។

កូតាសំរាប់ស្ត្រីតំរូវថា ស្ត្រីត្រូវមានចំនួន ឬភាគរយជាក់លាក់នៅក្នុងស្ថាប័នមួយ ដូចជាក្នុងបញ្ជីឈ្មោះបេក្ខជនរដ្ឋសភាគណៈកម្មាធិការ ឬរដ្ឋាភិបាល ។ ប្រព័ន្ធកូតាដាក់បន្ទុកនៃការជ្រើសរើសមិនមែនតែទៅលើស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែទៅលើអ្នកដែលគ្រប់គ្រងដំណើរការជ្រើសរើសទាំងអស់ ។ គំនិតស្នូលនៅខាងក្រោយប្រព័ន្ធកូតា គឺដើម្បីជ្រើសរើសស្ត្រីអោយចូលបំរើការក្នុងការងារនយោបាយ និងដើម្បីធានាថា ស្ត្រីមិនត្រូវបានដាក់អោយនៅដាច់ដោយឡែកក្នុងឆាកនយោបាយឡើយ ។

កូតាភាគច្រើនមានគោលដៅបង្កើនតំណាងរបស់ស្ត្រី ពីព្រោះបញ្ហាដែលត្រូវដោះស្រាយ ជាទូទៅនោះតំណាងរបស់ស្ត្រីនៅមានកំរិតទាប ។ នេះក៏ជាបញ្ហាដែលមានដូចគ្នាផងដែរ ដែលនៅក្នុងបណ្តាប្រទេសភាគច្រើនមានអំពីចំនួនប្រជាពលរដ្ឋជាស្ត្រី 50% ។

ប្រព័ន្ធកូតាអាចត្រូវបានបង្កើតជាលក្ខណៈអព្យាក្រិត្យខាងយេនឌ័រដែលមានន័យថា ប្រព័ន្ធទាំងនេះមានគោលដៅកែតំរូវកំរិតនៃតំណាងអោយស្ត្រី និងបុរស ។ នៅក្នុងករណីនេះលក្ខខ័ណ្ឌអាចនឹងតំរូវអោយចំនួនស្ត្រី និងបុរសមាន 40% នៃសមាជិកនៃគណៈកម្មាធិការ ឬ មិនតំរូវអោយភេទណាមួយមានចំនួនលើសពី 60% ឬ តិចជាង 40% ទេ ។

មានវិធីសាស្ត្រកូតាជាច្រើនដើម្បីធានាថា ស្ត្រីមានតំណាងរបស់ខ្លួននៅក្នុងរដ្ឋសភា ។ ប្រព័ន្ធកូតាដែលមានប្រជាប្រិយភាពបំផុតនៅក្នុងពិភពលោកមាន 2 គឺ: **កូតាតាមរយៈរដ្ឋធម្មនុញ្ញ ឬ នីតិបញ្ញត្តិជាតិ និងកូតាតាមរយៈបញ្ជីឈ្មោះក្នុងគណបក្សនយោបាយ** ។

### ប្រពន្ធ័កូតា : មតិស្រប និងមតិជំទាស់

### មតិជំទាស់

- ប្រព័ន្ធកូតាប្រឆាំងនឹងគោលការណ៍នៃឱកាសស្មើភាពសំរាប់មនុស្សទាំងអស់ ដោយសារស្ត្រីត្រូវបានផ្តល់តាមការចូលចិត្ត ឬ បក្សពួក ។
- ប្រព័ន្ធកូតាដែលមានលក្ខណៈមិនប្រជាធិបតេយ្យមានន័យថា ការបោះឆ្នោតទៅតាមការបង្ហាត់បង្ហាញពីអ្នកណាម្នាក់ ឬ ក្រុមណាមួយ ។ ពីព្រោះអ្នកបោះឆ្នោតគួរតែអាចធ្វើការសំរេចចិត្តដោយខ្លួនឯងថា តើត្រូវបោះឆ្នោតអោយអ្នកណាដោយគ្មានការបង្ខិតបង្ខំពីអ្នកណាឡើយ ។
- ប្រព័ន្ធកូតាកំនត់ថា អ្នកនយោបាយត្រូវបានបោះឆ្នោតជ្រើសតាំងដោយសារតែភេទរបស់ពួកគេ គឺមិនមែនដោយសារលក្ខណៈសម្បត្តិរបស់ពួកគេទេ ហើយបេក្ខជនដែលមានសមត្ថភាពខ្ពស់ជាងត្រូវបានបដិសេធ ។
- ស្ត្រីភាគច្រើនមិនចង់អោយគេបោះឆ្នោតអោយខ្លួនទេ ពីព្រោះតែពួកគេគិតថាពួកគេជាស្ត្រី ។
- ការបង្ហាញប្រព័ន្ធកូតាបង្កើតអោយមានទំនាស់នៅក្នុងគណបក្ស ។

**មតិស្រប**

• ប្រព័ន្ធកូតាសំរាប់ស្ត្រីមិនមែនជាប្រព័ន្ធរើសអើងទេ ប៉ុន្តែ វាជួយដោះស្រាយនូវឧបសគ្គជាក់ស្តែងដែលរារាំងស្ត្រីមិនអោយទទួលបានចំនែកស្មើគ្នាក្នុងអាសនៈនយោបាយរបស់ពួកគេ។

• ប្រព័ន្ធកូតាកំណត់ថា មានស្ត្រីមួយចំនួនធ្វើការរួមគ្នាក្នុងគណៈកម្មាធិការ ឬ សភា ដូចនេះអាចកាត់បន្ថយភាពស្មុគស្មាញរបស់ស្ត្រីដែលមានចំនួនតិចតួច។

• ស្ត្រីមានសិទ្ធិក្នុងការចូលរួមជាតំណាងរបស់ស្ត្រីស្មើគ្នានឹងតំណាងបុរសដែរ។

• ស្ត្រីមានបទពិសោធន៍ខាងនយោបាយវាជាកត្តាចាំបាច់សំរាប់ស្ត្រីធ្វើនយោបាយ។

• ការបោះឆ្នោត គឺសំដៅតំណាងដែលបានទទួលអាសនៈមិនមែនសមត្ថភាពខាងការអប់រំទេ។

• ស្ត្រីមានសមត្ថភាពដូចបុរសដែរ ប៉ុន្តែសមត្ថភាពរបស់ស្ត្រីត្រូវបានកាត់បន្ថយ នៅក្នុងប្រព័ន្ធនយោបាយដែលមានបុរសភាគច្រើន ហើយគ្របដណ្តប់ទៅលើប្រព័ន្ធគ្រប់គ្រងនយោបាយ។

• ការពិតកត្តាសំខាន់នោះ គឺគណបក្សនយោបាយដែលគ្រប់គ្រងលើការជ្រើសរើសបេក្ខ-ជនដែលត្រូវឈរឈ្មោះមិនមែនអ្នកបោះឆ្នោតទេដែលត្រូវសំរេចថា គួរជ្រើសរើសអ្នកណានោះ។

• ប្រព័ន្ធកូតាអាចធ្វើអោយមានទំនាស់ តែទំនាស់ក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ។

**ប្រព័ន្ធកូតាដែលជោគជ័យនាំអោយមាន ៖**

• ការជ្រើសរើសស្ត្រីយ៉ាងសកម្មពីសំណាក់គណបក្សនយោបាយ ដើម្បីអោយមានចំនួនបេក្ខជនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញកូតា។

• មានចំនួនស្ត្រីច្រើនប្រសើរជាងមានចំនួនស្ត្រីតិចពីព្រោះវាអាចជះឥទ្ធិពលដល់ទំលាប់នយោបាយ។

• ស្ត្រីដែលមានលទ្ធភាពអាចជះឥទ្ធិពលដល់ដំណើរការសំរេចចិត្តជាឯកត្តជន ឬ កំណត់ទស្សនៈជាក់លាក់មួយថា ស្ត្រីនិយម។

**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥**

សូមគោរពគណៈអធិបតី ឯកឧត្តម លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិជាទីគោរព !

ខ្ញុំមានសេចក្តីរីករាយបំផុតដោយបានចូលរួមនៅក្នុងវេទិកានាក្នុងថ្ងៃនេះ ដែលវេទិកានេះបានផ្តល់ឱកាសឱ្យស្ត្រីក្រុមប្រឹក្សាមកពីខេត្ត-ក្រុងនានា នៅក្នុងប្រទេសកម្ពុជាស្ត្រី និងបុរសមកពីស្ថាប័នរដ្ឋាភិបាលបណ្តាអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងអង្គការអន្តរជាតិនានាបានជួបជុំគ្នា។ ថ្ងៃនេះជាឱកាសមួយដ៏កម្រដែលយើងទាំងអស់គ្នាបានជួបគ្នា និងពិភាក្សាគ្នាស្តីអំពីថា តើយើងម្នាក់ៗអាចធ្វើអ្វីខ្លះ ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រី និងសំលេងរបស់ពួកគេនៅក្នុងសាលាឃុំ-សង្កាត់។

នៅក្នុងពេលព្រឹកនេះ លោកស្រី **ប៉ុក ណណ្ត** បានបកស្រាយអំពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយនៅថ្នាក់ឃុំ សង្កាត់។ លោកស្រីបានលើកឡើងថា ដើម្បីធ្វើអោយរដ្ឋបាលថ្នាក់មូលដ្ឋានផ្តល់នូវផលប្រយោជន៍ឱ្យបានគ្រប់ អ្នកដែលបោះឆ្នោតអោយពួកគេត្រូវយល់ និងធ្វើការពិចារណាអំពីបទពិសោធន៍ និងតម្រូវការផ្សេងៗ ពីគ្នាទាំងរបស់ស្ត្រី និងបុរស។ ការងារនេះអាចសំរេចទៅបានដរាបណាមានការចូលរួមដ៏សកម្មរបស់ស្ត្រី។ ការធ្វើឱ្យទាំងបុរស និងស្ត្រីចូលរួមនៅក្នុងការធ្វើនយោបាយ និងការសម្រេចចិត្តពិតជានឹងធ្វើឱ្យបញ្ហាផ្សេងៗនៅក្នុងថ្នាក់មូលដ្ឋានត្រូវបានគិតគូរនឹងអាចដែលជាបញ្ហាស្នូលទាក់ទងនឹងលិទ្ធិប្រជាធិប-តេយ្យ និងអភិបាលកិច្ចល្អក៏ដូចជាការអភិវឌ្ឍន៍ដែលឯកឧត្តម **ព្រុំ សុខា** បានធ្វើការពិភាក្សា។ គេបានយល់ច្បាស់ហើយយល់ស្របថាយុទ្ធសាស្ត្រដើម្បីកាត់បន្ថយភាពក្រីក្រនឹងបានទទួលជោគជ័យតែនៅពេលណាដែលតម្រូវការរបស់បុរស និងស្ត្រីត្រូវបានគេគិតគូរពិចារណា។ ទាំងនេះសុទ្ធតែជាចំនុចសំខាន់មួយចំនួនទាក់ទិននឹងសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយ។ វិមាត្រមួយទៀតនៃសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយគឺការផ្តល់អំណាចឱ្យស្ត្រី។ ខ្ញុំប្រើប្រាស់ពាក្យថា **"ផ្តល់អំណាច"** នៅក្នុងន័យថា ការចូលរួមនៅក្នុងវិស័យនយោបាយបានផ្តល់ឱកាសឱ្យស្ត្រីកម្ពុជាទាញយក និងអនុវត្តមិនត្រឹមតែជំនាញចំណេះដឹង និងបទពិសោធន៍ផ្សេងៗ នៅក្នុងជីវិតពួកគេទាំងឡាយនោះទេ ប៉ុន្តែសក្តានុពលរបស់ពួកគេដែលមិនទាន់ត្រូវបានគេយកមកប្រើប្រាស់ក៏នឹងត្រូវបាននាំមកបញ្ចូលនៅក្នុងការចូលរួមរបស់ពួកគេដែរ។

ក្រុមប្រឹក្សាឃុំ-សង្កាត់ និងលិទ្ធិប្រជា-ធិបតេយ្យនៅថ្នាក់មូលដ្ឋាន គឺនៅមានភាពថ្មី

ថ្នោងនៅក្នុងប្រទេសកម្ពុជានៅឡើយទេ។ ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយនៅថ្នាក់មូលដ្ឋានក៏ថ្មីដែរ។ ខ្ញុំពេញចិត្តករណីសិក្សាដែលបង្ហាញដោយលោកស្រី **រស់ សុភាព** ដែលបង្ហាញនូវផលប៉ះពាល់ជាសក្តានុពលនៃការចូលរួមរបស់ស្ត្រីនៅក្នុងការិយាល័យ។ ជាពិសេសជាងនេះទៀត ខ្ញុំពេញចិត្តត្រង់ចំនុចដែលបានបង្ហាញថា ស្ត្រីនៅក្នុងការិយាល័យអាចធ្វើអោយមានលទ្ធផលការងារច្រើន បើទោះបីជាពួកគេមានសមត្ថភាពទាប ឬ មួយក៏ពួកគេមិនចេះអាន ឬ សរសេរក៏ដោយ។

ចំនុចនេះមិនមានន័យថា ស្ត្រីក្រុមប្រឹក្សាខ្វះសមត្ថភាពទេនៅប្រទេសកម្ពុជា។ មានសារៈប្រយោជន៍ខ្លាំងណាស់ដោយយើងបានដឹងពីកញ្ញា **អេង នេត្រា** ដែលថាស្ត្រីក្រុមប្រឹក្សាជាទូទៅពុំមានការអប់រំតិចតួចប៉ុន្មានទេបើប្រៀបធៀបទៅនឹងបុរស។ ខ្ញុំអាចនិយាយបានថា តាមរយៈបទពិសោធន៍ការងារផ្ទាល់ខ្លួនរបស់ខ្ញុំ ខ្ញុំបានមើលឃើញច្បាស់អំពីសមត្ថភាពជាក់ស្តែងរបស់ស្ត្រីក្រុមប្រឹក្សាឃុំនៅក្នុងប្រទេសកម្ពុជា។ ពិតណាស់លោកស្រី **វង់ ស៊ូ** លោកស្រី **គង់ ផល្លី** និងលោកស្រី **ហាក់ លី** គឺជាឧទាហរណ៍នៃចំនុចដែលបានលើកឡើងខាងដើម។ ខ្ញុំមានឱកាសចូលរួមនៅក្នុងការរៀបចំវេទិកាសម្រាប់ស្ត្រីក្រុមប្រឹក្សានៅក្នុងខេត្តចំនួន ៧ នៅក្នុងប្រទេសកម្ពុជាដែលវេទិកាទាំងនេះ ត្រូវបានសម្របសម្រួលដោយអង្គការចំរើនស្ត្រី។ វេទិការបស់ស្ត្រីក្រុមប្រឹក្សាមិនផ្តល់ការបណ្តុះបណ្តាលទេ ប៉ុន្តែវេទិកាទាំងឡាយផ្តល់ឱកាសឱ្យស្ត្រីក្រុមប្រឹក្សាដែលជាអ្នកចូលរួមនៅក្នុងវេទិកា ដើម្បីរួមគ្នាបង្កើតជាយុទ្ធសាស្ត្រផ្ទាល់របស់ពួកគេក្នុងការដោះស្រាយបញ្ហាដែលពួកគេជួបប្រទះក្នុងនាមជាស្ត្រីក្រុមប្រឹក្សា។ នៅក្នុងវេទិកាទាំងនេះខ្ញុំបានមើលឃើញថា បទពិសោធន៍ និងគតិបណ្ឌិតរួមរបស់ស្ត្រីក្រុមប្រឹក្សាបានផ្តល់កំណើតដល់យុទ្ធសាស្ត្រមួយចំនួន ដើម្បីធ្វើការដោះស្រាយបញ្ហាផ្ទាល់ខ្លួន និងបញ្ហាទាក់ទងនឹងជីវភាពការងាររបស់ពួកគេ។ យុទ្ធសាស្ត្រទាំងឡាយដែលពួកគេបានបង្កើតឡើងដោយខ្លួនឯងផ្ទាល់បានធ្វើឱ្យជីវិតរបស់ពួកគេមានភាពខុសប្លែកពីមុន។ នៅក្នុងករណីមួយចំនួនយុទ្ធសាស្ត្ររបស់ពួកគេត្រូវបានឱ្យតម្លៃ និងអនុម័តឱ្យប្រើប្រាស់ដោយក្រុមប្រឹក្សារបស់ពួកគេទៀតផង។

តាមរយៈការអង្កេតមើលរបស់ខ្ញុំ ស្ត្រីក្រុមប្រឹក្សាកំពុងតែមានការរីកចម្រើននៅក្នុងការបំពេញតួនាទីរបស់ពួកគេរឹតតែមានការជឿជាក់លើខ្លួនឯង និងសមត្ថភាពកាន់តែកើនឡើងដែរ។ នៅក្នុងថ្ងៃនេះ យើងទាំងអស់គ្នាបានដឹងអំពីឧទាហរណ៍មួយដ៏ប្រសើរទាក់ទងនឹងចំនុចនេះគឺលោកស្រី **វង់ ស៊ូ** និងស្ត្រីពីរនាក់ទៀតបានទទួលជោគជ័យនៅក្នុងការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារនៅក្នុងឃុំរបស់គាត់។ តាមរយៈបទពិសោធន៍ដែលស្ត្រីក្រុមប្រឹក្សាទាំងឡាយបានទទួលចាប់តាំងពីចូលកាន់តួនាទីបន្ទាប់ពីការបោះឆ្នោតនៅក្នុងឆ្នាំ ២០០២ ស្ត្រីក្រុមប្រឹក្សាបានក្លាយទៅជាទ្រព្យសម្បត្តិដ៏មានតម្លៃរបស់ប្រទេសកម្ពុជា ដែលទ្រព្យសម្បត្តិដ៏មានតម្លៃទាំងនេះសមនឹងទទួលបានការវិនិយោគ និងគាំទ្រ

បន្ថែម។ ជាមួយនឹងបទពិសោធន៍ដែលពួកគេបានទទួលបន្ទាប់ពីការបោះឆ្នោតឆ្នាំ ២០០២ គេអាចរំពឹងទុកថា ស្ត្រីក្រុមប្រឹក្សាដែលនឹងឈរឈ្មោះបោះឆ្នោតនៅក្នុងឆ្នាំ ២០០៧ និងស្ត្រីដែលត្រូវបានគេបោះឆ្នោតឱ្យម្តងទៀតនឹងបន្តរីកចំរើនចូលរួមកាន់តែច្រើន នៅក្នុងការបំពេញការងារដែលជាផលប្រយោជន៍របស់ស្ត្រីក៏ ដូចជាផលប្រយោជន៍របស់អ្នកដែលបានបោះឆ្នោតឱ្យពួកគេទាំងអស់ផងដែរ។ ហើយលើសពីនេះទៅទៀតចំនុចនេះនឹងជម្រុញឱ្យមានការចូលរួមឈរឈ្មោះបោះឆ្នោតពីសំណាក់ស្ត្រីកាន់តែច្រើនជាងមុនថែមទៀត។

តែទោះជាយ៉ាងណាទស្សនៈវិស័យនេះមិនទំនងជាលក្ខណៈល្អប្រសើរទាំងស្រុងនោះទេ។ មានស្ត្រីក្រុមប្រឹក្សាមួយចំនួនមានបំណងចង់ឈប់ពីការងាររបស់ពួកគេ ហើយមានខ្លះបានសម្រេចចិត្តរួចហើយថានឹងមិនឈរឈ្មោះបោះឆ្នោតទៀតឡើយនៅក្នុងឆ្នាំ ២០០៧។ ស្ត្រីទាំងនេះ គឺជាស្ត្រីដែលបានប្រឈមមុខនឹងការលំបាកផ្សេងៗ នៅក្នុងគ្រួសារ និងការទទួលខុសត្រូវនៅក្នុងការងាររបស់ក្រុមប្រឹក្សាឃុំដូចដែលបានពិពណ៌នាដោយកញ្ញា **អេង នេត្រា**។ ស្ត្រីក្រុមប្រឹក្សាមួយចំនួនខ្វះការគាំទ្រពីក្រុមគ្រួសារ និងកូនៗរបស់ពួកគេ។ អ្នកខ្លះទៀតខ្វះការគាំទ្រទាំងនៅក្នុងក្រុមប្រឹក្សា និងនៅក្នុងគ្រួសារ។

ខ្ញុំបានមើលឃើញទឹកភ្នែកបានស្រក់ចេញពីដួងនេត្រារបស់ស្ត្រីក្រុមប្រឹក្សាម្នាក់នៅក្នុងខេត្តបាត់ដំបង ដោយសារតែស្វាមីរបស់គាត់ជារៀងរាល់ថ្ងៃតែងតែធ្វើឱ្យគាត់ដឹងច្បាស់ថា មិនចង់ឱ្យគាត់ទៅធ្វើការនៅក្នុងក្រុមប្រឹក្សាឡើយ។ ខ្ញុំក៏បានមើលឃើញទឹកភ្នែកបានស្រក់ចេញពីកែវភ្នែករបស់ស្ត្រីក្រុមប្រឹក្សាម្នាក់ទៀត ដែលមានវ័យក្មេងនៅក្នុងខេត្តសៀមរាប ដែលបានបង្ហាញពីបំណងរបស់គាត់ថាចង់ឈប់ពីការងារដោយសារតែការ-ងារជាជំទប់ទីពីររបស់គាត់ត្រូវបានមេឃុំទទួលខុសត្រូវទៅវិញ។ ខ្ញុំបានឮស្ត្រីក្រុមប្រឹក្សាជាច្រើនអ្នកទៀតដូចជា លោកស្រី **គង់ ផល្លី** និងលោកស្រី **ហាក់ លី** ដែលថាពួកគាត់ត្រូវបានគេមិនយកចិត្តទុកដាក់នៅក្នុងរង្វង់ក្រុមប្រឹក្សាឃុំពោល គឺមិនហៅឱ្យចូលរួមប្រជុំមិនបានផ្តល់ឱ្យពួកគាត់នូវឯកសារទាក់ទងនឹងក្រុមប្រឹក្សាឃុំរបស់ពួកគាត់ តែឯកសារទាំងនោះត្រូវបានផ្តល់ឱ្យតែបុរសដែលជាក្រុមប្រឹក្សា។ ស្ត្រីក្រុមប្រឹក្សាខ្លះទៀតបានឱ្យយើងដឹងថា ពួកគេត្រូវបានគេឱ្យឆុងទឹកតែសម្រាប់បុរសក្រុមប្រឹក្សាតែមិនត្រូវបានអនុញ្ញាតិឱ្យចូលរួមក្នុងការធ្វើការសម្រេចចិត្ត។

យើងម្នាក់ៗត្រូវសួរសំណួរថា **តើខ្ញុំអាចធ្វើអ្វីខ្លះ ដើម្បីគាំទ្រស្ត្រីក្រុមប្រឹក្សា?** តើខ្ញុំអាចធ្វើអ្វីខ្លះ ដើម្បីគាំទ្រស្ត្រីក្រុមប្រឹក្សា និងស្ត្រីដទៃទៀតដើម្បីឱ្យពួកគេឈរឈ្មោះបោះឆ្នោតនៅក្នុងឆ្នាំ ២០០៧ ? បទចំណាប់អារម្មណ៍របស់លោកស្រី **ធីតា ឃឹះ** ត្រូវបានទទួលការស្ញើចសរសើរ ដោយសារចំណាប់អារម្មណ៍របស់លោកស្រីបានផ្តល់ជាគោលការណ៍ណែនាំនៅក្នុងការស្វែងរកចំលើយចំពោះសំនួរទាំងឡាយខាងលើ។ នៅក្នុងការពិភាក្សានៅក្នុងក្រុមតូចៗ នៅក្នុងពេលរសៀលនេះ យុទ្ធសាស្ត្រដែលមានការគិតគូរ

ជិតដល់ត្រូវបានពិភាក្សាគ្នា ដើម្បីលើកកម្ពស់ការគាំទ្រពីសំណាក់អង្គការក្រៅរដ្ឋាភិបាល។ ខ្ញុំសង្ឃឹមថា ថ្ងៃនេះគឺជាការពិភាក្សាទីមួយនៅក្នុងចំណោមការពិភាក្សាទាំងឡាយដែលនឹងត្រូវធ្វើឡើងជាបន្តបន្ទាប់ ហើយសង្ឃឹមថាយើងទាំងអស់នឹងមានឱកាសនៅក្នុងពេលអនាគតដើម្បីជួបគ្នាពិភាក្សានឹងចាត់វិធានការណ៍ ដើម្បីគាំទ្រស្ត្រីកម្ពុជាដែលកំពុងកាន់មុខតំណែងក្នុងវិស័យនយោបាយក៏ដូចជាស្ត្រីផ្សេងៗទៀត ដើម្បីជម្រុញឱ្យពួកគេឈរឈ្មោះបោះឆ្នោតនៅក្នុងពេលអនាគត ។

ខ្ញុំសូមចូលរួមជាទស្សនៈចំពោះស្ត្រី ក្រុមប្រឹក្សាដែលមានវត្តមាននៅទីនេះថា នៅក្នុងអំឡុងពេលពេញមួយឆ្នាំ កាលពីឆ្នាំមុនខ្ញុំមានកិត្តិយសបំផុតដោយបានធ្វើការដោយផ្ទាល់ជាមួយស្ត្រីក្រុមប្រឹក្សា។ អ្នកទាំងអស់បានបង្កើតនូវអ្វីមួយដែលថ្មី ហើយស្នាដៃរបស់អ្នកបានធ្វើឱ្យមានការងាយស្រួលសម្រាប់កូនស្រី និងចៅស្រីរបស់អ្នកក្នុងការឈរឈ្មោះបោះឆ្នោត និងបំពេញការងារ ដោយប្រើប្រាស់បាននូវសក្តានុពលទាំងឡាយដែលពួកគេមាន។ អ្នកបានបង្ហាញថា ស្ត្រីអាចធ្វើការងារជាអ្នកដឹកនាំ និងជាដៃគូរការងារបានយ៉ាងមានប្រសិទ្ធិភាព។ ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកទាំងអស់គ្នា ចំពោះការខិតខំធ្វើដំណើរពីបណ្តាខេត្តនានា មកកាន់ទីក្រុងភ្នំពេញដើម្បីចូលរួមនៅក្នុងវេទិកាដ៏ឧឡារិកនេះនឹងធ្វើឱ្យវេទិកានេះទទួលបាននូវជោគជ័យជាផ្លែផ្កា។

ខ្ញុំសូមថ្លែងអំណរគុណ ជាពិសេសចំពោះលោកស្រី **ហាក់ លី** លោកស្រី **គង់ ផល្លី** និងលោកស្រី **វង់ ស៊ូ** ដែលបានបង្ហាញបញ្ហារបស់លោកស្រីចំពោះពួកយើងទាំងអស់គ្នានៅក្នុងវេលាថ្ងៃនេះ។ លោកស្រីទាំងអស់គ្នាបានជួយពួកយើងទាំងអស់គ្នាឱ្យបានយល់ដឹងកាន់តែប្រសើរឡើងនូវស្នាដៃ និងការប្រឈមមុខរបស់ស្ត្រីកម្ពុជានៅក្នុងសាលាឃុំ។

ខ្ញុំសូមអរគុណជាពិសេសផងដែរ ចំពោះលោកស្រី **រស់ សុភាព** និងបុគ្គលិករបស់អង្គការយេនឌ័រ និងការអភិវឌ្ឍន៍ ដើម្បីកម្ពុជា ដែលបានរៀបចំវេទិកា និងបង្កើតការពិភាក្សាទៅលើប្រធានបទថា តើយើងទាំងអស់គ្នាអាចធ្វើយ៉ាងណាដើម្បីគាំទ្រ និងលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងឆាកនយោបាយនៅក្នុងថ្ងៃនេះ។

កញ្ញា **Shelley Flam** ទីប្រឹក្សារបស់អង្គការ GTZ ផ្នែកកសាងសមត្ថភាព និងសង្គមស៊ីវិល។